ជំនួយស្មារតី

កំណែប្រែទី៣

បទានុក្រម
ភាសាខ្មែរចំនើប

ថ្នាក់ទី៦ ២៨៦៣ក្យ


ថ្នាក់ទី៥ ២៦៥៣ក្យ

ថ្នាក់ទី៤ ១៧៤៣ក្យ

ថ្នាក់ទី៣ ៤៩៣៣ក្យ

ថ្នាក់ទី២ ២៦៨៣ក្យ

ថ្នាក់ទី១ ០៦៤៣ក្យ



ឆាហារណ៍តាមនំយ ពាក្យតាមរមៀន
លម្អិត-ខ្លី-ចំ ចាយប្រើ ចំរណាញ្ញរោស
ព.ស.២៥៦៨ រ៉ា ឆែលាម គ.ស.២០២៥

បទានុក្រមពន្យល់ពាក្យភាសាខ្មែរអំនើបថ្នាក់បឋម

មេពាក្យ	ចំណាត់ក្រុមពាក្យ	សេចក្តីពន្យល់	ថ្នាក់ទី
ក		ក	
កខ្វក់	គុ.	ដែលគគ្រិចមិនស្អាត ដែលស្មោកគ្រោក។ ឧ. សុខាមិនយកដៃកខ្វក់ទៅជូតនឹងខ្លួន។	៣
កងឈ្លប	ន.	ក្រុមស៊ើបការណ៍នៅក្នុងសម័យខ្មែរក្រហម។	៥
កញ្ជ្រៀប	គុ.	ដែលបះឡើងខ្ពើបទៅលើ។ ឧ. ស្លឹកត្រចៀកកញ្ជ្រៀប, ស្មាកញ្ជ្រៀប។	៤
កញ្ចាំង	ន.	ឈ្មោះក្បាច់រចនាមានទំនងផ្សេងៗ ដែលហៅថាក្បាច់កញ្ចាំងច្រើនធ្វើពីស្ពាន់ក្រាប។ ឧ. ក្បាច់កញ្ចាំងមានដូចជាក្បាច់កញ្ចាំងរាយ កញ្ចាំងដុំ កញ្ចាំងត្របកទំពាំងជាដើម។	៦
កណ្តុរ	ន.	សត្វកកេរមាឌមធ្យម មានកន្ទុយវែង, ជាសត្វកាត់បំផ្លាញសំពត់អាវ ស៊ីស្រូវជាដើម។ ឧ. កណ្តុរជាសត្វចង្រៃ។	៣
កណ្តៀវ	ន.	ប្រដាប់ធ្វើដោយដែកមានផ្លែខុប សម្រាប់ច្រូតស្រូវ ច្រូតស្មៅជាដើម។	៥
កតញ្ញូ	គុ.	ដែលដឹងឧបការគុណដែលអ្នកឯទៀតបានធ្វើដល់ខ្លួន។ ឧ. កុលបុត្រខ្មែរត្រូវមានចិត្តកតញ្ញូ។	៣, ៦
កត្តា	ន.	អ្នកធ្វើ អ្នកផ្តើមធ្វើ, បុព្វហេតុឬសមាសភាពដែលជះឥទ្ធិពល។ ឧ. កត្តាដែលនាំឱ្យខ្ញុំបានជោគជ័យគឺកត្តាគ្រួសារ កត្តាសង្គមល្អ ជាពិសេសកត្តាជឿជាក់លើខ្លួនឯង។ ឧ. នាងធ្វើការលឿន ដោយដឹងអំពីកត្តាពេលវេលា។	៦
កន្តឹប	ន.	ឈ្មោះមួកដែលអ្នកកាន់សាសនាមហាម៉ាត់ពាក់។ ឧ. បុរសឥស្លាមពាក់មួកកន្តឹបដើរសំដៅវិហារ។	២
កន្តើយ	គុ.កិ.	ព្រងើយ មិនយកចិត្តទុកដាក់។ ឧ. កុំនៅកន្តើយ តស់យើងទៅរៀន។	២
កន្តើយ	គុ.កិ.	ព្រងើយ មិនយកចិត្តទុកដាក់។ ឧ. មិត្តកុំនៅកន្តើយ ពួកយើងទៅសាលារៀន។	២

កន្ត្រាក់	កិ. ទាញកញ្ឆក់ដោយប្រញាប់ ទាញកញ្ឆក់យ៉ាងខ្លាំង។ ឧ. ឆ្កែភ័យពេក កន្ត្រាក់មួយទំហឹងដាច់ខ្សែ រួចបោលប្រុច។	៣
កន្ត្រែ	ន. ប្រដាប់សម្រាប់កាត់សំពត់...ឬសក់ មានផ្លែដែកមុខមុតពីរ។ ឧ. ឪនយ៉ារីតាមដណ្តើមក្រដាស កាំបិត ឬកន្ត្រែពីបង។	៤
កន្ត្រោង	កិ. លោតខាំ លោតចាប់។ ឧ. ឆ្កែកន្ត្រោងកូនក្មេង។ ក្មេងកន្ត្រោងបេះផ្លែស្វាយ។	៤
កន្ទោង	ន. ភាជន៍ធ្វើដោយស្លឹកសម្រាប់ដាក់ភោជនាហារ...ស្លាបារីបាន។ ឧ. យាយៗធ្វើកន្ទោងទុកចីបបាយដាក់ ពេលរាប់បាត្រ។	៦
កន្ទ្រុល	គុ. រល ននលមិនសមរម្យ។ ឧ. តុលាមានរាងធាត់កន្ទ្រុល។	២
កន្ទ្រើង	គុ. សំពោងមិនរាបទាប។ ឧ. នាងមានសក់កន្ទ្រើង។	៥
កម្ចី	គុ. ១.អ្វីដែលនៅខ្ចី។ ឧ. សុខបេះផ្លាក់ស្វាយកម្ចីច្រើន។ ២.ន. របស់ឬប្រាក់ដែលបានខ្ចីហើយត្រូវទូទាត់សងវិញ។ ឧ. ខ្ញុំនៅជាប់កម្ចីច្រើនដែរ។	២
កម្ចេចកម្ចី	កិ. អ្វីៗដែលខ្ចេចខ្ចី សំណល់ពីការកម្ទេចបំផ្លាញ។ ឧ. ក្រុមសង្គ្រោះកាយកម្ទេចកម្ចីអគារបែកបាក់។	៣
កម្ម	ន. អំពើ ទោះអំពើល្អក្តីអាក្រក់ក្តី ក៏ហៅថាកម្ម។ ឧ. បុញ្ញកម្ម គឺអំពើល្អទាំងឡាយដែលចាត់ទុកជាបុណ្យ។	៣
កម្មករ	ន. អ្នកធ្វើការយកកម្រៃ...ភាគច្រើនខាងហត្ថកម្ម។ ឧ. ប្រទេសយើងនៅខ្វះកម្មករជំនាញច្រើន។	៣
កម្មសិទ្ធិ	ន. ទ្រព្យសម្បត្តិដែលសម្រេចមកលើខ្លួន, សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ។ ឧ. សៀវភៅនេះជាកម្មសិទ្ធិរបស់គាត់។	៥
កម្រ	គុ. ដែលមិនសម្បូរ។ ឧ. សត្វក្រៀលជាសត្វដ៏កម្រ។	៦
កម្រាល	ន. របស់សម្រាប់ក្រាល។ ឧ. ពូទិញកម្រាលព្រំ។	២
កម្រៃ	ន. អ្វីៗដែលចំណេញ ដែលបានមកលើសដើម។ ឧ. យើងលក់ដំណាំក្រោយផ្ទះយកកម្រៃខ្លះ។	៣
កម្សត់	គុ. ដែលក្រខ្សត់ ដែលក្រីក្រលំបាក។ ឧ. ឆ្នាំច្លូបបុរសកម្សត់។	៣

កម្សាន្ត	កិ. ធ្វើឱ្យក្សាន្តចិត្ត លម្ហើយចិត្តឱ្យសប្បាយ ។ ឧ. ពួកយើងលេងល្បែងកម្សាន្ត អារម្មណ៍បានធូរ។ ឧ. ពេលមានទុក្ខ យើងគួរដើរកម្សាន្តបន្តិចឱ្យធូរចិត្ត។ ឧ. គន្ធាដើរកម្សាន្តគ្រប់ទីកន្លែង។ ឧ. ឯងត្រូវចេះកម្សាន្តនឹងជីវិត។	២; ៣; ៤; ៥
កម្ទេល	ន. ចំហាយ ឬអំណាចនៃការឆួល។ ឧ. ព្រះអាទិត្យផ្សព្វផ្សាយកម្ទេល ក្តៅគ្រប់ទិសទី។	៤
កល្យាណមិត្ត	ន. មិត្តល្អនិងត្រឹមត្រូវដែលបុគ្គលគួរសេពគប់គួររាប់រកជាគ្នា។ ឧ. កូនត្រូវចេះរក្សាកល្យាណមិត្ត។	៥
ករី	ន. អ្នកតែងកំណាព្យ។ ឧ. លោកគ្រូសាតជាករីដ៏ក្រហម។	៥
កសិកម្ម	ន. ការធ្វើស្រែចម្ការឬចិញ្ចឹមសត្វ។ ឧ. យើងគប្បីជួយទិញផលកសិកម្មស្រុកយើងជាង។ ឧ. វិស័យកសិកម្មកាន់តែអភិវឌ្ឍ, ចុះកសិផល? ឧ. ផ្ទៃដីជុំវិញបឹងទន្លេសាបមានជីវជាតិសម្រាប់កសិកម្ម។	២; ៣; ៤
កសិករ	ន. អ្នកធ្វើស្រែចម្ការឬចិញ្ចឹមសត្វ។ ឧ. កសិករជាអ្នកមានគុណ។ ឧ. គ្មានកសិករ គ្មានអាហារ គ្មានអនាគត។	២; ៣
កសិដ្ឋាន	ន. ទីឋានដាំដំណាំឬចិញ្ចឹមសត្វ គឺដីរួមទាំងផ្ទះនិងអគារ។ ឧ. គ្រូនាំសិស្សទៅមើលកសិដ្ឋានដាំបន្លែ។ ឧ. អ្នកខ្លះទៀតចង់គ្រប់គ្រងកសិដ្ឋានធំៗ។ ឧ. ពួកគេក៏បានទៅដល់កសិដ្ឋាននោះ។	៣; ៥; ៦
កាកគតិ	ន. ឈ្មោះបទកាព្យពាក្យ៤ (បទដំណើរក្អែកលោត)។ ឧ. បទកាកគតិនេះ គេអាចសូត្របាន១២បែប។	២
កាកសំណល់	ន. វត្ថុដែលសល់ពីការប្រើប្រាស់។ ឧ. ពូសុខយកកាកសំណល់ផ្ទះបាយទៅផ្សំធ្វើចំណីត្រី។	៣
កាតព្វកិច្ច	ន. ការងារដែលត្រូវតែធ្វើ ចំណងផ្លូវច្បាប់ដែលបង្ខំឱ្យត្រូវតែធ្វើ។ ឧ. តើការបញ្ជូនកូននៅរៀនជាកាតព្វកិច្ចរបស់ឪពុកម្តាយឬ?	៥
កាន់វស្សា	ន. នៅរក្សាអរុណក្នុងរដូវភ្លៀងក្នុងទីមានកំណត់របស់អ្នកបួសខាងពុទ្ធសាសនា។ ឧ. តថាគតអនុញ្ញាតឱ្យភិក្ខុចូលឬកាន់វស្សាចាប់ពីពេលនោះ។	៥

កាផា	ន. សម្ភារៈប្រើប្រាស់ស្រដៀងនឹងជាល កម្ពស់ខ្ពស់ជាង មានខ្សែសម្រាប់ស្ពាយពីក្រោយខ្នងដែលជនជាតិដើមភាគតិចនិយមប្រើ។ ឧ. យុវជនចាំយស្ពាយកាផាទៅចម្ការ។	១
កាមគុណ	ន. ដំណើរចម្រើននៃសេចក្តីប្រាថ្នានូវអារម្មណ៍ទាំង៥ គឺរូប សំឡេង ក្លិន រស និងសម្ផស្ស។ ឧ. អ្នកណាមួយតែងបរិភោគកាមគុណ នឹងដល់នូវសេចក្តីមិនចម្រើន ដល់នូវវិនាស។	៦
កាយ	ក. ទាញ ប្រមូលដោយដៃ ជើង ឬឧបករណ៍ផ្សេងៗ។ ឧ. មាន់កាយដីរកចំណី។	៣
កាយ	ន. រូបដែលជាទីប្រជុំអាការៈ៣២មានសក់ រោម ក្រចកជាដើម រួមទាំងអស់ហៅថា កាយ។ ឧ. ចិត្តទន់ខ្សោយនាំឱ្យកាយងាយឈឺទ្រុឌទ្រោម។	៣
កាយវិការ	ន. ការកម្រើកនៃកាយ, ចលនានៃកាយ។ ឧ. នារីច្រៀងផង ធ្វើកាយវិការផង។	៣
កាយា	ន. រូប ខ្លួន ខ្លួនប្រាណ។ ឧ. នារីញញឹម រៀបចំកាយា។	២
ការ	ក. មូរសរសៃសូត្រ សរសៃអំបោះជាដើមដោយខ្នារ។ ឧ. ពេលទំនេរ ក្មេងៗជួយរវៃនិងការសូត្រ។	៤
ការងារ	ន. កិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន។ ឧ. ថ្ងៃសម្រាក ខ្ញុំទៅជួយការងារពុកនៅចម្ការ។	៣
ការដ្ឋាន	ន. កន្លែងធ្វើការងារ, ទីនៃការងារ។ ឧ. ពេលដល់ការដ្ឋានធ្វើផ្លូវ កូនត្រូវជិះប្រយ័ត្នប្រយែង។	៣
ការដ្ឋានសំណង់	ន. ទីកន្លែងកំពុងធ្វើការសាងសង់។ ឧ. តាឌីដើរសំដៅការដ្ឋានសំណង់។	៣
ការណ៍	ន. ហេតុ ដំណើរ។ ឧ. អ្នករាយការណ៍មកហើយ។	៤,៦
ការសូត្រ	ក. មូរសរសៃសូត្រ សរសៃអំបោះជាដើមដោយខ្នារ។ ឧ. ពេលទំនេរ ក្មេងៗជួយរវៃនិងការសូត្រ។	២
ការអភិរក្ស	ន. ការរក្សាដោយប្រយ័ត្ន។ ឧ. សត្វព្រៃខ្លះឈានដល់ការផុតពូជ ដោយសារគ្មានការអភិរក្ស។	៤

ការអភិវឌ្ឍ	ន. ការលូតលាស់ចម្រើន ការចម្រើនក្រៃលែង។ ឧ. ពួកគាត់ចងក្រងជាសមាគមដើម្បីទទួលបានការអភិវឌ្ឍដូចគ្នានិងការពារផលប្រយោជន៍រួម។	៤
ការអំពោះ	កិ. មូរសរសៃអំបោះ។ ឧ. នារីជួយការអំបោះ។	១
កាលៈទេសៈ	ន. សម័យកាលរបស់ស្រុកទេស។ ឧ. មុននឹងប្រកបមុខរបរផ្សេងៗ គប្បីពិចារណាលៃលកមើលឱ្យសមរម្យទៅតាមកាលៈទេសៈ។	៥
កិច្ចកល	ន. អំពើដែលជាល្បិច ជាស្នៀត ជាការបញ្ឆោត។ ឧ. ប្តីនាងក៏មិនអាចដឹងដល់កិច្ចកលនោះឡើយ។	៤
កិច្ចការ	ន. ការដែលត្រូវធ្វើ ការងារផ្ទាល់ខ្លួនដែលត្រូវធ្វើ។ ឧ. កូនៗទៅវិញ កុំភ្លេចធ្វើកិច្ចការផ្ទះភ្លាម។ ឧ. ម៉ែមើលសព្វកិច្ចការក្នុងគេហដ្ឋាន។ ឧ. យើងទៅសាលា រៀនសព្វកិច្ចការ រៀនកត់ចំណាំ...។	២; ៣; ៦
កិត្តិនាម	ន. កេរ្តិ៍ឈ្មោះ នាមល្បីល្បាញ។	៥
កិត្តិយស	ន. យសសក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង។ ឧ. ការធ្វើល្អនឹងផ្សាយកិត្តិយសជាងនិយាយ។	៣, ៦
កិន	ន. សង្កត់ឱ្យបែក ស៊ីចុកទំពារដូចគេកិន។ ឧ. មាត់ឯងចេះតែកិនហ្មង អស់ម៉ានអស់ទៅ អត់ខ្វល់?	៣
កិរិយា	ន. អំពើ ឫកពា។ ឧ. សុខាមានកិរិយាល្អ។	៣
កិរិយាសព្ទ	ន. សម្តីសម្តែងកិរិយា គឺពាក្យប្រាប់អំពើ។ ឧ. តើនរណាអាចរកកិរិយាសព្ទបាន?	៣
កិលេស	ន. សេចក្តីសៅហ្មងចិត្ត។ ឧ. ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរៀនលះបង់កិលេស ... និងកាមគុណឱ្យអស់ជាទីបំផុត។	៦
កុកសាប់	ន. ប្រភេទកុកម្យ៉ាងមានសប្បរប្រផេះដូចសំបកទំពាំង។ ឧ. ចូរត្រាប់កុកសាប់ កុំត្រាប់កុកស។	១
កុដិ	ន. ខ្ទម ផ្ទះ លំនៅរបស់អ្នកបួស។ ឧ. ពួកគាត់ធ្វើបុណ្យផ្តាំដើម្បីកសាងកុដិ។	២; ៦
កុដុម្ពិកៈ	គុ. អ្នកមានសម្បត្តិដោយផលប្រយោជន៍កើតអំពីស្រែចម្ការដំណាំ។	៦

កុមារមេត្រី	គុ. ដែលជាទីសប្បាយរីករាយរបស់កុមារ។ ឧ. សាលាយើងនៅខ្វះបរិស្ថានកុមារមេត្រី។	៣
កុមារាកុមារី	ន. ក្មេងប្រុសស្រី។ ឧ. កុមារាកុមារីទាំងឡាយគួរលេងល្បែងណាដែលមានប្រយោជន៍និងមិនបណ្តាលឱ្យមានគ្រោះថ្នាក់។	២
កុលធីតា	ន. កូនស្រីនៃត្រកូល, កូនស្រីអ្នកមានត្រកូល។ ឧ. កុលបុត្រកុលធីតាខ្មែរត្រូវមានចិត្តកតញ្ញូ។	៣
កុលបុត្រ	ន. កូនប្រុសនៃត្រកូល កូនប្រុសអ្នកមានត្រកូល។	៣
កុសល	ន. កម្មដែលកម្ចាត់បង់នូវអំពើអាក្រក់។ ឧ. សូមកុសលដែលខ្ញុំបានធ្វើជួយការពារអ្នកទាំងអស់គ្នា។ ឧ. គេប្រគេនចង្ហាន់ វត្ថុផ្សេងៗ និងរាប់បាត្រដើម្បីបញ្ជូនកុសលដល់ញាតិដែលបានចែកឋាន។	២; ៦
កុហក	គុ. ដែលបំភាន់ជំនឿគេ។ ឧ. គាត់ជាមនុស្សកុហក ព្រោះប្រើពាក្យកុហកច្រើនដង។ កិ. និយាយឱ្យគេភាន់ជំនឿ។ ឧ. កុំកុហកគេ...បាប។	៦
កុះករ	គុ. ច្រើន បរិបូណ៌ ដេរដាស។ ឧ. ស្រុកនេះមានមនុស្សកុះករ។	៣
កើតទុក្ខ	កិ. មានទុក្ខ ពិបាកចិត្តឬកាយ។ ឧ. តាឌីកើតទុក្ខ ព្រោះចៅកើតដំបៅងា។	៣
កេណ្ឌ	កិ. ប្រមូលផ្តុំ ហៅរកប្រមែប្រមូលកងទ័ពដោយអាជ្ញា។ ឧ.សេនាមឿងកេណ្ឌពលខ្មោច។ ឧ. ស្តេចយក្សឆោឡោកេណ្ឌពលទៅរកបុត្រី។	៥; ៦
កែរ	ន. ដំណែល, សម្បាច់របស់ដូនតាឬមាតាបិតា។ ឧ. ប្រាសាទអស់នេះជាកែរដូនតាយើង។ ឧ. អំបានបន្សល់ទុកកែរបន្តិចបន្តួចឱ្យកូនគាត់។	២; ៣; ៥
កែរដំណែល	ន. អ្វីៗជារបស់រក្សាទុកមកពីដូនតាពីបុព្វបុរស។ ឧ. ស្រែនេះជាកែរដំណែលរបស់ជីតាខ្ញុំ, ប្រាសាទអង្គរវត្តជាកែរដំណែលរបស់ព្រះមហាក្សត្រខ្មែរ។	៤
កេរ្តិ៍	ន. សេចក្តីសរសើរ ការល្បី ការលេចឮខ្ចរខ្ចារ។ ឧ. ...អ្វីដែលក្រអូបនោះគឺកេរ្តិ៍ឈ្មោះដ៏ល្អប្រពៃ។	២;៣;៦

កេរមរតក	ន. ទ្រព្យដំណែលឬទ្រព្យដែលបន្សល់ទុកពីបុព្វបុរស។ ឧ. យើងត្រូវចេះលើកតម្កើងនិងថែរក្សាកេរមរតកនេះ។	៥
កៅស៊ូ	ន. ប្រភេទឈើជ័រស្អិតយឺត សម្រាប់ធ្វើសម្ភារៈបានច្រើនយ៉ាង។ ឧ. ស្រុកយើងត្រូវការរោងចក្រកែច្នៃជ័រកៅស៊ូ។	៣
ក្តីក្តាំ	ន. វិវាទធម្មតា គឺដំណើរទាស់ទែងគ្នា មានជម្លោះនឹងគ្នា។ ឧ. តាង៉ុយថា កើតក្តីក្តាំឡើងតុលាការអស់ខោអស់អាវ...។	៦
ក្តារងឿ	ន. ក្តារក្រាស់បន្ទះធំៗពីរឬបីសន្លឹកតម្រៀបភ្ជិតគ្នាលើជើងម៉ាទ្រ។ ឧ. ក្តារងឿពីរសន្លឹកនេះជាឈើបេង។	២
ក្បាលជង្គង់	ន. ប៉ែកកណ្តាលនៃជើងនៅត្រង់សន្លាក់ដែលភ្ជាប់ឆ្អឹងភ្លៅទៅឆ្អឹងកំភួនជើង។ ឧ. ក្រុមឈ្នះបានជោះក្បាលជង្គង់គេ។	៣
ក្បួន	ន. របស់ដែលចងជាដុំឱ្យអណ្តែតទឹក។ ឧ.ក្បួនឫស្សី។	៦
ក្បួនខ្នាត	ន. កំណត់ជាគោលសម្រាប់ធ្វើតាម បែបបទកំណត់អ្វីមួយ។ ឧ. យើងចាប់គូសតាមរាងអក្សរយឺតៗតាមក្បួនខ្នាត។	២
ក្មេងទំនើង	ន. ក្មេងដែលកំពុងពេញពាល មិនស្គាល់ខុសត្រូវ និងមិនស្តាប់បង្គាប់។ ឧ. ការមានក្មេងទំនើង ព្រោះកង្វះភាពកក់ក្តៅពីគ្រួសារ ពីសាលា និងភាពឆកល្វែងការអនុវត្តច្បាប់។	៣
ក្រញាង	គុ.កិ. ដែលមិនរៀបរយ។ ឧ. សក់បះក្រញាង។ ឧ. ពេលមកពីតម្រង់ជួរ ក្មេងខ្លះរត់ក្រញាងមកវិញ។	៣
ក្រហែងក្រហូង	ន. ក្រហូងតូច ធំ ខ្ពស់ និងទាប។ ឧ. ផ្លូវនេះមានក្រហែងក្រហូងច្រើនកន្លែង។	២
ក្រឌីឈូក	ន. ខ្នែងដែលបែកចេញពីមើមឈូក។ ឧ. ពូឱមដកក្រឌីឈូកនៅឯបឹង។	២
ក្រឹត្យក្រម	ន. លំដាប់នៃកិច្ច ក្បួនច្បាប់។ ឧ. អូ...លោកនាយកថ្មី ធ្វើតាមក្រឹត្យក្រមណាស់ណ៎ា។	៦
ក្រុមប្រឹក្សាកុមារ	ន. ក្រុមកុមារដែលសាលារៀបចំឱ្យជួយគ្រប់គ្រងនិងដឹកនាំកុមារ។ ឧ. ក្រុមប្រឹក្សាកុមារដើរមើលនិងដាស់តឿនកុមារដែលឆ្គងភ្លេចខ្លួន។	៣
ក្រុមសង្គ្រោះ	ន. ក្រុមមនុស្សមាននាទីជួយក្នុងគ្រាមានអាសន្ន។ ឧ. បន្ទាប់ពីទឹកជំនន់ ក្រុមសង្គ្រោះបានមកជួយដែរ។	៣

ក្រុមហ៊ុន	ន. ការដាក់ដើមទុនចូលគ្នាដើម្បីរកស៊ី។	៦
ក្រោក	កិ. ឡើងចាកដំណេក ឡើងចាកបង្គុយ។ ឧ. សុខានិងម្ចុនក្រោកពីព្រលឹម។	៣
ក្រោធ	កិ. ខឹង។ ឧ. ព្រះចៅសៀមក្រោធយ៉ាងខ្លាំង។ ឧ. កុំអាលក្រោធ ស្តាប់ខ្ញុំសិន។	៥
ក្លិន	ន. ចំហាយដែលផ្សាយចេញពីវត្ថុផ្សេងៗ ក្រអូប ឬស្អុយជាដើម។ ឧ. វាមានក្លិនក្រអូបគួរឱ្យចង់ហិត។	២
ក្តី	ន. មិត្តជិតស្និទ្ធដែលរួមសុខទុក្ខជាមួយគ្នា។ ឧ. សុខាជាក្តីរបស់តុលា។ ឧ. សត្វទាំងបីរាប់គ្នាជាក្តី។	៤
ក្លែង	កិ. បន្លំភ្នែក ធ្វើឱ្យប្លែកពីរូបដើមដើម្បីកុំឱ្យគេស្គាល់ឬដឹង។ ឧ. ទីទុយប្រាប់ស្មាន់ឱ្យក្លែងធ្វើជាបាក់ជើង។	៤
ក្សាន្ត	គុ. ដែលស្ងប់ស្ងាត់ចាកក្តីទុក្ខ។ ឧ. ចិត្តក្សាន្ត។	៦
ក្សិណ	ន. ពេល ស្របក់ រំពេច។ ឧ. ក្សិណនោះព្រះយមពន្រាយលើសលែងសព្វសាយ ស្តេចបើកព្រះនេត្រយល់ជាក់ ...។[1]	១
ក្សេម	គុ. សុខសប្បាយ។ ឧ. ចិត្តក្សេមចិត្តក្សាន្ត ជាចិត្តស្ងប់អស់អំពល់។	១
ក្សេមក្សាន្ត	គុ. ដែលមានសេចក្តីសុខសាន្ត។ ឧ. ទីនោះ ពួកគេរស់នៅបានសុខក្សេមក្សាន្ត។ ឧ. ចិត្តក្សេមក្សាន្តជាមង្គលដ៏ឧត្តម។	៣; ៤; ៦
ក្សីយ[2]	ន. សេចក្តីស្លាប់ វិនាស, ការបាត់បង់។ កិ. ស្លាប់ បាត់បង់ វិនាសអស់។ ឧ. ឯងជិះលឿនពេក ប្រយ័ត្នក្សីយជីវិតមុនគេទៅ។	២, ៤
កំព្រា	គុ. ដែលឥតម្តាយឥតឪពុក។ ឧ. មេមាន់ឃើញកូនទាកំព្រាក៏យកមកចិញ្ចឹម។	៣
ខ	**ខ**	
ខន្ធ	ន. កង ប្រជុំ ពួក គំនរ ដើម។ ឧ. ខន្ធ៥ គឺមានរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ។	៦

[1] *(សាស្ត្រាពាក្យកាព្យ សុបិនកុមារ)*

[2] ដែលប្រើសព្វថ្ងៃនេះ មានទំនងដូចជាកិរិយាសព្ទជាង។

ខម	កិ. បើកភ្នែក បើកមាត់ លៀនអណ្តាត សម្តែងអាការៈគួរឱ្យខ្លាច។ ឧ. ក្មេងហ្នឹងខិលណាស់ វាហ៊ានខមដាក់ខ្ញុំ។ ន. ឈ្មោះហៅខ្មែរក្នុងសម័យបុរាណព្រេងនាយ។ ន. ឈ្មោះអក្សរខ្មែរមួយបែប គឺអក្សរធំកាច់ជ្រុង(អក្សរខម)។	១
ខេមរា	ន. ខ្មែរ។ ឧ. យើងបុត្រខេមរាត្រូវគោរពទង់ជាតិ។	៣
ខ្ជាប់ខ្ជួន	គុ.កិ. ខ្ជាប់ណាស់ មាំមួនណាស់ ប្រយ័ត្នមិនធ្វេសប្រហែស។ ឧ. សុធាគោរពវិន័យសាលាយ៉ាងខ្ជាប់ខ្ជួន។	២; ៣
ខ្ជីខ្ជា	គុ.កិ. ធ្វើការឬនិយាយមិនម៉ត់ចត់។ ឧ. សុខាលែងធ្វើការខ្ជីខ្ជា។	២
ខ្ជីខ្ជា	គុ.កិ. ធ្វើការឬនិយាយមិនហ្មត់ចត់។ ឧ. យើងស្រោចទឹកមិនដែលខ្ជីខ្ជា។	២
ខ្ចាល់	កិ. ខឹង។ ឧ. ស្តេចខ្ចាល់, លោកសង្ឃខ្ចាល់។	៤
ខ្ទុង	ន. ឈ្មោះសត្វល្អិតមួយប្រភេទស្រដៀងនឹងកំពោង ឬកញ្ជ្រោ។	១
ខ្ទៀវខ្ទារ	គុ.កិ. ដែលទ្រហឹងអឺងកង ដោយសូរសម្រែកនៃសត្វបក្សី។ ឧ. សារិកាកែវស្រែកខ្ទៀវខ្ទារ។ ឧ. គេនាំគ្នាលេងល្បែងប្រជាប្រិយយ៉ាងខ្ទៀវខ្ទារ។	២
ខ្ទុំស្រី	ន. អ្នកបម្រើស្រី។ ឧ. កាលនុះ លោកម្ចាស់បានប្រើខ្ទុំស្រីឱ្យទៅ។	៦
ខ្នើត	ន. លំដាប់ពន្លឺព្រះចន្ទដែលកើតពីថ្ងៃ១កើតដល់១៥កើតពេញបូណ៌មី។ ឧ. ក្នុងរដូវខ្នើតខែបុស្សឆ្នាំនេះ ត្រីប្រហុកសម្បូរជាងឆ្នាំកន្លងទៅ។	៦
ខ្មីឃ្មាត	កិ. ខំប្រឹង សង្វាតខ្លាំង។ ឧ. កុមារាកុមារីខ្មីឃ្មាតរៀនសូត្រ។	៣
ខ្មែរ	ន. ជនជាតិខ្មែរ មនុស្សដែលមានជាតិពន្ធុខ្មែរ។ ឧ. គាត់ជាខ្មែរតែសញ្ជាតិបារាំង។	៣
ខ័ន	ន. ពួកសស្ត្រាខ្លីស្រដៀងនឹងដាវដែលផ្លៃមានមុខទាំងពីរតែធំវែងជាងលំពែង...។ ឧ. ព្រះខ័នមានន័យថាដាវទេព។	៣
គ	**គ**	
គឃៀរ	គុ.កិ. ដែលបែកញើសហៀរហូរសស្រាក់។	២

គង្គា	ន. ទឹក, ឈ្មោះទន្លេធំ១នៅក្នុងប្រទេសឥណ្ឌា។ ឧ. យើងជិះទូកលេងតាមគង្គា។ ឧ. ទន្លេគង្គាមានប្រវែងប្រហែល ២,៥១០គីឡូម៉ែត្រ។	៣, ៦
គង់វង្ស	គុ.កិ. គង់ពូជវង្សនៅមិនសូន្យ គង់ដំណែលប្រពៃណីដូចដើម។ ឧ. យើងត្រូវរក្សាប្រពៃណីឱ្យនៅគង់វង្ស។ ឧ. យើងរក្សាល្បែងប្រជាប្រិយល្អឱ្យគង់វង្ស។	៣; ៤; ៥
គជសារ	ន. ដំរីមាឌធំសម្បើម។	៤
គណៈកម្មការ	ន. ក្រុមជំនុំដែលចាត់តាំងឡើងដោយការបោះឆ្នោតឬជ្រើសតាំង ឱ្យពិនិត្យកិច្ចការណាមួយដាច់ដោយឡែក។ ឧ. គណៈកម្មការបានសាកល្បងម្ហូបក់ម្តងៗ។	៥
គណៈកម្មាធិការ	ន. សមាជិកក្រុមដែលតាំងឡើងដោយរាជការ។ ឧ. គាត់ទៅជួបគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។	៥
គណៈប្រតិភូ	ន. ជនមួយក្រុមដែលចាត់ជាតំណាងប្រទេស ក្រសួង ឬតំណាងក្រុមណាមួយ ដើម្បីបំពេញកិច្ចការផ្សេងៗ។ ឧ. សម្តេចបាននាំគណៈប្រតិភូទៅធ្វើទស្សនកិច្ចនៅកម្ពុជាក្រោម។	៥
គមនាគមន៍	ន. ដំណើរទៅនិងមក ផ្លូវទាក់ទងសម្រាប់ដំណើរទៅមក។ ឧ. បច្ចេកវិទ្យាគមនាគមន៍ ជាឧបករណ៍ដែលមនុស្សប្រើដើម្បីបង្កើត បញ្ជូន រក្សាទុក និងចែករំលែកព័ត៌មាន។	៣
គម្ពីរ	ន. សាស្ត្រា ច្បាប់ ធម្មវិន័យ ឬក្បួនដែលរួបរួមដោយពួក ប៉ែក ឬខ្សែ។ ឧ. លោកបាននិពន្ធសៀវភៅធម៌នានា ប្រៃគម្ពីរព្រះត្រៃបិដក កសាងវត្ត។ល។	៥; ៦
គិរី	ន. ភ្នំ។ ឧ. មណ្ឌលគិរីសម្បូរព្រៃព្រឹក្សា ភ្នំតូចធំ និងទឹកជ្រោះ។	១
គុណ	ន. សេចក្តីចម្រើន សេចក្តីល្អ អំពើល្អគួរគោរពតបស្នង។ ឧ. ពួកគាត់ជាអ្នកមានគុណ។ ឧ. ឪពុកម្តាយជាអ្នកមានគុណដ៏លើសលប់។	៤; ៦
គុណធម៌	ន. សេចក្តីល្អ សេចក្តីបរិសុទ្ធ សេចក្តីអាណិតអាសូរ។	៦
គុណភាព	ន. ភាពល្អ ភាពប្រសើរ របស់ដែលមានអានុភាពសក្តិសិទ្ធិ។ ឧ. សំពត់សូត្ររបស់ខ្មែរយើងមានគុណភាពល្អគ្មានពីរ។	៥, ៦
គុណវិបត្តិ	ន. ការប្រាសចាកគុណ ខ្វះសេចក្តីល្អ គ្មានផលប្រយោជន៍។	៤

គុណសម្បត្តិ	ន. ការបរិបូណ៌ដោយសេចក្តីល្អ សេចក្តីបរិសុទ្ធ។ ឧ. មនុស្សមានគុណសម្បត្តិគួរឱ្យសរសើរ។	៤, ៦
គុម្ព	ន. ពួក ប្រជុំដើមឈើ ឬដំណាំផ្សេងៗ។	៦
គូសវាស	កិ. ធ្វើឱ្យមានជួរស្មាម-គំនូសឥតសណ្តាប់ធ្នាប់។ ឧ. ខ្ញុំឃើញស្នាមរហែកនិងគូសវាសផ្តេសផ្តាស។	៣
គួរឱ្យស្រឡាញ់	គុ. ដែលសមនឹងស្រឡាញ់គ្មានទាស់។ ឧ. ដាវីមានចរិតគួរឱ្យស្រឡាញ់។	៣
គេហដ្ឋាន	ន. ផ្ទះ ទីផ្ទះដែលរស់នៅ។ ឧ. ទីបំផុត គេដាក់ត្រីលើទូកនាំបងប្អូនត្រឡប់មកគេហដ្ឋានវិញ។	៦
គែន	ន. ឧបករណ៍ភ្លេងសម្រាប់ផ្គុំរបស់ជនជាតិដើមភាគតិច។	១
គោម[1]	ន. ឈ្មោះចានម្យ៉ាងរាងក្រឡម ធំជាងចានសម្ល។	២
គោម[2]	ន. ប្រទីបមានឡូត មានប្រឆេះ មានលំផូង មានច្រើនបែបច្រើនយ៉ាង មានសណ្ឋានផ្សេងគ្នា សម្រាប់ប្រើកាន់លើកដាក់បាន។ ឧ. គោមពណ៌ដុតបំភ្លឺពេលចូលឆ្នាំ។	២
គោរព	កិ. កោតខ្លាច ឱនលំទោន ប្រតិបត្តិតាមសេចក្តីកោតក្រែងដឹងគុណ។ ឧ. យើងទៅគោរពទង់ជាតិ។ ឧ. សិស្សត្រូវគោរពគ្រូ។	២,៣,៦
គោលដំហ	ន. ឥរិយាបថ ចិត្តគំនិត ការប្រកាន់យកគំនិតណាមួយ។ ឧ. បឋមវ័យជាវ័យផុយស្រួយ បើយើងពុំមានគោលជំហររឹមាំ។	៥
គោឧសភរាជ	ន. គោដែលគេយក មកប្រារព្ធពីធីបុណ្យច្រត់ព្រះនង្គ័ល។	៥
គ្មាន	កិ. ពាក្យបដិសេធប្រាប់សេចក្តីថាមិនមាន ឥត។ ឧ. បើយើងគ្មានអីសរសេរ យើងអាចប្រាប់គ្រូបាន។	៣
គ្រងរាជ្យ	កិ. សោយរាជ្យ។ ឧ. ជ័យអស្ចារ្យឡើងគ្រងរាជ្យបន្តពីព្រះបិតា។	៥
គ្រូបាអាចារ្យ	ន. គ្រូឧបជ្ឈាយ៍ គឺគ្រូបង្រៀនធម៌ឬគ្រូច្បាប់។	៦
គ្រួសារ	ន. ក្រុមមនុស្សដែលមានចំណងទាក់ទងដោយសារកំណើត អាពាហ៍ពិពាហ៍ ...។ ឧ. ប៉ាម៉ាក់ជាបង្គោលគ្រួសារ។ ន. ប្តីឬប្រពន្ធ។ ឧ. ខ្ញុំមានគ្រួសារហើយ។	៣
គ្រឿងញៀន	ន. រុក្ខជាតិឬសារធាតុញៀនដែលច្បាប់កំណត់។ ឧ. យើងត្រូវចៀសឱ្យឆ្ងាយពីគ្រឿងញៀន។	៣

គ្រឿងទេស	ន. គ្រឿងផ្សំបន្ថែមសម្រាប់ធ្វើឱ្យសម្លមានរសជាតិនិងក្លិន។ ឧ. ម៉ាក់ទៅទិញគ្រឿងទេសទុកស្លនិងធ្វើម្ហូបផ្សេងៗ។	៣
គ្រឿងស្រវឹង	ន. សុរាឬសារធាតុរាវផ្សេងៗដែលធ្វើឱ្យស្រវឹងបាន។ ឧ. គ្រឿងស្រវឹងមានឥទ្ធិពលឱ្យមនុស្សស្រវឹង សម្តីតឹងអួតក្អេងក្អាង ជំពាក់គេ និងវង្វេងស្មារតីនាំដល់គ្រោះថ្នាក់ចរាចរណ៍។	៣
គ្រឿងឧបភោគ	ន. គ្រឿងសម្រាប់ប្រើប្រាស់ជិតខ្លួន។ ឧ. មន្ត្រីកាំកុងត្រូលបានចុះត្រួតពិនិត្យគ្រឿងឧបភោគបរិភោគនៅក្នុងផ្សារគគីរ។	៥
គ្រោះថ្នាក់	ន. គ្រោះកាច រឿងអាក្រក់ដែលកើតឡើងភ្លាមៗដោយចៃដន្យ។ ឧ. ដើម្បីចៀសវាងគ្រោះថ្នាក់ យើងត្រូវប្រុងប្រយ័ត្ននិងដឹងពីរបៀបធ្វើឬប្រើប្រាស់។ ឧ. មេមាន់ខ្លាចកូនមានគ្រោះថ្នាក់។	២; ៣
គ្រោះមហន្តរាយ	ន. គ្រោះថ្នាក់ធំ។ ឧ. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវសហការជាមួយក្រសួង... ដើម្បីបំពេញការងារនេះ។ ឧ. ...ប្រទេសយើងក៏នឹងធ្លាក់ក្នុងគ្រោះមហន្តរាយ។	៥; ៦
គំនាប	ន. ប្រដាប់សម្រាប់គាប ឃ្នាប។	៤
គំនូរ	ន. រូបភាព ក្បាច់រចនា ក្បួរក្បាច់រំលេច... ដែលកើតមានឡើងដោយការ គូរ។ ឧ. នេះជាគំនូររឿងទន្សាយចង់ស៊ីចេក។	១
ឃ	**ឃ**	
ឃាតក:	ន. អ្នកសម្លាប់ អ្នកធ្វើឃាត។ ឧ. លោកត្រូវទទួលមរណភាពដោយសារដៃឃាតក:បារាំង។	៤; ៥
ឃោរឃៅ	គុ. ពន្លឹកគួរឱ្យខ្លាច កាចខ្លាំងឥតមានមេត្តាប្រណី។ ឧ. ចិត្តឃោរឃៅ, ចោរឃោរឃៅ។	១; ២
ឃ្លើស	គុ. ដែលទើស ទាក់ ទាស់។	១
ឃ្មាតខ្មី	កិ. ខំប្រឹង សង្វាតខ្លាំង។ ឧ. ពុកឃ្មាតខ្មីធ្វើការ ឯកូនឃ្មាតខ្មីសិក្សាយកចំណេះវិជ្ជា។	៣
ឃ្មឹក	គុ.កិ. ពាក្យសម្រាប់ចម្រើនពាក្យក្រាស់អោយវិសេសវិសាស។ ឧ. ភ្នំនេះដូចផុសចេញពីព្រៃព្រឹក្សាដ៏ក្រាស់ឃ្មឹក។	៤
ឃ្វាល	កិ. ចាំ រក្សាសត្វចិញ្ចឹម។ ឧ. ស្នានិងស្នាយតែងទៅឃ្វាលគោនៅឯវាល។	២

ង	**ង**	
ងងឹត	គុ. ទីទៃពីភ្លឺ ដែលឥតមានពន្លឺ។ ឧ. យប់ងងឹត ខែងងឹត ងងឹតភ្នែក។	២
ងារ	ន. មុខការ ទីតំណែងរាជការ តាមបណ្តាស័ក្តិឋានន្តរ។ ឧ. ស្តេចសៀមប្រទានងារឱ្យឧទេនជាអ្នកត្រួតត្រាភ្នាក់ងារខាងដំរី។	៥
ងឿ	ន. ក្តារក្រាស់បន្ទះធំៗពីរ ឬបីសន្លឹកតម្រៀបភ្ជិតគ្នាលើជើងម៉ាទ្រ។ ឧ. ក្តារងឿ។	១
ច	**ច**	
ចង្កូម	ន. ធ្មេញដែលដុះត្រង់ផុតជិតថ្គាម ស្រួចជាងគេ។ ឧ. ចម្រើនមានធ្មេញស្រួច ចង្កូមវិញវែងហើយមុត។	៣
ចង្រៃ	ន. ឧបទ្រព ដែលបណ្តាលឱ្យមានទុក្ខ មានកង្វល់។	២
ចង្ហាន់	ន. អាហារសម្រាប់ព្រះសង្ឃ។ ឧ. មនុស្សម្នាក្មេងចាស់ប្រុសស្រីយកចង្ហាន់ទៅវត្ត។	២; ៦
ចន្ទ្រា	ន. លោកខែ ព្រះចន្ទ។	២
ចម្ការ	ន. ទីដែលគេឆ្ការសម្រាប់ដាំដំណាំ។ ឧ.ពុកធ្វើការភ្ជួរចម្ការស្រែ។	៣
ចម្បង	គុ. ដែលលើសគេ ដែលច្បងគេទាំងពួងក្នុងបែប១ឬពួក១។ ឧ. សុវត្ថិភាពជាចម្បង។	៣
ចម្រាញ់	កិ. រំងាស់ សំរេងឱ្យដាច់ទឹក។ ឧ. ចម្រាញ់យកប្រេង។	៦
ចម្រើន	កិ. ធ្វើឱ្យច្រើន ឱ្យកើនឡើង។ ឧ. ខ្ញុំចង់ចម្រើនប្រាក់សន្សំ។ ន. ឆ្នាំនេះឈ្មោះចម្រើន ព្រោះវាមានប្រយោជន៍ច្រើន។	៣
ចម្រៀង	ន. ឈើ ឫស្សី ឬដែក ដែលស្តេចបោះនៅដី។ ឧ. ចម្រៀងបទនគររាជត្រូវបាននិពន្ធដោយសម្តេចសង្ឃរាជ ជួនណាត។	៥
ចម្លាក់	ន. រូបឬក្បាច់ដែលគេឆ្លាក់។ ឧ. ចម្លាក់ថ្មកែវមានការលំបាកជាងចម្លាក់ឈើ។	៥
ចម្អិន	កិ. ធ្វើឱ្យឆ្អិនដោយអំណាចចំហាយភ្លើ។ ឧ. កូនចេះចម្អិនស៊ុតចៀនហើយ។	៣
ចរចា	កិ. និយាយប្រស្រ័យ សំណេះសំណាលរកគ្នា។ ឧ. គាត់កំពុងចរចាគ្នា។	៤

ចរាចរណ៍	ន. ការធ្វើដំណើរទៅមក ដំណើរខ្វាត់ខ្វែងចុះឡើង។ ឧ. គាត់មកមិនទាន់ដល់ទេ នៅស្ទះចរាចរណ៍។ ឧ. នៅតាមដងផ្លូវ មនុស្សម្នាធ្វើចរាចរណ៍យ៉ាងមមាញឹក។	២;៣;៦
ចរិត	ន. ការប្រព្រឹត្តិ កិរិយា មារយាទ ឫកពា បែបបទ។ ឧ. កូនចង់បានចរិតល្អ ត្រូវហាត់ធ្វើតាមគ្រូណែនាំ។	៤; ៦
ចរិយា	ន. មារយាទ ឫកពា ការប្រព្រឹត្ត សំណាង។ ឧ. ក្មេងនេះមានចរិយាល្អ ចេះគោរពចាស់ ទុកដាក់សម្ភារៈ។ ឧ. ពុកម៉ែសប្បាយចិត្ត ព្រោះកូនមានចរិយាប្រពៃ។	៣; ៥; ៦
ចរិយាសម្បត្តិ	ន. ការបរិបូណ៌ដោយការប្រព្រឹត្តិល្អ។ ឧ. មនុស្សត្រូវមានរូបសម្បត្តិ ចរិយាសម្បត្តិ និងចំណេះវិជ្ជាទើបប្រពៃ។	២; ៤; ៥
ចរិយាសម្បទា	ន. ផ្លូវឬគន្លងនៃឥរិយា គឺការដើរ ឈរ អង្គុយដេក។	៤
ចលនា	ន. ការមិនតាំងនៅស្ងៀម ដំណើរវើរវាយជានិច្ច។	៦
ចល័ត	គុ. ដែលមិនឋិតនៅនឹងតែមួយកន្លែង។	៤
ចាក់ស្តុក	កិ. លោតក្រមាច់ក្រមើម។	២
ចាប់អារម្មណ៍	កិ. ចាប់ចិត្ត ជាប់ចិត្ត ជាប់គំនិត។ ឧ. ពេលខ្លះ អ្នកស្ដាប់ចាប់អារម្មណ៍ មានការគិតវែងឆ្ងាយ។	៣
ចារ	កិ. ធ្វើរបងទាបដោយដោតចម្រឹងឱ្យជាចារឹក។ ឧ.តាចារចំណារ។ កិ. សរសេរ(ដោយដែកចារ)។ ឧ. គាត់ចារសាស្ត្រាបុរាណ។ ន. ឈ្មោះឈើម្យ៉ាងមានផ្កាសម្បុរក្រហម ក្លិនឆ្ងាប។ ឧ. ដើមចារ ផ្កាចារ។	១; ៥
ចារឹក	កិ. សរសេរ កត់។ ឧ. ស្លាកថ្មចារឹកថា៖ "សូមឱ្យទឹកជ្រោះនេះបានជាតួយ៉ាងដល់មនុស្សគ្រប់គ្នា"។	៤
ចិញ្ចាច	គុ.កិ. ពេញពន្លឺឆ្នុះផ្សាយ។ ឧ. នៅរាត្រី មានភ្លើងចម្រុះពណ៌ភ្លឺចិញ្ចាច។	២
ចិញ្ចឹម	កិ. គ្រប់គ្រងរក្សាបន្តជីវិត បីបាច់រក្សាឱ្យរស់ធាត់ធំ។ ឧ. ពុកម៉ែរែកពុនចិញ្ចឹមគ្រួសារ។	៣
ចិត្ត	ន. ១.ធម្មជាតិ[3]សម្រាប់សន្សំអារម្មណ៍ សម្រាប់គិត គឺវិញ្ញាណ។ ឧ. ចិត្តត្រង់ ចិត្តវៀច ចិត្តល្អ ចិត្តអាក្រក់។ល។	

[3] តាមវេយ្យាករណ៍() "ធម្មជាត" គឺត្រឹមត្រូវ, តែយើងធ្លាប់ប្រើ "ធម្មជាតិ" ជាទូទៅទៅហើយ។

		២.សមត្ថភាពគិត យល់ដឹង ពិចារណា វិនិច្ឆ័យ និងសម្រេចចិត្តរបស់មនុស្ស, ក៏ជាមជ្ឈមណ្ឌលនៃញាណដែលបង្កើតការគិត អារម្មណ៍ គំនិត ប្រត្យក្សារម្មណ៍ និងជាកន្លែងផ្ទុកពុទ្ធិនិងការចងចាំ។ ឧ. ចិត្តជាប្រធាននៃកាយនិងវាចា។ ឧ. ចិត្តជាអ្នកបញ្ជា រីឯកាយនិងវាចាជាអ្នកអនុវត្ត, ដូច្នេះដើម្បីកុំឱ្យខូចចិត្ត ចិត្តសៅហ្មង ចិត្តអាក្រក់ យើងដែលជាម្ចាស់ចិត្តត្រូវតែរៀនទូន្មានចិត្ត សង្កៀមចិត្ត ... ទើបជីវិតបានសុខជាងទុក្ខ។ ៣.កិ. អត់ធ្មត់ ពូកែទ្រាំ ស៊ូទ្រាំ។ ឧ. កីឡាករប្រដាល់នេះចិត្តណាស់ គេវាយបែកមុខហើយនៅមិនព្រមចុះចាញ់។ ៤.ឆាប់ប្រកាន់ ឆាប់ងរង៉ក់ ឆេវឆាវ។ ឧ. កូននេះចិត្តណាស់ ម្តាយបន្ទោសបន្តិចបន្តួច លែងស៊ីបាយ។	
ចិន្តា	ន.	សេចក្តីគិត គំនិត។ ឧ. ព្រះអង្គសិទ្ធត្ថទ្រង់ព្រះចិន្តាថា បើសិនអាត្មាអញទទួលដំណែង... អាត្មាអញក៏ត្រូវតែធ្វើដូចជាព្រះអង្គដែរ។	៤
ចីវរ	ន.	គ្រឿងស្លៀកដណ្តប់សម្រាប់អ្នកបួសក្នុងពុទ្ធសាសនា។ ឧ. មានចីវរនៅខាងមុខរៀងៗខ្លួន។	៦
ចឹក	កិ.	ខាំដោយចំពុះ។ ឧ. ក្រសារមួយឈរចាំចឹកត្រីនៅមាត់បឹង។	២
ចេចចាច	ន.	សូរភាសាបក្សី មានគ្រលេងគ្រលោងជាដើម។ ឧ. មានតែសំឡេងសត្វចេចចាចនិងដើមឈើខ្ពស់ស្រឡឹមឈរជុំវិញប្រាសាទនោះ។	២
ចេញដំណើរ	កិ.	ធ្វើដំណើរទៅ ចាកចេញទៅ។ ឧ. ក្មួយចេញដំណើរពីរង្វង់មូលស្តន់។	៣
ចេតិយ	ន.	ទីដែលគេគោរពបូជា ទីសម្រាប់តម្កល់សារីរិកធាតុ។	២
ចេះគួរសម	គុ.	សុភាពរៀបរយត្រូវបែបបទ, មានការគោរពនិងអាកប្បកិរិយាល្អ។ ឧ. ម៉ានីជាក្មេងល្អនិងចេះគួរសម។	២
ចែកឋាន	កិ.	ស្លាប់ ទទួលមរណភាព។ ឧ. ឧទ្ទិសកុសលចំពោះញាតិកាទាំងប្រាំពីរសន្តានដែលបានចែកឋានទៅ។	២

ចែដន្យ	គុ.កិ. គាប់ចួន ដំណើរកើតឡើងដោយឥតព្រាងទុក។ ឧ. ចែដន្យរំពេចនោះ ភ្លើងស្តុបបានដាច់។	៣
ចោរកម្ម	ន. អំពើរបស់ចោរ អំពើលួចប្លន់។ ឧ. ពេលខ្លះ ចោរកម្មកើតអំពីការមិនអើពើពីសង្គម សេដ្ឋកិច្ចធ្លាក់ចុះ ល្បែង និងគ្រឿងញៀនជាដើម។	៣
ចោលឈូង	កិ. បោះគ្រវែងឈូងសំដៅឱ្យគេតាមចាប់។ ឧ. ឯងចាំចាប់ពេលខ្ញុំចោលឈូងទៅ។	៣
ចោលម្សៀត	ន. ឥតបានការ ប្រើការមិនកើត។ ឧ. ចោលម្សៀត! ចេះមកពោលពាក្យថាកាន់ព្រះរាជអាជ្ញា...។	៤
ចៅហ្វាយ	ន. អ្នកដែលជាម្ចាស់ឬនាយកលើគេ។ ឧ. ចៅហ្វាយប្រើអ្នកបម្រើ។	២; ៣
ច្បង	គុ. ដែលជាបងបង្អស់។ ឧ. កូនស្រីច្បងឈ្មោះនាត។	៦
ច្បាប់	ន. សេចក្តីបញ្ញត្តិ វិន័យ ក្រិត្យក្រម ក្បួនប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។	១
ច្បាប់ក្រម	ន. ឈ្មោះសាស្ត្រាសុភាសិតសម្រាយកាព្យ។	១
ច្បារ	ន. សួនដំណាំ ទីដីដែលដាំបន្លែ។ ឧ. ល្ងាចម៉ោង៥ ប៉ាតែងចូលស្រោចទឹកក្នុងច្បារ។	២
ច្យុត	កិ. ឃ្លាត របូត ស្លាប់(ច្រើននិយាយជាមួយទេវតាអស់ជីវិត)។	១
ច្រឡាស	កិ. ខុសរបៀប ខុសពីផ្លូវពីគន្លង ច្រឡោតទៅខាង។ ឧ. កូនកុំច្រឡាសលើរៀមច្បង។	៤
ច្រែះ	ន. ស្នឹមលោហជាតិមានដែកជាដើម។	២
ចំណាប់អារម្មណ៍	ន. ការចាប់អារម្មណ៍ ការចាប់ចិត្តទៅលើអ្វីមួយ។ ឧ. សេចក្តីបញ្ចប់នៃតែងសេចក្តីការពណ៌នាមានពីរ គឺការវាយតម្លៃនិងចំណាប់អារម្មណ៍។ ឧ. ខ្ញុំពុំសូវមានចំណាប់អារម្មណ៍លើរឿងនេះទេ។	៣
ចំណី	ន. វត្ថុសម្រាប់ឆី។	៣
ចំណេះ	ន. សេចក្តីចេះ ដំណើរដែលចេះ។	១
ឆ	**ឆ**	

ឆត្រ	ន. ប្រដាប់មានដងឆ្អឹង គន្លឹះ ពាសសំពត់ សម្រាប់បើកកាន់ជាំងកម្តៅថ្ងៃជាំងភ្លៀង។	២
ឆស័ក	ន. ស័កទី៦ក្នុងចំនួនស័កដប់ឆ្នាំ។ ឧ. សម្តេចសង្ឃជួនណាត ប្រសូត្រនៅថ្ងៃ១១រោច ខែផល្គុនឆ្នាំវក ឆស័ក ព.ស. ២៤២៧។	៥
ឆី	កិ. ស៊ី។ ឧ. ឆ្កែជាឱ្យបាយឆី ដេកនៅដីចាំធនធាន។	៤
ឆែឃ្មាំ	ន. ឈ្មោះភ្លេងមួយបែបគេច្រើនលេងកម្សាន្តក្នុងពិធីបុណ្យកឋិនឬបុណ្យផ្កា។	២
ឆ្ការ	កិ. ត្រាយត្រួសរុក្ខជាតិតូចធំហើយរម្លើងគល់ឬគុម្ពឱ្យស្អាតទុកដាំដំណាំជាដើម។	
ឆ្កួត	គុ. ឡប់សតិ។	៥
ឆ្នេរ	ន. ចំណែកដីខ្សាច់ដែលនៅជាប់មាត់សមុទ្រឬទន្លេ។ ឧ. ឆ្នេរអូរឈើទាលជាទឹកដីដ៏ស្រស់បំព្រង។	៣
ឆ្នាំឆ្គង	គុ. មិនសមរម្យ មោះមែបន្តិចបន្តួច។	២
ឆ្មាបា	ន. សត្វព្រៃមានស្បែកជាស្លាបមួយប្រភេទ សម្រែកស្រដៀងនឹងឆ្មា។ ឧ. ឆ្មាបាពោបឡើងដើមត្នោត។	១
ឆ្នូល	កិ. ១.ប្រមូលឱ្យមូលជាដុំ៖ ឧ. ឆ្នូលសំពត់ ឆ្នូលកន្សែង។ ២.រមូលប្រមូលឱ្យចុកសៀត៖ ឧ. ឆ្នូលពោះ។	
ឆ្លៀតពេល	កិ. រំលែកពេលឬរកឱកាសល្អដើម្បីនឹងធ្វើអ្វីមួយ។ ឧ. នាងឆ្លៀតពេលទៅជួយម្តាយលក់ដូរ។	៣
ដ	**ដ**	
ដង្កែក	ន. កន្លែងដាក់ស្រូវ ក្រង់ស្រូវ។	២
ដម	កិ. ធ្វើឱ្យមានរាងជ្រុលម ព្រួមឱ្យមានរាងដូចត្រយូងចេក។ ឧ. យកស្លឹកត្នោតមកជមជាកន្ទោង។	១
ដម្រែក	ន. ទីកន្លែងសម្រាប់ជ្រក កន្លែងស្នាក់នៅ។ ឧ. ពុទ្ធសាសនាជាយាន ជាស្ពាន និងជាដម្រែកនៃសិរីសួស្តី។	៤; ៦

ដម្រាបប្រសាសន៍	កិ! (ពាក្យគំនាប់នៅពេលតបសម្តី)សូមឱ្យនរណាម្នាក់ជ្រាប, តបទៅប្រសាសន៍នរណាម្នាក់។ ឧ. ជម្រាបប្រសាសន៍អ្នកគ្រូ! ការងារនេះខ្ញុំចូលចិត្តណាស់។	៦
ដម្រើស	ន. អ្វីៗឬវត្ថុអ្វីដែលបានរើសរួចហើយ។ ឧ. មុខរបរដាំដំឡូងមីត្រូវការរោងចក្រច្រើន។	៣
ដយតុ!	ន. ពាក្យសម្រាប់ឱ្យពរជ័យថា សូមឱ្យមានជ័យជម្នះ! ឧ. ព្រះសង្ឃបានទូងស្គរនិងសូត្រជយតុក្នុងឱកាសនោះ។	៥
ដរា	គុ. ដែលគ្រាំគ្រា ដែលទ្រុឌទ្រោម ចាស់។ ឧ. ពេលកូនឃើញចាស់ជរា កូនត្រូវចេះគួរសមរាក់ទាក់។ ឧ. ពួកគាត់មានវ័យជរាណាស់ហើយ។	២; ៣
ដា	កិ. គឺជា ពាក្យនិយាយចង្អុលនាមសព្ទឱ្យដាច់សេចក្តីដោយឡែក។ ឧ. នេះប្រហែលជាប្រផ្នូលរាំងស្ទះហើយ។	
ជាតិសាសន៍	ន. ១.កំណើតមនុស្ស។ ឧ. ខ្មែរជាជាតិសាសន៍មួយដែលមានវប្បធម៌ អរិយធម៌រុងរឿងតាំពីសម័យបុរាណ។ ២.ជាតិនិងសាសនា។ ឧ. ខ្មែ សៀម លាវ មន ភូមា ... មានជាតិផ្សេងគ្នាប៉ុន្តែសាសន៍ត្រូវគ្នា ព្រោះជាពុទ្ធសាសន៍ដូចគ្នា, ពុំគួរមានសង្គ្រាមនឹងគ្នាឡើយ។	៥
ជានិច្ច	គុ.កិ. គ្រប់កាល គ្រប់ពេល ឥតឈប់។ ឧ. សុខាមករៀនទាន់ពេលជានិច្ច។	២; ៣
ជីវភាព	ន. ភាពនៃការរស់នៅ ការចិញ្ចឹមជីវិត។ ឧ. អក្សរសិល្ប៍ប្រជាប្រិយច្រើនទាក់ទងនឹងជីវភាពប្រជាជនដែរ។ ឧ. ដើម្បីមានជីវភាពធូរធារ យើងត្រូវមានចំណូលពីរ។[4]	៣; ៥
ដួ	គុ. ដែលអាក្រក់ ដែលឆ្គងមិនសូវស្គាល់ក្តីគួរសម។ ឧ. មនុស្សដួ, អាក្រក់ដួជាតិ។	៤
ដួត	កិ. រុំក្បាលដោយឈ្នួត។	១
ជោគ	ន. សេចក្តីសុខស្រួល សេចក្តីសមប្រកបកើតការ។ ឧ. ថ្ងៃមានជោគ, មនុស្សមានជោគ។	៣

[4] ចំណូលប្រចាំថ្ងៃនិងចំណូលប្រចាំខែ ឬចំណូលសកម្មនិងចំណូលអសកម្ម។

ជោគជ័យ	ន. សេចក្តីសមប្រកបដោយជ័យ។ ឧ.កូនបានជោគជ័យហើយ។	៣
ជោរ	កិ. ពោរឡើង។ ឧ. ពេលនោះ ទឹកសមុទ្រកំពុងទឹកជោរ។	២
ជ្វាលា	ន. អណ្តាតភ្លើង សេចក្តីរុងរឿង ពន្លឺដែលភ្លឺព្រោងព្រាត។	១
ជំងឺ	ន. សេចក្តីឈឺចាប់ ភាវៈឈឺ អាពាធ រោគ។ ឧ. ការហាត់ប្រាណអាចទប់ស្កាត់ជំងឺបានច្រើន។	៣
ជំនាញ	គុ. ដែលចេះស្ទាត់ប្រាកដ។	១
ជំនោរ	ន. ទឹកដែលជោរ ឈ្មោះនាំទឹកឱ្យជោរ។	២
ជ័យ	ន ជម្នះ ការឈ្នះ។ ឧ. សូមឱ្យកូនបានសុខបានជ័យ។	៣
ជ័យជម្នះ	ន. ជោគជ័យ, ការឈ្នះក្នុងការប្រយុទ្ធឬប្រឡងប្រជែងណាមួយ។ ឧ. ការរត់ប្រណាំងលើកទីពីរ តុលាទទួលបានជ័យជំនះ។	៤
ជ័រលុប	ន. ជ័រដែលដុសលុបស្នាមឬអក្សរដែលបានសរសេរ។ ឧ. ជ័រលុបនេះទុកសម្រាប់លុប កែកំហុស ឬកែឱ្យល្អ។	៣
ឈ	**ឈ**	
ឈឺ	កិ. ចាប់ជំងឺ ទទួលរងជំងឺ។ ឧ. សិង្ហឈឺចិត្តក៏អត់ស៊ីចំណីរហូតដល់ស្លាប់។	៣
ឈើទាល	ន. ឈ្មោះឈើមួយប្រភេទមានជ័រសម្រាប់ធ្វើចន្ទុះឬលាប បិទពរទូកជាដើម ឯខ្លឹមសម្រាប់ជាគ្រឿងទព្វសម្ភារៈផ្សេងៗជាឈើមានប្រយោជន៍។	២
ឈ្នានីស	ន. ច្រណែន ឫស្យា បង្ខាត កាត់លាភឬប្រយោជន៍គេ។ ឧ. អក្សរសិល្ប៍ប្រជាប្រិយក៏អប់រំឱ្យចេះស្រឡាញ់ កុំឱ្យមានចិត្តនិន្ទាឈ្នានីស...។	៥
ឈ្មៀង	ន. សំយាបដែលតពីគេហដ្ឋានចេញមកជារបៀង។	៥
ឈ្មុស	ន. សត្វជើងបួន ពពួកសំពោចមានក្លិនទឹកកាមប្រហើរភាយសម្រាប់ឱ្យផ្សំធ្វើទឹកអប់។ ឧ. ឈ្មុសមានពីរប្រភេទ គឺ ឈ្មុសស្បូវនិងឈ្មុសប្រែង១។ កិ. ឈ្មុសគាស់ដីដោយចុងច្រមុះ។ ឧ. ជ្រូកឈ្មុសដី។	១
ញ	**ញ**	

ញញឹម	កិ. សើចបិទមាត់មិនចេញសំឡេង។ ឧ. ប៉ូលិសញញឹមរួចណែនាំក្មេងៗឱ្យចេះរកជំនួយ។	៣
ញ៉ែះញ៉ោះ	កិ. រឡេះឡោះដោយលេង ឬដោយប្រឡែង។	២
ញាំង	កិ. ប្រើ បង្គាប់។ ឧ. គ្រូញាំងសិស្សឱ្យរៀន, យើងត្រូវញាំងចិត្តឱ្យជ្រះថ្លាសិន។	៦
ញាណ	ន. សេចក្តីដឹង ប្រាជ្ញា។ ឧ. គាត់មានញាណដឹងរឿងដែលនឹងកើតឡើង។	៥; ៦
ញាតិកា	ន. ពួកញាតិ។	៦
ញាតិ	ន. អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងម្តាយឬឪពុក(ញាតិ៧សន្តាន)។ ឧ. បើគេឫកល្អ ទោះបីមានក្រ កូនគួររាប់យកគេជាញាតិ។	២;៤;៥
ញៀន	កិ. ជាប់ចិត្តដែលអត់មិនបានដោយធ្លាប់ប្រព្រឹត្ត ជក់ ស៊ីផឹក ...។ ឧ. គាត់ញៀនស្រាហើយ បបួលតែគ្នាផឹកមិនសូវគិតគ្រួសារ។	៣
ញោម	ន. ពាក្យសម្រាប់បព្វជិតហៅឪពុកម្តាយ។ ឧ. ញោមប្រុសនាម ព្រហ្មជួន និងញោមស្រីនាម យក់។	៥
ញោះ	កិ. សំពងដោយពាក្យសម្តី។ ឧ. ខ្ញុំញោះមួយម៉ាត់ទៅ គាត់ច្រឡោតតូង។	១
ញ័រ	កិ. កម្រើកទទាក់ កម្រើករន្ធាន់។	២
ដ	**ដ**	
ដរាប	ឈ. រៀងរាប ត្រឹម កំណត់ត្រឹម។ ឧ. ដរាបណាខ្ញុំនឹងវិលមកដល់វិញ ដរាបនោះសឹមយើងនឹងទៅជាមួយគ្នា។	៦
ដរាប(ជាដរាប)	គុ.កិ. ជានិច្ច គ្រប់ពេលវេលា។ ឧ. គាត់យកកូនទៅជាមួយជាដរាប។	៦
ដារលាន	ន. ពិធីបុណ្យដែលប្រជាជនរួមគ្នាធ្វើតាមភូមិក្រោយប្រមូលផលស្រូវរួច។ ឧ. បុណ្យដារលានធ្វើនៅក្រោមដើមពោធិ៍។	៣
ដាស់តឿន	កិ. តឿនឱ្យភ្ញាក់ស្មារតី ឱ្យនឹកឃើញ។ ឧ. គាត់ចូលចិត្តនិយាយដាស់តឿនកូនចៅ។	៣

ដឹក	កិ. ១.នាំបណ្តើរដោយខ្សែរ។ ឧ. ឪពុកនិងកូនដឹកលាទៅលក់។ ២.កាន់ខ្សែទាញអូសទាំង២ខាង៖ ឧ. ដឹកគន។ ៣. គូសអូសឱ្យដិតជាស្នាមគំនូស៖ ឧ. ដឹកបន្ទាត់។	២
ដឹង	ន. ប្រដាប់ប្រើប្រាស់ធ្វើដោយដែកមានដង មានផ្លែសម្រាប់ក្របែល ពុះ ឬចាំងឈើ។	២
ដឹងគុណ	កិ. ស្គាល់គុណ ជ្រាបច្បាស់ក្នុងចិត្តនូវគុណ។ ឧ. អ្នកគ្រូសប្បាយចិត្តដែលឃើញសិស្សដឹងគុណគ្រូ។	៣
ដើរ	កិ. លើកជើងឈានដោយលើកដាក់ជើងនីមួយៗជាវេន។ ឧ. ពេលដើរក្បែរចាស់ៗឬស្ត្រីមានផ្ទៃពោះ យើងរឹតតែប្រយ័ត្ន។	៣
ដៀល	កិ. រិះគន់ និយាយបង្អាប់បង្អោនអ្នកដទៃ។ ឧ. គាត់ហ៊ានដៀលពូជឯងធ្ងន់ៗ។	៤
ដំណាំ	ន. រុក្ខជាតិដែលដាំដុះជាអាហារ។ ឧ. យើងមានដំណាំដំឡូងមីនិងកៅស៊ូ តែខ្វះរោងចក្រច្នៃ។	៣
ដំបូន្មាន	ន. ឱវាទ ពាក្យប្រដៅ។ ឧ. គ្រូឱ្យដំបូន្មានទៅតុលា។ ឧ. កូនល្អស្តាប់ដំបូន្មានដោយចិត្តស្មោះសរ។	៣; ៤
ដំបៅងា	ន. ប្រភេទដំបៅមា្យ៉ងមិនងាយជា។ ឧ. ដំបៅងាអាចឆ្លងតាមរយៈការប៉ះពាល់ដោយផ្ទាល់លើដំបៅ។	១; ២
ដំឡូង	ន. រុក្ខជាតិដើមត្រង់ឬវល្លិមានមើមប្រើជាអាហារ។	៣
ដំឡូងមី	ន. ដំឡូងមានដើមត្រង់ មែកច្រើន ស្លឹកស្រដៀងនឹងស្លឹកគ មើមរាងមូលទ្រវែង។ ឧ. ម្សៅដំឡូងមីអាចយកមកធ្វើនំបុ័ង នំប៉ាវ មី ...។	៣
ដំឡើង តម្លើង	កិ. ធ្វើឱ្យឡើង ធ្វើឱ្យខ្ពស់ជាងមុន។ ឧ. អ្នកនេសាទចេះតែដំឡើងថ្លៃត្រី។	
ដ៏	គុ.កិ. ដែល ណាស់។ ឧ. គាត់ជាមនុស្សដ៏ល្អ។(very)	
ឋ	**ឋ**	
ឋានន្តរ	ន. លំដាប់នៃទី មុខងារ ងារ ថ្នាក់ងារ ថ្នាក់កិត្តិយស។ ឧ. លោកម លោកមានឋានន្តរជាអភិបាលក្រុង។	២

ហានីយ	ន. ទីសម្រាប់សំចត កន្លែងចតយាន។ ឧ.តាឌីដើរសំដៅហានីយរទេះភ្លើង។	១
ហានៈ	ន. ងារ មុខងារ យសស័ក្តិ។ ឧ. លោកត្រូវបានថ្វាយហានៈជា "សម្តេចសង្ឃរាជថ្នាក់ទី១" និងជាបណ្ឌិតអក្សរសាស្ត្រទី១។	៥
ឋិតថេរ	គង់វង្ស។	៥
ឌ	**ឌ**	
ឌឺ	កិ. ផ្តើនឱ្យ និយាយផ្តើន។ ឧ. ខ្ញុំស្តីប្រដៅទៅ វាឌឺមកវិញ។ បើគុ.កិ. និយាយឌឺ ជេរឌឺ។	១; ២
ឍ	**ឍ**	
ឍាមរា 🐓	ន. បក្សីស្រដៀងទា តែមានរាងកាយធំរឹងប៉ឹង ស្លាបរឹង ក្បាលធំ ចំពុះទំពក់ស្រដៀងត្មាត ហើយមិនចេះហើរ។	១; ២
ណ	**ណ**	
ណាស់	និ. ក្រៃពេក ក្រៃលែង លើសលប់ ខ្លាំង។ ឧ. ល្អណាស់ អាក្រក់ណាស់។	២
ណែងណែង	ន. ពាក្យច្រូនជាប់គ្នាធ្វើឱ្យកំណាព្យឬឃ្លាល្បះកាន់តែពីរោះថែមទៀត។ ឧ. បទនីមួយៗពីរោះរណ្តំណែណែងគួរឱ្យចូលចិត្ត។	៥
ត	**ត**	
តណ្ហា	ន. ចំណង់ សេចក្តីប្រាថ្នា សម្រែក សេចក្តីអន្ទះអន្ទែង ...។ ឈ្មោះធីតានៃមារ ...។	៦
តថភាព	ន. ភាពនៃការពិត។	៥
តន្ត្រី	ន. ភ្លេង សំឡេងដែលបានប្រគំហើយដោយដេញ ដំ ផ្លុំ កូត។ ឧ. ពេលស្តាប់តន្ត្រីបុរាណខ្មែរ ធ្វើឱ្យយើងលន្លង់លន្លោច។	២,៣,៤
តបស្នង	កិ. សងគុណ។ ឧ. លទ្ធផលសិក្សាល្អ ក៏អាចចាត់ទុកជាការតបស្នងសងគុណមាតាបិតានិងលោកគ្រូអ្នកគ្រូដែរ។	២
តម្បាញ	កិ. គ្រឿងប្រដាប់សម្រាប់ត្បាញ។ ឧ. នៅភូមិខ្ញុំ ប្រជាជនភាគច្រើនប្រកបរបរតម្បាញ។	២
តម្ពក់	ន. ឈើ ឬឫស្សីវែងដែលគេប្រើសម្រាប់បេះផ្លែឈើ។	៥

តម្រា	ន. សេចក្តីត្រាទុក រឿងដែលកត់ទុកដោយសង្ខេប។ ឧ. តាមក្បួនតម្រា យើងធ្វើបុណ្យដារលានក្រោយប្រមូលផល។	៣
តម្លឹង	ន. ឯកតាទម្ងន់ដែលថ្លឹងមានចំនួន១០ជីឬ៣៧.៥ក្រាម។ ឧ. ពួកគេអាចរកមាសបានពីប្រាំជីទៅមួយតម្លឹង។	៦
តាខេ	ន. ឈ្មោះគ្រឿងភ្លេងមួយប្រភេទមានខ្សែធ្វើដោយលួស មានស្នូករាងដូច ក្រពើ។	២
តាព្រហ្ម	ន. ទេវតាដែលកើតនៅឋានលើ(ព្រហ្មលោក)។ ឧ. តាព្រហ្មសារភាពសុំចុះចាញ់។	២
តុល្យភាព	ន. ការថ្លឹងឱ្យមានទម្ងន់ស្មើគ្នា ការស្មើភាពគ្នា។	៤
តូរ្យតន្ត្រី	ន. គ្រឿងភ្លេងទាំងឡាយដែលលេងតាមរយៈដេញ ដំ ផ្លុំ កូត ។ ឧ. តូរ្យតន្ត្រីខ្មែរជាសិល្បៈបុរាណដែលកើតមានយូរហើយ។	៣, ៤
តួយ៉ាង	ន. គំរូ ឧទាហរណ៍។ ឧ. ចម្លើយនេះយកជាតួយ៉ាងពុំកើត។	៤
តួសេចក្តី	ន. ខ្លួននៃតែងសេចក្តីដែលជាសេចក្តីបរិយាយសំខាន់។ ឧ. ឬនត្រូវបន្ថែមមួយចំណុចទៀតត្រង់តួសេចក្តី។	៣
តួអង្គ	ន. មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលមានសកម្មភាពនៅក្នុងរឿង។ ឧ. តួអង្គសិង្ហមានភាពស្មោះត្រង់តែរើសអើង។	៣; ៦
ត្បាល់ក្បឿង	ន. ត្បាល់ដែលមានអង្រែជាប់នឹងដងសម្រាប់ជាន់បុកស្រូវជាដើម។	១
ត្មាតភ្លើង	ន. បក្សីមួយប្រភេទមានមាឌធំ មានក្បាលក្រហមដូចភ្លើង។	១
ត្រឈឹងត្រឈៃ	គុ. ម្លប់ជិតឈឹងសន្លែ។	២
ត្រសុំ	គុ. ដែលមានបរិមណ្ឌលល្អមូលជុំគ្នា។ ឧ. ដើមឈើនេះបែកមែកត្រសុំម្លប់សាខា។	៣
ត្រាយ	កិ. ធ្វើឱ្យមានជាតម្រាយ, កាត់ព្រៃឱ្យមានជាផ្លូវជាជ្រលង។ ឧ. ត្រាយព្រៃ ត្រាយផ្លូវ។	
ត្រិះរិះ	ន. ការគិត ពិចារណា។	៤
ត្រីចក្រយាន	ន. ឈ្មោះយានតូចមានកង់៣មួយប្រភេទ។ ឧ. ខ្ញុំធ្លាប់ឃើញត្រីចក្រយាននៅកំពង់ចាម។	៣

ត្រីចក្រយានយន្ត	ន. ឈ្មោះយានតូចមានកង់៣មួយប្រភេទ ដោយប្រើកម្លាំងម៉ាស៊ីន។ ឧ. សព្វថ្ងៃ យើងកម្រឃើញត្រីចក្រយានយន្ត។	៣
ត្រីសព្ទ	ន. សញ្ញាដូចសក់ក(ៈ)នេះ ដាក់លើពួកអ៤តួ គឺ«ប ស ហ អ» ឱ្យមានសំឡេងជាពួកអ៊ គឺ«ប៊ ស៊ ហ៊ អ៊»។ ឧ. ខ្ញុំអាចរកពាក្យដែលមានត្រីសព្ទបាន១០ពាក្យ។	៣
ត្រុដិ	ន. ការផ្តាច់ ដំណើរកាត់, ភ្លេងចម្រៀងមួយប្រភេទក្នុងខេត្តសៀមរាប លេងតែពេលចូលឆ្នាំ។ ឧ. ភ្លេងត្រុដិ លេងត្រុដិ។	៦
ត្រួស	កិ. ព្រាង, គ្រោយ, ធ្វើឱ្យមានលំនាំដើម្បីនឹងធ្វើទៀតឱ្យបានសម្រេច។ ឧ. ត្រួសព្រៃ។	៣
ត្រួស	ន. សា គ្រា ដង។ ឧ. មើលពីរត្រួស គឺមើលពីរសាឬពីរដង។	៣
ត្រួសៗ	ច្បាលៗ, លំៗ។ ឧ. មើលត្រួសៗ និយាយត្រួសៗ។	៣
ត្រេកអរ	កិ. មានអំណររីករាយចិត្ត។ ឧ. ពុកត្រេកអរពេលកូនចេះអានអក្សរ។	៣
ត្រែះ	ន. ល្បែងលេងដោយប្រើខ្នាច់ចង្កឹះឬគ្រាប់អ្វីៗ...ពោតជាដើម។ ឧ. អ្នកខ្លះលេងត្រែះ។	២
ត្រៃសរណគមន៍	ន. ការដល់នូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំង៣ ជាទីរឭក ឬជាទីពឹង គឺជឿព្រះរត្នត្រ័យទាំង៣នេះស៊ប់ថា ជាទីរឭក ឬជាទីពឹងដ៏ប្រសើរបំផុត។	៦
ត្លុក	ន. អ្នកកំប្លែង អ្នកក្រមាច់ក្នុងល្បែងរបាំដើម្បីឱ្យគេសើច។	២
ត្លុម	ន. ឈ្មោះសត្វស្លាបមួយប្រភេទ មានជើងវែង សម្បុរដូចខ្មែកត្រោក មានវាវិជជាតិជាចំណី។	២
ត្អូញត្អែរ	កិ. ត្អូញហើយត្អូញទៀត។ ឧ. ទោះហត់នឿយម៉ែមិនត្អូញត្អែរ។ ឧ. គាត់បានត្អូញត្អែរប្រាប់ប្រពន្ធ។	២:៣:៩
ត្អើក	កិ. កម្រើកញាក់សរសៃទ្រូងដល់ក បង្កើតឱ្យចេញខ្យល់មានទាំងសូរអឺកៗ ង៉ុកៗមកផង។	២
តំបន់ទេសចរណ៍	ន. ទីកន្លែងសម្រាប់ដើរលំហែកម្សាន្ត។ ឧ. រមណីយដ្ឋានផ្សោកជាតំបន់ទេសចរណ៍ដែលគួរឱ្យចាប់អារម្មណ៍។	៥

តាំងពិព័រណ៍	កិ.	ដាក់តាំងផលិតផល...របស់ផ្សេងៗបង្ហាញឱ្យមហាជនមើល។ ឧ. អាឡិចសាន់ដឺ ក្រាហាំបែល និងជំនួយការចូលរួមក្នុងពិធីតាំងពិព័រណ៍។	៥
ថ		**ថ**	
ថវិកា	ន	ប្រាក់ ចំនួនទឹកប្រាក់ដែលគ្រោងទុកចំណាយលើអ្វីមួយ។ ឧ. ការទាក់ទងគ្នាតាមទូរសព្ទឆ្លាតវៃនាំឱ្យចំណេញពេលវេលានិងថវិកា។ ឧ. យើងគ្រោងថវិកា, គាត់ចាយវាយប្រាក់កុំឱ្យហួសលើសពីថវិការបស់ខ្លួន។	៣:៤:៦
ថាមពល	ន.	កម្លាំងចិត្តនិងកម្លាំងកាយ កម្លាំងយ៉ាងស្វាហាប់។ ឧ. អាស៊ានចង់រួបរួមគ្នាប្រកបដោយថាមពល។	៣
ថេរ	គុ.	មាំមួន ខ្ជាប់ខ្ជួន យឺនយូរ, សម្រាប់និយាយផ្សំនឹងពាក្យបិត។ ឧ. បិតថេរ គឺតាំងនៅមាំយឺនយូរ។	១
ថែរក្សា	កិ.	គ្រប់គ្រងផងរក្សាផង។ ឧ. យើងត្រូវថែរក្សាធនធានព្រៃឈើដោយស្វែងយល់ពីសារៈសំខាន់និងផ្សាយចំណេះដឹងនេះ និងការពារដោយកុំឱ្យមានការកាប់គ្មានច្បាប់ទម្លាប់។	៣
ថោក	គុ.	មិនថ្លៃថ្នូរ ដែលមានតម្លៃតិច។ ឧ. បន្លែនេះមិនគួរមានតម្លៃថោក។	៣
ថ្កូរ	ន.	ខ្សែចងអំបោះឆ្នាក់សម្រាប់ត្បាញ។ ឧ. មនុស្សធំជួយថ្កូរនិងជ្រលក់សូត្រ។	២
ថ្កើងថ្កាន	គុ.	ថ្កើងរុងរឿង ថ្កើងមានកេរ្តិ៍ឈ្មោះខ្ពស់ត្រដែត។ ឧ. ប្រទេសថ្កើងថ្កានព្រោះពួកយើងខិតខំរៀន។	៣
ថ្នាក់រៀន	ន.	ខណ្ឌនៃបន្ទប់សម្រាប់រៀននិងបង្រៀន។ ឧ. នេះជាថ្នាក់រៀនរបស់បងខ្ញុំ។	៣
ថ្កក់	កិ.	កោះការដោយតម្កក់។	២
ថ្មី	គុ.	ទីទៃពីចាស់ គឺថ្មោង ឬដំបូង។ ឧ. ចៅឪបានកាតាបថ្មី។	៣
ថ្មើរជើង	ន.	ការធ្វើដំណើរដោយដើរ អ្នកដើរដោយជើង។ ឧ. តារានិងស្រីពេជ្រទៅរៀនដោយថ្មើរជើង។ ឧ. ផ្លូវនេះមានថ្មើរជើងឆ្លងកាត់ច្រើន។	៣
ថ្លាឈ្វេង	គុ.	ដែលជ្រះស្រឡះឥតមន្ទិល។	២

ថ្ដុក	ន. ទីដីក្រហូងដែលដក់ទឹកភ្លៀងក្នុងរដូវវស្សា តែតូចជាងត្រពាំង ច្រើនកើតដោយសារក្របីដេក។	២
ថ្លៃ	គុ.កិ. ១.ដែលមានតម្លៃ។ ឧ. ពូនោះលក់ថ្លៃណាស់។ គុ. ២.គាត់ប្រើរបស់ថ្លៃ។ កិ. ៣.មានតម្លៃច្រើន។ ឧ. ប្រអប់នេះថ្លៃណាស់។ ន. ៤.ចំនួនប្រាក់នៃតម្លៃទំនិញឬសេវា។ ឧ. នេះជាថ្លៃឈ្នួលរបស់ឯង។ គុ. ៥. ដែលមិនមែនជាសាច់បង្កើត។ ឧ. បងថ្លៃ ប្អូនថ្លៃ សាច់ថ្លៃ។	៣
ថ្លៃថ្នូរ	គុ. មានតម្លៃគួរលើកសរសើរ គួររាប់អាន។ ឧ. ឪពុកម្ដាយតែងចង់ឱ្យកូនមានសេចក្ដីថ្លៃថ្នូរ។ ឧ. មនុស្សនេះមានឫកថ្លៃថ្នូរ។	២;៤;៥
ទ	**ទ**	
ទក្សិណ	ន. ទិសខាងត្បូង។ ឧ. លោកឱ្យគោរពទិសខាងស្ដាំឬខាងត្បូង គឺគោរពគ្រូព្រឹទ្ធាចារ្យ អ្នកដឹកនាំបង្រៀនយើង។	៣
ទង់ជាតិ	ន. ទង់ដែលជានិមិត្តរូបនៃជាតិមួយ។ ឧ. តស់! ទៅគោរពទង់ជាតិ។	៣
ទន្ត	ន. ធ្មេញ ភ្នុក។ ឧ. ទន្តពេទ្យពេទ្យមានឯកទេសខាងព្យាបាលធ្មេញ។	៣
ទន្ទ្រំ	កិ. ដាក់ជើងចំខ្លាំងៗ។ ឧ. ព្រានទន្ទ្រំជើងឮសូរដល់លលក។	២
ទន្ទ្រាន	កិ. ពារពានលើ រុករានលើអ្វីមួយ។ ឧ. អាជីកម្មកាប់ទន្ទ្រានព្រៃឈើក៏នាំឱ្យវិនាសសត្វព្រៃដែរ។	២; ៤
ទន្សោង	ន. ឈ្មោះសត្វជើង៤ ពួកគោព្រៃ។ ឧ. ទន្សោង គោព្រៃ ខ្ទីង... បានបាត់បង់មួយចំនួនធំ។	៤
ទន់ភ្លន់	គុ. ល្អាសល្អន់ សុភាព។ ឧ. ឫកពាទន់ភ្លន់ សម្ដីទន់ភ្លន់។	៤
ទន់ល្មើយ	គុ. ដែលទន់ល្មៃ ទន់ដូចសំឡី។	២
ទស្សនកិច្ច	ន. ទស្សនាចរណ៍ទៅទីណាមួយឬជួបជនណាម្នាក់ ក្នុងគោលបំណងអ្វីមួយ។ ឧ. ទស្សនកិច្ចនេះបានផ្ដល់គំនិតរៀបចំវត្ត	៥

	អារាមធ្វើបុណ្យ ជាមណ្ឌលជួបជុំទាក់ទងគ្នា ពិសេសរៀនអក្សរសាស្ត្រខ្មែរ។	
ទស្សនា	កិ. មើល មើលកម្សាន្ត ដើរមើលកម្សាន្ត គយគន់។ ឧ. ខ្ញុំបានទៅទស្សនាសារមន្ទីរជាតិ។ ឧ. គេទស្សនាទូរទស្សន៍។ ឧ. នៅពេលដើរទស្សនាកន្លែងទាំងនោះ នាងបានជួបហេតុការណ៍គួរឱ្យចាប់អារម្មណ៍ជាច្រើន។	៣:៤:៥
ទស្សនាវដ្តី	ន. សៀវភៅចុះអត្ថបទច្រើនផ្នែក ផ្សាយប្រចាំសប្តាហ៍ឬប្រចាំខែ។ ឧ. ថ្ងៃទំនេរ ប៉ែនតែងដើរលក់កាសែត ទស្សនាវដ្តី។	៥
ទស្សនៈ	ន. ការយល់ឃើញ ដំណើរយល់ឃើញ។ ឧ. មនុស្សបញ្ចេញទស្សនៈផ្សេងៗគ្នាដើម្បីសន្សំសំចៃទឹក។ ឧ. សុខានិងធីតាជជែកគ្នាអំពីទស្សនៈអ្នកសរសេរ។	៤; ៥; ៦
ទស្សន៍ទាយ	កិ. ទាយពីអ្វីៗដែលមិនទាន់ដល់តាមការសង្កេត។ ឧ. អ្នកវិទ្យាសាស្ត្រទស្សន៍ទាយថា ពិភពលោកនឹងខ្សត់ទឹកប្រើប្រាស់។	៤
ទាញព្រ័ត្រ	ន. ល្បែងមនុស្សពីរពួក ច្រើនតែប្រុសម្ខាងស្រីម្ខាង ទាញកន្ទុយព្រ័ត្រឬពួរទាំងពីរខាងដោយប្រឹងពេញទំហឹង ល្បងកម្លាំងគ្នាយកឈ្នះ។ ឧ. ក្មេងៗចង់លេងទាញព្រ័ត្រ តែគ្មានអ្នកនាំ។	៣
ទាយ	កិ. ពោលឱ្យដឹងមុនពីអ្វីៗដែលមិនទាន់ដល់មិនទាន់មក។ ឧ. ហោរទាយថា ក្នុងឆ្នាំនេះមានទឹកភ្លៀងច្រើនជាងឆ្នាំចាស់។	៤
ទារុណកម្ម	ន. អំពើកាច អំពើអាក្រក់ អំពើសាហាវយង់ឃ្នង។ ឧ. ពួកចាំរាងបានធ្វើទារុណកម្មលោកដោយសម្ងាត់។	៥
ទាសី	ន. ខ្ញុំស្រី ខ្ញុំបម្រើស្រី។	៦
ទិញ	កិ. បានអ្វីៗដោយឱ្យថ្លៃជាប្រាក់ទៅអ្នកលក់។ ឧ. តើក្មួយចង់ទិញអ្វីដែរ? -បាទ ស្ករស១គីឡូ។	៣
ទិដ្ឋភាព	ន. ភាពនៃអ្វីៗដែលគេបានឃើញបានច្បាស់ប្រទះ។ ឧ. ទិដ្ឋភាពនេះ ធ្វើឱ្យអ្នកភូមិនាំគ្នារត់ឡើងមកលើភ្នំដើម្បីពន្លត់ភ្លើង។ ឧ. គន្ធាបានឃើញទិដ្ឋភាពខេត្តមណ្ឌលគិរីតាមទូរទស្សន៍។	២:៤:៥:៦
ទិព្វ	គុ. ដែលប្រហែលនឹងឬជារបស់ទេវតា។	៥

ទិវង្គត	កិ. ស្លាប់។ ឧ. ស្តេចសៀមសោយទិវង្គត់ ពេលច្បាំងជាមួយជ័យអស្ចារ្យ។	៥
ទិវា	ន. ក្នុងវេលាថ្ងៃ នៅពេលថ្ងៃ។ ឧ. សូមឱ្យសត្បាននិងគ្រួសារជួបតែសេចក្តីសុខគ្រប់ទិវារាត្រី។	៥
ទិសអាគ្នេយ៍	ន. ខាងកើតឆៀងត្បូងត្រង់១៣៥°។ ឧ. ហោរាទស្សន៍ទាយថាទឹកដីនាទិសអាគ្នេយ៍នៃភ្នំដូនពេញជាកន្លែងល្អ។	៥
ទិសា	ន. ភាគចំណែកមុខ ក្រោយ ឆ្វេង ស្តាំព្រមទាំងជ្រុងជាចន្លោះទាំង៤និងខាងលើ ខាងក្រោម។	៤
ទីកន្លែង	ន. កន្លែងដែលជាទីណាមួយ។ ឧ. បងចង់នាំអ្នកទៅទីកន្លែងដែលសប្បាយៗ។	៣
ទីសាធារណៈ	ន. កន្លែងទូទៅ កន្លែងដែលប្រើបានទាំងអស់គ្នា។ ឧ. កុមារនេះមានសុជីវធម៌នៅទីសាធារណៈ។	៣
ទឹកចិត្ត	ន. សន្ដានចិត្ត ចិត្តដែលមានអធ្យាស្រ័យ អារម្មណ៍។ ឧ. គេមានទឹកចិត្តគោរពស្រឡាញ់ម្ដាយគេណាស់។	៣
ទឹកជំនន់	ន. ទឹកឡើងហួសពីកម្រិតកំណត់នៅកន្លែងនីមួយៗនៃផ្លូវទឹក។ ឧ. សាលាយើងធ្លាប់មានទឹកជំនន់។	៣
ទឹកដី	ន តំបន់ណាមួយរបស់ប្រទេស ខេត្ត ឬស្រុក។ ឧ. ខ្ញុំស្រឡាញ់ទឹកដីខ្មែរ។	៣
ទឹម	កិ. ដាក់នឹមលើ-កឬពាក់គ្រឿងប្រដាប់សត្វពាហនៈឱ្យ ទាញឱ្យអូសនង្គ័ល។ ឧ. កសិករទឹមគោទៅស្រែហើយបានចួបខ្លា។	៣
ទុក	កិ. ដាក់អ្វីក្នុងទីណាមួយឱ្យគង់ រក្សាអ្វីៗឱ្យគង់។ ឧ. ខ្ញុំដាក់សៀវភៅនៅលើតុ។	៣; ៦
ទុក្ខ	ន. សេចក្តីព្រួយ សេចក្តីលំបាក (កាយនិងចិត្ត)។ ឧ. សិង្ហកើតទុក្ខមិនស៊ីចំណីប្រាំថ្ងៃ។ ឧ. ខ្ញុំមានទុក្ខ។	២;៣;៤;៦
ទុក្ខធុរៈ	ន. ការមានទុក្ខកង្វល់ផងរវល់ផង។ ឧ. គ្រួសារខ្ញុំយោគយល់គ្នានិងជួយទុក្ខធុរៈគ្នា។	៣
ទុក្ខព្រួយ	ន. ទុក្ខហើយព្រួយនឹងទុក្ខឥតល្ហែ។ ឧ. គាត់គ្មានទុក្ខព្រួយទេ ព្រោះកូនចេះជួយ។	៣
ទុយមុយ	គុ. ដែលមុយៗ យឺតៗ ភ្លឹះៗ មិនសូវនិយាយស្តី។	៦

ទូន្មាន	កិ. ដាស់តឿន ប្រៀនប្រដៅ អប់រំ។ ឧ. សុជាតែងស្តាប់ការទូន្មានរបស់អ្នកគ្រូលោកគ្រូ។ ឧ. យាយប្រដៅប្រៀន ចៅៗខំរៀន គ្រួសាររីករាយ។ ឧ. មាតាបិតាទូន្មានបុត្រធីតាឱ្យខំសិក្សាគ្រប់វិជ្ជា។	២; ៣; ៥; ៦
ទូរទស្សន៍	ន. ប្រដាប់វិទ្យាសាស្ត្រម្យ៉ាងសម្រាប់បញ្ចាំងបញ្ជូនរូបភាពនិងសូរសព្ទទៅទីឆ្ងាយបាន។ ឧ. ទូរទស្សន៍នៅលើទូ។	២; ៥
ទូរសព្ទ	ន. ប្រដាប់វិទ្យាសាស្ត្រម្យ៉ាងសម្រាប់បញ្ជូនសំឡេងឆ្លើយឆ្លងទៅកាន់ទីឆ្ងាយបាន។ ឧ. ជាងមួយរយឆ្នាំមុន គេប្រើទូរសព្ទស្រាប់តែហៅទាក់ទងគ្នា។	៥
ទូល	កិ. ប្រាប់ ឱ្យដំណឹង។ ឧ. ទូលស្តេច ទូលព្រះសង្ឃ។	៤
ទេសចរ	ន. ជនអ្នកធ្វើដំណើរលម្ហែកម្សាន្ត។ ឧ. ទេសចរទិញវត្ថុអនុស្សាវរីយ៍។	៣
ទេសចរណ៍	ន. ដំណើរលម្ហែកម្សាន្ត។ ឧ. កុសលសួរកកន្លែងទេសចរណ៍។ ឧ. គ្រួសារគន្ធានាំគ្នាជិះរថយន្តទេសចរណ៍។	៣; ៤
ទេសនា	ន. ការសម្តែងធម៌។ ឧ. មីងពូស្តាប់លោកទេសនា។	៣;៦
ទេសភាព	ន. សភាពដែលអាចមើលឃើញទាំងអស់ដូចជាទឹក ដី ព្រៃ ព្រឹក្សាជាដើម។ ឧ. ខ្ញុំចូលចិត្តទេសភាពវាលស្រែអ៊ីចឹង។ ឧ. គ្មានអ្វីដែលគួរឱ្យចង់គយគន់ជាងទេសភាពវាលស្រែ។	២; ៣
ទោចក្រយាន	ន. យានមានកង់ពីរនិងទៅមុខបានដោយឈ្នាន់ជាក់។ ឧ. ស្រុកយើងមានដំឡើងទោចក្រយាន។	៣
ទោចក្រយានយន្ត	ន. យានមានកង់ពីរដែលដើរដោយកម្លាំងម៉ាស៊ីន។ ឧ. នៅពេលនោះ ទោចក្រយានយន្តកំពុងបើកបរតាមដងវិថី។	៣
ទោស	ន. កំហុសព្រោះកំហឹង ព្រោះទង្វើខុសច្បាប់ ព្រោះប្រមាថ។ ឧ. មនុស្សមានទោសកុំយកខ្លួនបៀត។ ឧ. គាត់មានទោសព្រោះលួចគេ។	៣
ទោសា	ន. កំហឹង។	៦
ទោស័ក	ន. ស័កទី២នៃឆ្នាំ ក្នុងចំនួនស័កឆ្នាំទាំងដប់។	៦
ទ្រគោះ	គុ. ដែលច្រឡោះបោះ គំរោះគំរើយ។ ឧ. ពាក្យទ្រគោះ សម្តីទ្រគោះ, គុ.កិ. និយាយទ្រគោះ។	២

ទ្រនំ	ន. ទីកន្លែងដែលសត្វស្លាបតែងទំ។ ឧ. ក្រសារក៏វិលរកទ្រនំវិញទៅ។	២
ទ្រព្យ	ន. វត្ថុ ធនធាន សម្បត្តិ។ ឧ. ម៉ែពូកែថែទ្រព្យទាំងចាស់ទាំងថ្មី។ ឧ. បុរសដែលប្រើប្រាស់គ្រឿងញៀនបំផ្លាញទ្រព្យខ្លួនឯងនិងសង្គម។	២; ៣; ៦
ទ្រមែ	គុ. តូចទាបរាងសាយក្រោម។ ឧ. គាត់មានរាងទាបទ្រមែ។	១
ទ្រឹស្តី	ន. ការយល់ឃើញដោយគំនិតប្រាជ្ញានិងយោបល់, គោលការណ៍ដែលពន្យល់ចង្អុលប្រាប់ដំណើរទំនងនៃកិច្ចការទាំងពួងដែលត្រូវធ្វើយ៉ាងណាៗ។ ឧ. ការកាន់បិណ្ឌនៃបុណ្យគុំបិណ្ឌជាទ្រឹស្តីពុទ្ធសាសនា។	៦
ទ្រុឌទ្រោម	គុ. ទ្រុឌផងទ្រោមផង។ ឧ. គាត់មានរាងកាយទ្រុឌទ្រោម។ កិ. ឧ. សុខភាពវាទ្រុឌទ្រោមនិងចុះខ្សោយជាលំដាប់។	៣
ទ្រាំ	កិ. ខំអត់ អត់ធ្មត់ ស៊ូ។ ឧ. កូនទ្រាំមិនបាន ក៏ទម្លាក់ស្នែងចោល។	២; ៥
ទ្វេហារ	ន. ពីរនាក់ ទាំងពីរប្រាណ។ ឧ. ទាំងទ្វេហារពុំដែលត្អូញត្អែរ។	៣
ទំនប់	ន. ពំនូកដីដែលគេលើកទប់រាំងផ្លូវទឹក។ ឧ. អ្នកភូមិលើកទំនប់។	៦
ទំនប់វារីអគ្គិសនី	ន. ទំនប់រាំងផ្លូវទឹកទុកប្រើប្រាស់កម្លាំងទឹកហូរផលិតជាចរន្តអគ្គិសនី។ ឧ. ទំនប់វារីអគ្គិសនីសេសាននៅខេត្តស្ទឹងត្រែង។	៦
ទំនាក់ទំនង	ន. ការទាក់ទង ការជាប់ពាក់ព័ន្ធគ្នា។ ឧ. ល្បះខាងលើបង្ហាញទំនាក់ទំនងរវាងហេតុនិងផល។	៣
ទំនាប	ន. ទីដីដែលទាប។ ឧ. តំបន់ទំនាបសម្បូរដំណាំ។	៣
ទំនិញ	ន. អ្វីដែលសម្រាប់ឱ្យគេទិញ។ ឧ. ផ្សារភូមិខ្ពុំតូច តែមានលក់ទំនិញគ្រប់មុខ។	២
ទំនើប	គុ. ថ្មី ដែលទើបកើតតាមជំនាន់សម័យថ្មី។ ឧ. នាឡិកាឆ្លាតវៃជាមធ្យោបាយទាក់ទងគ្នាបែបទំនើប។	៣
ទំនៀមទម្លាប់	ន. ប្រពៃណី បែបបទ ឬសណ្តាប់ធ្នាប់ដែលធ្លាប់អនុវត្តតៗគ្នាមក។	៦

ទំនេរ	គុ. ឥតមានវល់ ឥតមានជំពាក់ដោយហេតុអ្វីនីមួយ។ ឧ. ឆ្លៀតពេលទំនេរ សុភីទៅជួយម្តាយលក់ដូរ។	៣
ទ័ព	ន. ទាហាន សេនា និងពលសម្រាប់ធ្វើចម្បាំង។ ឧ. ស្តេចសៀមដឹង ក៏លើកទ័ពដេញតាម។	៥
ទ័ល	គុ. ១.ដែលក្រីក្រទ្រព្យ។ ឧ. មនុស្សទ័ល អ្នកទ័ល។ ២.កិ. ទើសផ្លូវ ទើសដំណើរ។ ឧ. ទ័លផ្លូវ ទ័លគំនិត។	៤
ធ	**ធ**	
ធន	ន. ទ្រព្យ សម្បត្តិ។ ឧ. ហាងខ្ញុំជិតក្សីយធនហើយ។	៣
ធនធាន	ន. ទ្រព្យរបស់ផ្សេងៗដែលគង់នៅ។ ឧ. បឹងទន្លេសាបជាប្រភពធនធានធម្មជាតិ។ ឧ. ថ្មកែវជាធនធានធម្មជាតិ។ ឧ. អ្វីទៅជាក្រសួងធនធានទឹកនិងឧតុនិយម?	២:៣:២
ធនាគារ	ន. ១.ឃ្លាំងដាក់ប្រាក់ដាក់ទ្រព្យ។ ឧ. ផ្ញើប្រាក់ក្នុងធនាគារ។ ២.គ្រឹះស្ថានហិរញ្ញវត្ថុដែលផ្តល់ឥណទាន(កម្ចី) ទទួលប្រាក់បញ្ញើ ផ្តល់មធ្យោបាយទូទាត់ប្រាក់។ ឧ. ធនាគារឱ្យយើងខ្ចី មុខជាយើងនៅមានតម្លៃ។	៤: ៦
ធនាគារឥណទាន	ន. ធនាគារដែលឱ្យខ្ចីប្រាក់ ឬធនាគារដែលមានការផ្តល់ប្រាក់កម្ចី។	៦
ធម៌	ន. ១.សភាវៈទ្រទ្រង់សត្វលោក គឺបុណ្យ បាប សុចរិត ទុច្ចរិត ហេតុ កិរិយា...។ ឧ. វាគ្មានធម៌អាថ៌ក្នុងខ្លួនសោះ។ ២.ច្រើនប្រើសំដៅយកពាក្យឱវាទនិងអត្ថបទទូទៅដែលទាក់ទងដោយពុទ្ធសាសនា។ ឧ. ពុកទៅរៀនធម៌, ឥឡូវគាត់ចេះសូត្រធម៌ថែមពីបីមេ។	៣
ធម្មជាតិ	ន. ធម៌ សភាវៈ, អ្វីៗដែលកើតឡើងឯកឯង (រុក្ខជាតិ ទឹកដី...)។ ឧ. បឹងទន្លេសាបពិតជាប្រភពធនធានធម្មជាតិដ៏សំខាន់។ ឧ. ពូសុខចេះធ្វើឱ្យកើតជាចំណីធម្មជាតិសម្រាប់ត្រី។ ឧ. ក្រសួងធ្វើការតាមដាននិងស្រាវជ្រាវពីបាតុភូតធម្មជាតិ។	២:៣:២
ធម្មតា	ន. ប្រក្រតី អ្វីៗដែលតែងមានមក ទំនៀមទម្លាប់។ ឧ. ខ្ញុំសុខសប្បាយជាធម្មតាទេ។	២: ៣

ធាតុ	ន. ១.សភាវៈដែលទ្រទ្រង់ខ្លួនឯងដូចជាទឹក ដី ភ្លើង និងខ្យល់។ ឧ. ធាតុទឹក ធាតុដី ធាតុភ្លើង ធាតុខ្យល់។ ២.អាការៈក្នុងខ្លួនដូចយ៉ាងសក់ ធ្មេញ សាច់ ឈាមជាដើម។ ឧ. ធាតុដីទាំង២១ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ ឆ្អឹង ខួរក្នុងស្មុង ខួរថ្លា ខួរខាប់ ដង្ហើម ថ្លើម ពោះវៀនតូច ពោះវៀនធំ ពោះអាហារចាស់ ពោះអាហារថ្មី លលាដ៍ក្បាល ខួរ ពោះលាមក និងភ្នែក។ ៣.មាស ប្រាក់ ដែក-ល- ក៏ហៅថាធាតុ។ ឧ. មាសជាលោហៈធាតុដ៏មានតម្លៃ។ ៤.ឆ្អឹងរបស់បុគ្គលដែលគេគួរគោរព ក៏ហៅថាធាតុឬហៅថាអដ្ឋិធាតុ។ ឧ. គេរក្សាធាតុក្នុងកោដិ។...	៦
ធាតុអាកាស	ន. លក្ខខណ្ឌនៃបរិយាកាសដូចជាសីតុណ្ហភាព ខ្យល់ ភ្លៀង ដែលអាចប្រែប្រួល។ ឧ. ថ្ងៃនេះធាតុអាកាសល្អ។	៣
ធាត់	គុ. ទីទៃពីស្គម គឺមានសាច់ច្រើន។ ឧ. ខ្ញុំចិញ្ចឹមមាន់ទាឱ្យធាត់លក់យកថ្លៃ។	៣
ធុរៈ	ន. ការរវល់ ដំណើរជំពាក់ដោយកិច្ចការ។ ឧ. ខ្ញុំទៅមិនបានដោយមានធុរៈ។	២:៤:៩
ធូប	ន. គ្រឿងក្រអូបសម្រាប់អុជបង្អុយផ្សែងជាគ្រឿងបូជា។	២
ធូរ	គុ. ទីទៃពីតឹង គឺងាយ, ទូលាយ។ ឧ. កង់មុខរាងធូរបន្តិច។ កិ. ស្រាក ស្បើយ។ ឧ.ថ្ងៃនេះ ជីតាខ្ញុំបានស្បើយបន្តិច។	១
ធ្ងន់ធ្ងរ	គុ.កិ. ដុនដាបខ្លាំង យ៉ាប់ខ្លាំង។ ឧ. ទឹកជំនន់បង្កគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ។	៣
ធ្វើការ	កិ. ធ្វើការងារ បំពេញកិច្ចការដែលត្រូវធ្វើ។ ឧ. មាមីក៏ទៅធ្វើការដូចពុកម៉ែដែរ។	៣
ធ្វេសប្រហែស	កិ. ធ្លាយ ប្រហែស។ ឧ. ជីតាធ្វេសប្រហែសដោយទុកសៀវភៅលើទូសិន។	២
ន	**ន**	
នគរ	ន. បុរី ក្រុង ប្រទេស។ ឧ. អ្នកនគរ គឺអ្នកក្រុង។	៤
នគរបាល	ន. អ្នករក្សានគរ ឃុំ ស្រុក ឬខេត្ត, ប៉ូលិស។	៦

នង្គ័ល	ន. ប្រដាប់សម្រាប់ភ្ជួរដី។	៥
ននោង	ន. ឈ្មោះវល្លិ៍ដំណាំឡើងទ្រើងមានផ្លែជាអាហារ មានច្រើនប្រភេទគឺននោងជ្រុង ននោងទេស ននោងសាញជាដើម។	២
នយោបាយ	ន. កិច្ចការដែលទាក់ទងដោយការគ្រប់គ្រងរដ្ឋ។ ឧ. អាស៊ានចង់លើកកម្ពស់វឌ្ឍនភាពនយោបាយនៅតំបន់អាស៊ីអាគ្នេយ៍។	៣
នាក់	ន. ពាក្យប្រើសម្រាប់រាប់ចំនួនមនុស្ស។ ឧ. ក្នុងផ្ទះនេះមានមនុស្សប៉ុន្មាននាក់?	៦
នាគ	កិ. កូនប្រុសដែលមានសេចក្តីធុញទ្រាន់ចំពោះការនៅគ្រប់គ្រងផ្ទះ មានចិត្តជ្រះថ្លាចូលទៅសូមបួសក្នុងសំណាក់សាសនា។ ឧ. មុននឹងបួស គេធ្វើពិធីបំបួសនាគ។	៦
នាច	កិ. ស្រក ថយចុះ។ ឧ. ចាបក៏លោតតាមទឹកនាច។	២
នាយក	ន. អ្នកដឹកនាំ អ្នកត្រួតត្រា។ ឧ. នាយកជ្រើសរើសសុជាជាសិស្សឆ្នើមប្រចាំសាលា។	៣
នាវា	ន. កប៉ាល់។ ឧ. នៅលើនាវា ដៃទាំងពីររបស់លោកត្រូវជាប់ខ្នោះ។	៥
និន្ទេស	ន. ការសម្តែងចែកញែកសេចក្តី, វិចារណ៍រង្វាយតម្លៃលទ្ធផលថាជាកម្រិតណាៗ។ ឧ. អ្នកដែលចង់បាននិន្ទេសល្អ ត្រូវស្រវា ស្រទេញរៀនសូត្រ គ្មានពេលលេងច្រើននោះទេ។	៥
និទ្រា	ន. ដំណើរដេកលក់ លង់លក់។ ឧ. សុតីក្រោកពីនិទ្រាតាំងពីព្រលឹមអរុ។ កិ ឧ. ពួកប្រុសៗក៏និទ្រាលក់គ្មានសល់ម្នាក់។ ឧ. ស្លេះប្រាប់ឪនរួច ក៏និទ្រាលក់ទៅ។	៣; ៥; ៦
និន្ទា	កិ. តិះដៀល រិះគន់។ ឧ. កុំនិន្ទាគេ គឺកុំតិះដៀលគេ។	៥
និពន្ធ	កិ. តែងឡើង តាក់តែង ចងក្រង រៀបរៀង។ ឧ. បទភ្លេងខ្មែរច្រើននិពន្ធឡើងតាមលំនាំធម្មជាតិ។ ឧ. លោកបាននិពន្ធសៀវភៅធម៌នានានិងប្រែគម្ពីត្រៃបិដក។	៣; ៥
និញ្ញាន	ន. ឈ្មោះធម្មជាតិឬចិត្តដែលចេញផុតស្រឡះ ចាកតណ្ហាគឺឥតមានតណ្ហាទាក់ឆ្អាក់នៅក្នុងសន្តានចិត្ត។	៦

និមន្ត	កិ. អញ្ជើញ, សូមឱ្យទៅ ឬសូមឱ្យមក។ ឧ. លោកបាននិមន្តមកកាន់វស្សានៅវត្តឧណ្ណាលោម។	៥; ៦
និមិត្តសញ្ញា	ន. គ្រឿងសម្គាល់ជារូប លេខ ឬអក្សរសម្រាប់សម្គាល់ន័យ។ ឧ. និមិត្តសញ្ញាទង់អាស៊ានទៅតាមលក្ខណៈប្រទេសក្នុងតំបន់។	៣
និយម	កិ. ចូលចិត្ត ចូលចិត្តជាង មានទំនោ កំណត់។ ឧ. ប្រជាជននិយមលេងល្បែងប្រជាប្រិយនៅពេលចូលឆ្នាំ។ ឧ. ការីខ្លះនិយមតាក់តែងរឿងជាកាព្យ។	៣; ៤; ៥
និយមន័យ	កិ. ន័យដែលកំណត់ ន័យដែលនិយមប្រើ។ ឧ. កូនគួរអានឱ្យយល់និយមន័យសិន។	៥
និរតី	ន. ខាងត្បូងឆៀងលិច(ត្រង់225°)។ ឧ. សម្រស់ខេត្តកែបដ៏ស្រស់ស្អាតនៃទិសនិរតី។	៣
និរន្តរ៍	កិ. ជានិច្ច ដែលឥតមានចន្លោះ។ ឧ. យើងត្រូវតែប្តេជ្ញាការពារសម្បត្តិបេតិកភណ្ឌឱ្យបានបិតជេរជានិរន្តរ៍។	៥
និស្សិត	ន. អ្នករៀននៅកម្រិតឧត្តមសិក្សា។ ឧ. និស្សិតអាមេរិកចូលមកតាមច្រកប៉ោយប៉ែត។	៥; ៦
និស្ស័យ	ន. ដំណើរឬគុណសម្បត្តិដែលមានពីកំណើតស្រាប់។ ឧ. គាត់មាននិស្ស័យខាងវង់ភ្លេង។	៥; ៦
នេត្រា	ន. ភ្នែក(ទាំងពីរ)។ ឧ. (ព.កា.) ស្តេចទតព្រះនេត្រា ឃើញធីតានៃសេដ្ឋី មានរូបឆោមពិសី ព្រះចក្រីទ្រង់ត្រាស់សួរ។	៥
នេសាទុបករណ៍	ន. ប្រដាប់នេសាទមានឈ្នាង មង អញ្ចង ទ្រូ លប ជាដើម។ ឧ. ប្រជាជននៅតំបន់ផ្សេងផលិតនេសាទុបករណ៍។	៥
ន័យ	ន. សេចក្តីពន្យល់ ខ្លឹមសារ ហេតុ ទំនង។ ឧ. សញ្ញាក្បាលខ្មោចមានន័យថាទីនោះមានមីនឬគ្រាប់មិនទាន់ផ្ទុះ។ ឧ. បើជួយទិញត្បូងនៅទីនោះ មានន័យថាលោកអ្នកជួយលើកតម្កើងផលិតផលក្នុងស្រុក។	៣; ៥; ៦
ន័យផ្ទុយ	ន. ខ្លឹមសារដែលផ្ទុយគ្នា បញ្ជោសគ្នា ឬប្រឈមគ្នា។ ឧ. ពូកែនិងខ្សោយ ពាក្យពីរនេះមានន័យផ្ទុយគ្នា។	៣
ប	**ប**	
បកស្រាយ	កិ. និយាយសម្រាយសេចក្តី ឬពន្យល់បំភ្លឺឱ្យងាយយល់។ ឧ. តើឯងអាចបកស្រាយផ្លាកសញ្ញាកុមារដឹកដៃគ្នាបានឬទេ?	៣

បក្សា	ន. សត្វស្លាបទាំងឡាយ(ឈ្មោល)។ ឧ. បក្សាទាំងឡាយរស់ព្រោះមានបក្សីដែរ។	៣
បក្សាបក្សី	ន. សត្វស្លាបឈ្មោល សត្វស្លាបញី។	៤
បក្សី	ន. សត្វដែលមានស្លាប។ ឧ. យើងអនុវត្តបែបនេះ មិនឆ្លងជំងឺផ្តាសាយបក្សីទេ។	២
បង្ការ	កិ. ការពារការខ្វះនិងរារាំងអន្តរាយ។ ឧ. កុមារត្រូវទទួលថ្នាំចាក់បង្ការជំងឺឱ្យបានគ្រប់ចំនួន។	៥
បង្កើត	កិ. ធ្វើឱ្យកើត ធ្វើឱ្យកើតមាន។ ឧ. សមាគមអាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧។	៣
បង្គំ	កិ. សំពះ ឬក្រាបសំពះទៅរកអ្នកដែលគួរគោរព។	២
បង្សុកូល	ន. ឈ្មោះពិធីម្យ៉ាងក្នុងព្រះពុទ្ធសាសនាដែលគេនិមន្តព្រះសង្ឃឱ្យចាប់ កាន់អំបោះ ឬផ្ងាំងសំពត់ដែលតភ្ជាប់ពីសាកសពឬអដ្ឋិធាតុ រួចទាញយកមកប្រើប្រាស់តាមពុទ្ធានុញ្ញាត។	៦
បង្ហាញ	កិ. ធ្វើឱ្យឃើញ។ ឧ. អ្នកគ្រូបង្ហាញអក្សរផ្ងង់ដែលត្រឹមត្រូវល្អ។	២
បង្អុរ	កិ. ធ្លាក់ភ្លៀង ទម្លាក់ទឹកភ្លៀង។ ឧ. ហេតុអ្វីតាព្រហ្មមិនបង្អុរទឹកភ្លៀង?	២; ៣
បង្អួច	ន. រង្វេះជញ្ជាំងឬដំបូល... សម្រាប់ឱ្យខ្យល់និងពន្លឺចេញចូលបាន រាងសន្ទះដូចទ្វារតែតូចជាង។ ឧ. ឯងបើកបង្អួចបន្តិចមើល។	៣
បច្ចុប្បន្ន	ន. ពេលចំពោះមុខ ពេលឥឡូវនេះ។ ឧ. បច្ចុប្បន្ន ប្រជាជនយើងខិតខំកែច្នៃគុណភាពផលិតផល។ ឧ. បច្ចុប្បន្ន គេអាចទាក់ទងគ្នាបានតាមនាឡិកាឆ្លាតវែ។ ឧ. បច្ចុប្បន្ន ក្រុមហ៊ុនបរទេសមួយកំពុងធ្វើវិនិយោគទុន។	៣; ៤; ៥; ៦
បច្ចេកទេស	ន. វិធីអនុវត្តជាក់លាក់ណាមួយដោយជំនាញឬសិល្បៈផង។ ឧ. គេអាចរៀនជំនាញបច្ចេកទេសមួយចំនួនតាមទូរសព្ទ។ ឧ. ប៉ែនគូរប្លង់និងធ្វើសំណង់ប្រកបដោយបច្ចេកទេស។	១; ២; ៣
បច្ចេកវិទ្យា	ន. វិទ្យាសាស្ត្រដែលមានបច្ចេកទេសខ្ពស់អាចនាំឱ្យមនុស្សបង្កើតសម្ភារៈទំនើបៗជាច្រើន...។ ឧ. សាមសុងអេឡិចត្រូនិកគឺជាក្រុមហ៊ុនបច្ចេកវិទ្យាធំទីពីររបស់ពិភពលោក។	៥

បច្ចេកវិទ្យាព័ត៌មាន	ន. បច្ចេកទេសតាមបែបវិទ្យាសាស្ត្រសម្រាប់បង្កើត ទទួល រក្សាទុក ប្រតិបត្តិ និងចែករំលែកព័ត៌មាន។ ឧ. គាត់កំពុងសិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន។	៣
បច្ច័យ	ន. ១.គ្រឿងអាស្រ័យសម្រាប់បព្វជិតៈ ឧ. ចតុប្បច្ច័យ ជាគ្រឿងសម្រាប់អាស្រ័យ៤យ៉ាង គឺគ្រឿងស្លៀកដណ្តប់ អាហារ លំនៅ និងថ្នាំរំងាប់ជំងឺ។ ២.ហេតុដែលនាំឱ្យផលប្រព្រឹត្តទៅៈ ឧ. អ្វីដែលជាបច្ច័យឱ្យព្រាហ្មសោយសោកកើតទុក្ខ ព្រោះតែសេចក្តីស្រឡាញ់ជាប់ជំពាក់ហ្នឹងឯង។ ៣.អក្សរដែលចុះផ្សំខាងចុងធាតុៈ ឧ. នាយក, នី+ណ្ (បច្ច័យ) ផ្លាស់ជា អក ផ្សំជា នាយក។	៦
បញ្ចាំ	ដាក់ទ្រព្យរបស់អ្វីមួយទុកជាភ័ស្តុតាងដើម្បីយកប្រាក់មកប្រើប្រាស់។ ឧ. បើគ្មានស្រែទៅបញ្ចាំ គាត់បញ្ចាំកូនទៀត។	៣
បញ្ហា	ន. ប្រស្នា ចំណោទ ឬសេចក្តីមានអាថ៌កំបាំងមិនជាទីស្វាគមន៍ឬបង្កគ្រោះ លុះតែសួរហើយត្រូវដោះស្រាយយកឈ្នះ។ ឧ. បើមានបញ្ហាសុខភាព យើងត្រូវឆាប់រួតរះទៅពេទ្យ។	៣; ៤
បដិបត្តិ	កិ. ប្រព្រឹត្ត កាន់ ធ្វើតាម។ ឧ. យើងនាំគ្នាបដិបត្តិតាមច្បាប់។	៦
បដិសព្ទ	ន. ពាក្យទាំងឡាយដែលមានន័យផ្ទុយគ្នា។ ឧ. បដិសព្ទនៃពាក្យចេះ គឺល្ងង់។	៣
បដិសេធ	កិ. ១.មិនយល់ព្រម មិនយកជាការ។ ឧ. ដង្កូវឆ្លើយបដិសេធ។ ២.ឈ្មោះហៅវណ្ណយុត្ត(ៈ) ឬហៅទណ្ឌាឃាដសម្រាប់ដាក់ឃាត់អក្សរមិនឱ្យមានសំឡេង។	២;៣;៤
បណ្តាក់	គុ.កិ. ១.ដែលសន្ធតកំណត់ផ្លាស់ប្តូរវេនគ្នាឬបន្តគ្នា។ ឧ. ម្នាក់ចេញម្នាក់ចូលដូចគេបណ្តាក់គ្នា។ ២.កិ. ដាក់រាយគ្នាឱ្យនៅបន្តហែៗបណ្តោយតាមដងផ្លូវឬទីផ្សេងៗ។ ឧ. កងទ័ពបណ្តាក់គ្នាតាមដងព្រៃ។ ៣.កិ. ទិញឬដូរដោយដាក់ដើមទុនមុន។ ឧ. កសិករបណ្តាក់ស្រូវពីសេដ្ឋីយកមកដាំ។	៣
បណ្តុះ	កិ. ធ្វើឱ្យដុះ។ ឧ. ខ្ញុំព្រោះបណ្តុះឈើផ្លែផ្កា។	៣

បណ្តើរ	កិ. ធ្វើឱ្យដើរ នាំដើរជាមួយគ្នា។ ឧ. ពួកគេបណ្តើរគ្នាទៅហាត់ប្រាណ។	៣
បណ្ឌិត[1]	ន. អ្នកមានចំណេះជ្រៅជ្រះ អ្នកឈ្លាសវៃ អ្នកប្រាជ្ញ។ ហៅអ្នកមានវិជ្ជាថ្នាក់ខ្ពស់ដែលមានសញ្ញាបត្រដុកតូរ៉ាត៍ (doctorat)ថាបណ្ឌិត ដុកទ័រ(docteur) តាមឈ្មោះនៃវិទ្យាសាស្ត្រនោះៗដូចជាវេជ្ជបណ្ឌិត បណ្ឌិតខាងច្បាប់ ...។ ឧ. ព្រះអង្គជាបណ្ឌិតអក្សរសាស្ត្រទី១។	៥
បណ្ឌិត[2]	ន. ជនអ្នកប្រព្រឹត្តល្អ គឺអ្នកកាន់សុចរិត១០ប្រការ ឬជាពិស្តារឬកាន់សុចរិត៤០ប្រការដោយខ្ជាប់ខ្ជួន, អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌។	៥
បណ្ណ	ន. ក្រដាសឬសៀវភៅដែលគេសរសេរឈ្មោះ ឬកត់ត្រាអ្វីផ្សេងៗ ។ ឧ. ខ្ញុំគ្មានបណ្ណសរសើរនឹងគេទេ។	៥
បណ្ណាឃោសនា	ន. សំបុត្រផ្សព្វផ្សាយដំណឹងដោយអន្ទងឬបញ្ចុះបញ្ចូលសាធារណជនឱ្យចូលចិត្តលើវត្ថុណាមួយ ឬមានជំនឿលើសកម្មភាពអ្វីមួយ។ ឧ. ខ្ញុំសរសេរបណ្ណាឃោសនា។	៥
បណ្ណាធនាគារ	ន. បណ្ណ(កាត)ដែលធនាគារពាណិជ្ជចេញឱ្យអតិថិជន ដើម្បីដកដាក់ឬទូទាត់ប្រាក់។	៦
បណ្ណាល័យ	ន. ទីកន្លែងសម្រាប់តម្កល់ទុកសៀវភៅ ក្បួន ច្បាប់ផ្សេងៗ។ ឧ. អ្នកខ្លះទៀតកំពុងអានសៀវភៅនៅបណ្ណាល័យ។ ឧ. យើងនាំគ្នាទៅអានសៀវភៅនៅបណ្ណាល័យ។	២; ៣; ៤
បទ	ន. ១.រឿង ហេតុ ផ្លូវ ដំណើរទំនង។ ឧ. តែគាត់ធឹកជ្រុលហួសបទ នោះនឹងជំពាក់គេហើយ។ ២.លំនាំនៃសំឡេងដែលសូត្រឬច្រៀង។ ឧ. បទចម្រៀង។	៣; ៤
បទបញ្ជា	ន. លិខិតបទដ្ឋានដែលចេញដោយអង្គភាពតាមគន្លងច្បាប់។ ឧ. សុខាគោរពបទបញ្ជារបស់សាលារៀនបានត្រឹមត្រូវ។	៣
បទបញ្ញត្តិ	ន. សេចក្តីហាមប្រាម បម្រាប់ សេចក្តីដែលគេតែងតាំង ឬរៀបចំ។	៦

បទពិសោធ	ន. ចំណេះដឹងដែលបានឆ្លងកាត់ធ្លាប់ធ្វើ, ដំណើរនៃការសាកល្បងជាក់ស្តែង។ ឧ. គាត់ខិតខំដកស្រង់បទពិសោធផ្នែកសំណង់ទំនើបៗ។ ឧ. យើងអាចចែករំលែកចំណេះដឹងនិងបទពិសោធតាមរយៈទូរសព្ទដៃទំនើប។	៣:៤:៥
បន្តក់	ន. សញ្ញាគំនូសបន្តក់មួយ«ៈ»ដាក់លើព្យញ្ជនៈប្រកប«ក ង ច ញ ត ន ប ល ស»សម្រាប់កាត់សព្ទវែងឱ្យទៅជាខ្លី។	៣
បន្តក់	ក. សម្រក់ឱ្យធ្លាក់ចុះ១តំណក់ម្តង ធ្លោងឱ្យធ្លាក់ត្រង់ចំ។ ឧ. អ៊ំបន្តក់ថ្នាំដាក់ភ្នែក។ ឧ. ទាហានបន្តក់ឱ្យចំបន្ទាយខ្មាំង។	៣
បន្តិចបន្តួច	គុ. ដែលតិចតួច យ៉ាងតិចតួច។ ឧ. ម៉ែរៀបផ្លែឈើបន្តិចបន្តួចសិន។	៣
បន្ទោង	ន. ឈ្មោះគ្រឿងអលង្ការដាក់តោងជាមួយខ្សែ-ក សម្រាប់ស្ត្រី។	២
បន្ទប់	ន. ទីកន្លែងមានជញ្ជាំងបាំងបិទសម្រាប់ដេកសម្រាកឬធ្វើការ។ ឧ. ក្នុងបន្ទប់នីមួយៗមានតុ កៅអី ភ្ជារខៀន ...។	៣
បន្ទុក	ន. កិច្ចការធុរៈខុសត្រូវគ្រប់សព្វ, ភារៈដែលផ្ទុក។ ឧ. កូនៗនៅក្នុងបន្ទុករបស់ប៉ាម៉ាក់។ ឧ. ខ្ញុំគោរពពុក ព្រោះគាត់ទទួលបន្ទុកពុំគិតនឿយប្រាណ។	២; ៣
បន្ទោបង់	ក. បញ្ចេញចោល។ ឧ. កុំបន្ទោបង់ក្បែរឬក្នុងប្រភពទឹក។	២
បន្លែ	ន. ស្លឹក ផ្លែ ផ្កា ដើម ឬមើមសម្រាប់ស្ល។ ឧ. បន្លែស្រស់ បន្លែក្រៀម។	៣; ៥
បន្សល់ទុក	ក. ធ្វើឱ្យមាននិងរក្សាទុកឱ្យនៅជាដំណែល។ ឧ. នេះជាល្បែងប្រជាប្រិយដែលបន្សល់ទុកតាំពីដូនតា។	៣
បម្រាម	ន. សេចក្តីហាមប្រាម សំបុត្រហាមប្រាម។ ឧ. នោះជាផ្លាកសញ្ញាបម្រាម«ហាមចូល»។ ⛔	៣
បរទេស	ន. ប្រទេសដទៃ ឬអ្នកប្រទេសក្រៅ។ ឧ. លោកចេះភាសាបរទេស៥ភាសា។	៥
បរម	គុ. ឧត្តម ខ្ពង់ខ្ពស់ ប្រសើរ។ ឧ. បរមក្សត្រ ព្រះបរមរាជវាំង។	៣
បរិក្ខារ	ន. គ្រឿងប្រដាប់, គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់។	៦

បរិបូណ៌	គុ. ដែលមានច្រើន គ្រប់គ្រាន់ សម្បូរ ឆ្អែត។ ឧ. ដោយពុំមានអាវុធបរិបូណ៌ សេនាមឿងម្លូរជីវិតទៅកេណ្ឌពលខ្មោច។	៥
បរិភោគ	កិ. ឬន. ចម្អែតដោយស៊ី ញ៉ាំ ហូប។ ឧ. មុនពេលបរិភោគនំ ចំណី កុមាររូបនេះមិនដែលលាងដៃនឹងសាប៊ូ។ ឧ. សូមអញ្ជើញភ្ញៀវទាំងអស់បរិភោគភោជនាហារ។	៣; ៦
បរិមាណ	ន. ចំនួន ប្រមាណ។ ឧ. ផលស្រូវក្នុងឆ្នាំនេះ ឃើញថាមានបរិមាណលើសពីឆ្នាំមុនច្រើន។	៤
បរិវេណ	ន. ទីធ្លា ទីជិតខាងដែលព័ទ្ធជុំវិញ។ ឧ. សាលារៀននេះមានបរិវេណធំទូលាយ។ ឧ. រាល់ឆ្នាំ គេប្រារព្ធពិធីបុណ្យឯករាជ្យនៅបរិវេណវិមានឯករាជ្យ។	៣; ៥
បរិសុទ្ធ	គុ. ដែលស្អាតឥតសៅហ្មងមោះមែ។ ឧ. នៅពេលអស់ដើមឈើ ខ្យល់នឹងមិនបរិសុទ្ធ។ ឧ. គាត់មានចិត្តបរិសុទ្ធមែន។	៤; ៦
បរិស្ថាន	ន. ទីឋាននិងអ្វីៗដែលនៅជុំវិញខ្លួនទាំងអស់។ ឧ. គាត់គិតថាបើគាត់លក់ គាត់នឹងចូលរួមចំណែកក្នុងការបំផ្លាញបរិស្ថាន។ ឧ. ថ្វីត្បិតផ្ទះខ្ញុំតូច តែមានបរិស្ថានល្អស្រស់បំព្រង។ ឧ. ថ្នាំជក់ប៉ះពាល់មកលើសុខភាព បរិស្ថាន និងសេដ្ឋកិច្ច។	៣; ៥; ៦
បវរ	គុ. ប្រសើរ ថ្លៃថ្លា។ ឧ. ប្រាសាទអង្គរដ៏បវរជារបស់ជូនតាយើង។	៣
បវេសនកាល	ន. ថ្ងៃចូលរៀនដំបូងនៅដើមឆ្នាំសិក្សា។ ឧ. អូ! ថ្ងៃនេះជាថ្ងៃបវេសនកាលផង។	២
បស្ចិម	ន. ទិសខាងលិច។ ឧ. គាត់ចូលចិត្តម្ហូបអាហារតាមបែបបស្ចិមប្រទេស។	៣
ឋាគូ	ន. អាចារ្យសាសនាព្រាហ្មណ៍រស់នៅក្នុងព្រះបរមរាជវាំងជាអ្នកផ្តុំសង្ឃពេលមានពិធីទ្វារទសមាស។ ឧ. ក្រុមឋាគូបានដឹកគោឧសភរាជទៅកាន់ថាសមាស។	៥
ឋាគូ	ន. អាចារ្យសាសនាព្រាហ្មណ៍រស់នៅក្នុងព្រះបរមរាជវាំងជាអ្នកផ្តុំសង្ឃពេលមានពិធីទ្វារទសមាស។	៥
ឋាត	ន. ប្រាក់ចាយពីបុរាណដែលទំនងជាផ្សំដោយមាស។ ឧ. មហាក្សត្រឱ្យរៃអង្គាសមាសឱ្យបានមួយឋាតជាកំហិត។	៦

បាតុភូតធម្មជាតិ	ន. ព្រឹត្តិការណ៍ដែលអាចសង្កេតឃើញ បណ្តាលឡើងឯងៗ ដោយធម្មជាតិ។ ឧ. បាតុភូតធម្មជាតិមានដូចជាផ្លែរះ អាកាសធាតុ អ័ព្ទ ផ្គរលាន់ ព្យុះកំបុតត្បូង ...។	៥
បាយសី	ន. កំណាត់ដើមចេកមានជើងដោតបញ្ឈរ មានរមូរស្លឹកចេកសណ្ឋានម្រាមដៃដោតជាថ្នាក់ៗមាន ៣ថ្នាក់ ៥ថ្នាក់ ៧ថ្នាក់ ៩ថ្នាក់ មានដោតផ្កាលាយចម្រុះ មានដាក់បាយព្រលឹងឬលាជ។	៦
បារម្ភ	កិ. នឹកថប់ជាមុន នឹកព្រួយជាមុន ភ័យខ្លាចមិនដឹងមុខ។ ឧ. ពេទ្យប្រាប់ម្តាយខ្ញុំកុំឱ្យបារម្ភ។ ឧ. អ្នកកុំបារម្ភឱ្យសោះ ការនុះមុខជានឹងសម្រេចជាប្រាកដ។ ន. ឧ. ខ្ញុំមានបារម្ភបន្តិចដែរ ក្រែងតែប្រឡងមិនបានល្អ។	៣;៤;៦
បារាយណ៍ទឹកថ្លា	ន. ឈ្មោះបឹងធំមួយវាលត្រូវស្រឡះស្អាតឆេង ឥតមានស្មៅឬចកត្រែបអ្វីឡើយ មានទឹកថ្លាឈ្វេងជានិច្ច។	៤
បិណ្ឌ	ន. ពិធីធ្វើបុណ្យទានឯវត្ត១៥ថ្ងៃ មានបាយបិណ្ឌពូនជាដុំ រៀបចំម្ហូបអាហារដើម្បីសែនដូនតា...។ ឧ. ខ្ញុំទទួលវេនបិណ្ឌទី២។	២; ៦
បិណ្ឌបាត្រ	ន. អាហារដែលប្រមូលឱ្យជាដុំដាក់បាត្រ, ចង្ហាន់ដាក់រាប់បាត្រ: ឧ. ចង្ហាន់បិណ្ឌបាត្រ។ កិ. ឧ. លោកនិមន្តទៅបិណ្ឌ(បាត្រ)។	៦
បិតា	ន. ឪពុក។ ឧ. ជ័យអស្ចារ្យឡើងគ្រងរាជ្យបន្តពីព្រះបិតា។	៥;៦
បីបាច់	កិ. ថែរក្សាដោយយកចិត្តទុកដាក់។ បីបាច់រក្សា គឺថែរក្សាដោយការចាំបាច់។ ឧ. គាត់មានឪពុកបីបាច់រក្សាតាំងពីតូច។	៦
បុគ្គលិក	ន. ភ្នាក់ងាររាជការឬនិយោជិតតាមស្ថាប័នផ្សេងៗ។ ឧ. នាយកសាលាបានជូនដំណឹងដល់បុគ្គលិកសិក្សារួចហើយ។	៥
បុណ្យ	ន. អំពើល្អ, ពិធីផ្សេងៗដែលប្រារព្ធ ឬ រៀបចំឡើងដើម្បីរម្លឹកដល់ព្រឹត្តិការណ៍ណាមួយ។ ឧ. កម្ពុជាធ្វើបុណ្យសមុទ្រដំបូងនៅឆ្នេរអូរឈើទាល។	៣
បុត្រ	ន. កូន (កូនប្រុស)។ ឧ. គេសរសើរថាជាបុត្រល្អ។ ឧ. បុត្រល្អមានទឹកចិត្តស្មោះសរគោរពមាតាបិតា។ ឧ. ព្រះនាង ឥន្ទ្រទេវី មានរាជបុត្រពីរអង្គ។	៣; ៦
បុព្វ	គុ. មុន ខាងដើម។ ឧ. យើងឃើញមានបុព្វកវីដូចជាបណ្ឌិតជ័យនន្ទដែលល្បីល្បាញខាងតែងកំណាព្យ។	៥

បុព្វការី	ន. ការីពីសម័យខាងដើម។	៥
បុព្វបុរស	ន. ១.បុរសជាខាងដើមវង្ស ២.ពួកញាតិទាំងអស់ដែលទៅកាន់បរលោកហើយ។ ឧ. ពេលគោរពទង់ជាតិ យើងនឹកគុណបុព្វ បុរសជាតិយើង។ ឧ. បុព្វបុរសយើងបានបន្សល់ទុកមរតកអក្សរសិល្ប៍យ៉ាងច្រើន។	៣; ៥; ៦
បុរាណ	គុ. ចាស់ ដែលកើតមានមុន ដែលធ្លាប់មានពីព្រេងនាយ។ ឧ. នៅសារមន្ទីរមានវត្ថុបុរាណ។ ឧ. ពីសម័យបុរាណ វង់ត្រុដិរបស់ជនជាតិសំរែប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅក្រុងអង្គរ។ ន. សម័យមុន។ ឧ. កាលពីបុរាណ ដូនតាជិះតែរទេះ។	២;៣;៤;៦
បុល	កិ. ខ្ចីឬបណ្តាក់ដោយត្រូវសងទ្វេដង។ ឧ. ពូសុខមិនបាច់ខ្ចីបុលប្រាក់គេ ព្រោះបានចំណូលបន្ថែមពីការចិញ្ចឹមត្រី។	៣
បូជា	កិ. ១.ដុត រំលាយ(សព)។ ឧ. គេបូជាសពគាត់នៅឯវត្ត។ ២. ថ្វាយ ជូន។ ឧ. សូមបូជាកម្រងផ្កានេះចំពោះព្រះពុទ្ធ។	១;៥;៦
បូព៌ា	ន. ទិសខាងកើត។ ឧ. ភូមិវត្តបូព៌ាស្ថិតនៅខេត្តសៀមរាប។	៣
បូល	កិ. ផ្សងឱ្យដឹងហេតុ ដោយមានវត្ថុអ្វីមួយជាគ្រឿងសម្គាល់ឬស្នង់ដោយព័ស្តុតាងតាមចំណាំនិងជំនឿ។ ឧ. បើបូលរកហេតុនានាពុំត្រូវ ជួនកាលគេបូលរកមធ្យោបាយញុះញង់។	
ប៉ូលិស	ន. ភ្នាក់ងាររក្សាការពារនូវរបៀបរៀបរយសាធារណៈ។ ឧ. ប៉ូលិសចរាចរណ៍ក៏មកដល់។	៣; ៥
ប៉ើង	កិ. ហើបឡើង ខ្ចាត់អណ្តែត ដោយខ្យល់បក់ខ្លាំង...។ ឧ. ក្រដាសប៉ើងធ្លាក់ទៅក្រោមតុ។	៣
បេតិកភណ្ឌ	ន. ទ្រព្យសម្បត្តិឬកេរមរតកដែលមានជាប់តមកពីខាងឪពុក។	៥
បេតិកភណ្ឌពិភពលោក	ន. ទ្រព្យសម្បត្តិពិភពលោក។ ឧ. ប្រាសាទអង្គរវត្តបានជាបេតិកភណ្ឌពិភពលោកហើយ។	៥

ប៉ែន	ន. ១.ប្រដាប់ធ្វើដោយដែកមានរន្ធតូចសម្រាប់ហូតលួស ២. ប្រដាប់ធ្វើដោយស្ពាន់ឬទង់ដែងមានរន្ធតូចៗ សម្រាប់រោយម្សៅឱ្យកើតជាសរសៃនំបញ្ចុក។	១
ប្តេជ្ញា	កិ. មត់គ្នា សន្យាគ្នា។ ឧ. សុភក្ត្រប្តេជ្ញាចិត្តខិតខំរៀនសូត្រនិងចៀសឱ្យផុតពីគ្រឿងញៀន។	៣
ប្រការ	ន. វិធី បែប ប្រភេទ។ ឧ. ឆ្កួតបីប្រការគឺឆ្កួតនឹងស្រីស្រានិងល្បែង។	៥; ៦
ប្រគេន	កិ. លើកឱ្យដល់ដៃព្រះសង្ឃ។	៦
ប្រជាខេមរា	ន. ប្រជាជនខ្មែរ។ឧ. ទាំងអស់នេះជាសម្បត្តិប្រជាខេមរាយើង។	៣
ប្រជាជន	ន. មនុស្សម្នានៅក្នុងសមូហភាព, ពួកជនចំណុះប្រទេស។ ឧ. ប្រជាជនកើតជំងឺរាក ព្រោះកង្វះទឹកស្អាតនិងអនាម័យ។	៣
ប្រជាជាតិ	ន. ជាតិមនុស្សដែលមានវង្សត្រកូលនិងភាសារួមគ្នា។ ឧ. ខ្មែរជាប្រជាជាតិដ៏ចំណាស់មួយក្នុងប្រវត្តិសាស្ត្រ។	៣
ប្រជាប្រិយ	គុ. ដែលប្រជាជននិយមចូលចិត្ត។ ឧ. បោះអង្គញ់ជាល្បែងប្រជាប្រិយខ្មែរ។ ឧ. គេឮសូរចម្រៀងប្រជាប្រិយ។ ឧ. នៅតាមវត្តនិងផ្ទះ គេនាំគ្នាលេងល្បែងប្រជាប្រិយ។	២;៣;៤
ប្រជាពលរដ្ឋ	ន. ពលរដ្ឋគឺប្រជាជន ឬប្រជាជនដែលជាពលរដ្ឋ។	៤
ប្រដៅ	កិ. ទូន្មាន ឱ្យឱវាទ ស្តីថា ក្រើនរំលឹក បង្ហឹក។ ឧ. ឪពុកម្តាយប្រដៅកូន, គ្រូប្រដៅសិស្ស។	
ប្រឌិត	កិ. ធ្វើអោយមានជារូបរាង។ ឧ. យើងត្រូវចេះច្នៃប្រឌិតយកទឹកដែលប្រើរួចទៅស្រោចដំណាំជាដើម។	៤
ប្រណីត	គុ. ដែលឧត្តម ថ្លៃថ្លា ស្រស់បញ្ជង់ ឆើតឆាយ។ ឧ. ឆ្នេរអូរឈើទាលជាកន្លែងដ៏ល្អប្រណីតសម្រាប់បុណ្យសមុទ្រ។ ឧ. ប្រាសាទព្រះវិហារមានក្បូរក្បាច់រចនាដ៏ប្រណីត។	៣; ៥
ប្រតិបត្តិ	ន. ការប្រព្រឹត្តិ ការធ្វើតាម។ កិ. ប្រព្រឹត្ត អនុវត្ត: ឧ. ឈ្មោះនុះគ្រាន់តែចេះធម៌ចាំច្បាស់ ប៉ុន្តែមិនប្រតិបត្តិតាម។	៦

ប្រទក្សិណ	គុ.កិ. ដើរឬហែជុំវិញបុគ្គលឬវត្ថុអ្វីៗនៅខាងស្តាំដៃដោយសេចក្តីគោរពឬស្រឡាញ់។ ឧ. ក្បួនហែនាគហែប្រទក្សិណព្រះវិហារបីជុំ។	៦
ប្រទាន	កិ. ឱ្យ ប្រគល់ឱ្យ។ ឧ. ព្រះចៅសៀមបានប្រទានងារឧទេន "ជ័យអស្ចារ្យ"។	៥
ប្រទូសរ៉ាយ	កិ. ប្រទូស បៀតបៀន រករឿងធ្វើឱ្យវិនាស។ ឧ. បើមានសត្រូវប្រទូសរ៉ាយ ខ្មែរម្តុំរជីវិតធ្វើសឹកតទល់វិញ។	៣
ប្រទេស	ន. ស្រុក ដែន, ទឹកដីនៃប្រជាជាតិមួយ។ ឧ. ខ្ញុំនៅប្រទេសគេ។	៣
ប្រប	ធ. ទៀប ជិត ក្បែរ។ ឧ. ផ្ទះគាត់សង់ប្របមាត់ស្ទឹង។	៣
ប្រផ្នូល	ន. ការបូល ឬហេតុដែលឱ្យបានដឹងជាមុន។ ឧ. គេចាត់ទុកជាប្រផ្នូលទាយថា ពោតទទួលបានផលល្អ។	៥; ៦
ប្រពលវប្បកម្ម	ន. ការធ្វើស្រែដែលមិនចាំបាច់រង់ចាំទឹកភ្លៀងធ្លាក់មក ទើបអាចធ្វើស្រែបាននោះទេ គឺមានប្រព័ន្ធប្រឡាយទឹកគ្រប់គ្រាន់ដែលមានទឹកជានិច្ចសម្រាប់ធ្វើស្រែគ្រប់រដូវ។ ឧ. ប្រជាកសិករត្រូវធ្វើស្រែវប្រពលវប្បកម្ម។	៤
ប្រពៃ	គុ. ល្អប្រសើរ ល្អកន្លង។ ឧ. ទឹកចិត្តដ៏ប្រពៃ។ ឧ. តំបន់ខ្ពង់រាបមានដំណាំច្រើនក្រៃ ផលាក៏ប្រពៃ។	២; ៣
ប្រពៃណី	ន. ទំនៀមទម្លាប់ដែលប្រជាជនក្នុងប្រទេសនិយមអនុវត្ត។ ឧ. តាមប្រពៃណីចូលឆ្នាំ ខ្មែរនិយមលេងល្បែងប្រជាប្រិយ។	៣; ៦
ប្រព្រឹត្ត	កិ. ធ្វើតាម។ ឧ. កុំប្រព្រឹត្តទុច្ចរិត។	៤
ប្រព័ន្ធ	ន. បណ្តាញប្រទាក់គ្នានិងអាចដំណើរការជាមួយគ្នា។ ឧ. ទីនោះមានការជួសជុលផ្លូវឬប្រព័ន្ធលូ។	៣
ប្រមាថ	កិ. បៀតបៀន មើលងាយ។	៦
ប្រមឹក	គុ. ដែលញៀនឬជាប់សុរា ដែលស្រវឹងជាប្រចាំ។ ឧ. អ្នកប្រមឹកតែងប្រមូលគ្នាផឹកមិនសូវប្រកាន់ចាស់ក្មេង។	៣
ប្រមូលអារម្មណ៍	កិ. ប្រមូលគំនិត ធ្វើឱ្យមូលចិត្ត។	៣
ប្រយុទ្ធ	កិ. ច្បាំងគ្នាតស៊ូគ្នាទៅវិញទៅមក។	២

ប្រយោជន៍	ន. អ្វីៗដែលកើតការ ឬគេត្រូវការ, ផលដែលសម្រេចអំពីការប្រកប។ ឧ. គោជាសត្វដ៏មានប្រយោជន៍។ ឧ. កូនត្រូវខិតរៀនខំសូត្រ កុំនៅទំនេរ ទើបមានប្រយោជន៍។	២; ៣
ប្រយ័ត្ន	កិ. ប្រុងដោយមិនធ្វេសប្រហែស។ ឧ. សូមប្រុងប្រយ័ត្នសាច់មាន់ទាដែលយកមកធ្វើម្ហូប។	២
ប្រលោមលោក	ន. រឿងប្រលោមចិត្តមនុស្សលោក។ ឧ. រឿងប្រលោមលោកកាកីនិងទុំទាវ សរសេរជាពាក្យកាព្យ។	៥
ប្រល័យ[១]	ន. សេចក្តីវិនាស សេចក្តីវិនាសជីវិត(មរណៈ)។ ឧ. ខ្ញុំនិងម្តាយបានទៅទស្សនាមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។	៥
ប្រល័យ[២]	កិ. សម្លាប់។ ឧ. ប្រល័យជន្ម គឺសម្លាប់ជីវិត។	៥
ប្រល័យពូជសាសន៍	កិ. កាប់សម្លាប់ដោយចេតនានិងជាប្រព័ន្ធនូវក្រុមមនុស្សទាំងមូល ជាពិសេសប្រជាជាតិ ពូជសាសន៍ ឬក្រុមសាសនាណាមួយ។ ឧ. របបនេះផុងខ្លួនប្រល័យពូជសាសន៍ឯង។	៥
ប្រវត្តិសាស្ត្រ	ន. គម្ពីរឬក្បួននិយាយអំពីពង្សាវតារប្រទេស។ ឧ. យើងអាចរៀនបានប្រវត្តិសាស្ត្រមួយចំនួនពីសារមន្ទីរ។ ឧ. រឿងខ្លីនេះនិយាយទាក់ទងនឹងប្រវត្តិសាស្ត្រ។	៣; ៥
ប្រសប់	គុ. ប៉ិន ឆ្នឹក។	៤
ប្រសាសន៍	ន. សម្តី ពាក្យ ពាក្យផ្តាំផ្ញើ។ ឧ. កុមារគុណតបទៅនឹងប្រសាសន៍អ្នកគ្រូថា គេចូលចិត្តការងារគំនូរណាស់។ ឧ. កូនមកជិត ចាំស្តាប់គាត់មានប្រសាសន៍។ ឧ. គាត់មានប្រសាសន៍ថា ខ្ញុំឧស្សាហ៍ដូចជីតាខ្ញុំដែរ។	២; ៤; ៦
ប្រសូត	កិ. សម្រាលកូន ឆ្លងទន្លេ។	៦
ប្រសើរ	គុ. ថ្លៃថ្លា ល្អកន្លង ដែលគួរសរសើរ។ ឧ. ពេលមកដល់ផ្ទះ កូនខំរៀនបន្ត នោះទើប្រសើរ។	៣
ប្រស្នា	ន. ចំណោទ ពាក្យឬសេចក្តីដែលមានអាថ៌កំបាំង។ ឧ. ដង្កូវដាក់ប្រស្នាឱ្យក្អែកដោះស្រាយ។ ឧ. អ្នកទាំងបីបានអានប្រស្នាចប់ ក៏នាំគ្នាដោះស្រាយ។	២; ៤

ប្រហារ	កិ. វាយ កាប់ ចាក់ សម្លាប់។ ឧ. ប្រហារជីវិត ប្រហារដោយដំបង។	៤
ប្រឡាយ	ន. ផ្លូវទឹកតូច គីជ្រលងតូចដែលគេជីកឬទឹកហូរច្រោះ។ ឧ. ស្រុកយើងមានប្រឡាយទឹកដែរ តែត្រូវការច្រើនទៀត។	៣
ប្រាកដ	គុ.កិ. ពិត ជាក់ច្បាស់។ ឧ. គាត់ចេះប្រាកដ។	៣
ប្រាកដជា	កិ.ជំ. ច្បាស់ជា មុខជា ពិតជា។ ឧ. គាត់ប្រាកដជាមានការអ្វីហើយ។ ឧ. កម្ពុជាយើងប្រាកដជាសម្បូរប្រាសាទបុរាណ។	២
ប្រាក់កាស	ន. លុយកាក់ សាច់ប្រាក់សម្រាប់ចាយវាយ។ ឧ. សុភីក៏ចេះសន្សំសំចៃប្រាក់កាសនិងរបស់របរតាមសំណាង។	៣
ប្រាក់ចំណូល	ន. ប្រាក់ដែលទទួលបាន ដែលចូលថែមមក។ ឧ. ដើម្បីបង្កើនប្រាក់ចំណូលក្រៅពីរបរធ្វើស្រែ ពូសុខចិញ្ចឹមគ្រីថែមទៀត។	៣
ប្រាជ្ញា	ន. បញ្ញា គឺការយល់ដឹងជាក់ច្បាស់តាមរយៈបទពិសោធនិងចំណេះដឹង។ ឧ. ខ្លាចាញ់ប្រាជ្ញាមនុស្ស។	២:៣:៤
ប្រាថ្នា	កិ. ប៉ង តាំងបំណង តាំងសំណូមឱ្យបានសម្រេចដូចបំណង។ ឧ. លោកបងប្រាថ្នាឱ្យបានត្រាស់ដឹង, មីងប្រាថ្នាឱ្យបានកូនស្រី, ខ្ញុំប្រាថ្នាសូមបានសេចក្តីសុខ។ ន. ឧ. មានប្រាថ្នា, តាមប្រាថ្នា, បានសម្រេចដូចប្រាថ្នា។	៦
ប្រារព្ធ	កិ. ធ្វើ តាំងផ្តើម ផ្តួចផ្តើម។ ឧ. ឆ្នាំនេះ បុណ្យច្រត់ព្រះនង្គ័លនឹងប្រារព្ធឡើងនៅថ្ងៃទី១៥ ខែឧសភា។ ឧ. រង់ត្រុដិរបស់ជនជាតិសំរែប្រារព្ធឡើងជារៀងរាល់ឆ្នាំ។	៥:៦
ប្រឹងប្រែង	កិ. ប្រឹងដោយស្រវាស្រទេញ ប្រឹងពេញទំហឹង។ ឧ. គ្រាន់តែរៀន...បានចេះខ្លះដឹងខ្លះ តែ*សិស្សប្រឹងប្រែងរៀន ទើបកើតមានចំណេះវិជ្ជា*។	៣
ប្រឹថពី	ន. ផែនដី ផ្ទៃដីទាំងមូល។ ឧ. សង្គ្រាមបង្ហូរឈាមស្រក់លើប្រឹថពី...។	៣
ប្រុង	កិ. ១.បម្រុងទុក ប្រយ័ត្នទុកមុន។ ឧ. ប្រុងខ្លួន ប្រុងស្មារតី។ ២.ផ្គងបំណងទុកមុន។ ឧ. ប្រុងនឹងទៅ ប្រុងនឹងឱ្យ។ ៣.ផ្ទុផ្គង ផ្សំ។ ឧ. ប្រុងគ្រឿងផ្ទះ។	៥

ប្រុងប្រយ័ត្ន	កិ. ប្រយ័ត្នទុកមុន ប្រុងដោយមិនធ្វេសប្រហែស។ ឧ. យើងត្រូវប្រុងប្រយ័ត្នជានិច្ចនិងគោរពច្បាប់ចរាចរណ៍។	៣
ប្រៃសណីយ៍	ន. ក្រុមរាជការទទួលបន្ទុកខាងការបញ្ជូននិងការដឹកនាំសំបុត្រស្មាម...ផ្សេងៗ។ ឧ. ឥឡូវ ប្រៃសណីយ៍ពិបាកប្រកួតជាមួយឯកជនហើយ។	៣
បំណង	ន. សេចក្តីដែលប៉ង គោលដៅឬផែនការ។ ឧ. បំណងខ្ញុំគឺចង់បានផ្ទះប្របមាត់ស្ទឹង។	៣
បំណិនជីវិត	ន. ជំនាញដែលចាំបាច់ ឬចង់បានសម្រាប់ការចូលរួមពេញលេញក្នុងជីវិតប្រចាំថ្ងៃ។ ឧ. គេអាចស្វែងយល់រៀនបំណិនជីវិតមួយចំនួនតាមយូធូប។	៣
បំណាំ	ន. បណ្តោយមិនស្តីថា រំឭកដាស់តឿន ជួយខ្នះខ្នែង ឬជួយធ្វើរួចចាំតែមើលពុត មើលមារយាទ។ ឧ. គាត់មើលបំណាំគ្នា។	៤
បំពាន	គុ.កិ. ពានពារលើ រំលោភលើ ជាន់រំលងការពិត។ ឧ. អ្នកប្រមឹកផឹកអួតបំពាន ទោះលុយអត់មាន ក៏ជំពាក់គេ។ កិ. ឧ.ចេះច្បាប់ហើយបំពាន ព្រោះគ្មានសច្ចធម៌និងសីលធម៌។	៣
បំភ្លៃ	កិ. បញ្ចូលថែម, លស់រំលងខ្លះមិនរៀបរៀងតាមលំដាប់។ ឧ. ខ្ញុំនឹងសរសេរតែព័ត៌មានមិនបំភ្លៃការពិត។	៥
ប័ណ្ណធនាគារ	ន. លិខិតឬប័ណ្ណ(កាត)សម្រាប់ម្ចាស់កម្មសិទ្ធិដែលមានរបស់ដាក់ក្នុងធនាគារ។	៦
ផ	**ផ**	
ផល	ន. ១.ផ្លែ ចំណេញ សេចក្តីចម្រើន។ ឧ. ឆ្នាំនេះគ្មានបានផលទេ។ ២.លទ្ធផលដែលកើតមានឡើងអាស្រ័យដោយហេតុ។ ឧ. បូណាផឹកទឹកឆៅ(ជាហេតុ) ទើបវាឈឺពោះ(ជាផល)។	២; ៣
ផលប្រយោជន៍	ន. ប្រយោជន៍ដែលសម្រេចជាផលពេញលេញ។ ឧ. ផលប្រយោជន៍នៃបច្ចេកវិទ្យាព័ត៌មាន គឺផ្តល់និងទទួលព័ត៌មានថ្មីៗដើម្បីរួមចំណែកអភិវឌ្ឍសមត្ថភាព។	៣
ផលា	ន. ផលទាំងឡាយ។ ឧ. ដំណាំ ស្រែស្រូវ និងចម្ការផ្តល់ផលាប្រពៃ។	៣
ផលិត	ន. ការបង្កើត។ ឧ. ស្រុកយើងអាចផលិតស្បែកជើង។	៤

ផលិតកម្ម	ន. ប្រតិបត្តិការផលិតទំនិញ។ ឧ.សិប្បកម្មជាផលិតកម្មធុនតូច។	៣
ផលិតផល	ន. ផលឬទំនិញដែលកើតឡើងមកពីរបរកសិកម្មនិងឧស្សាហកម្មជាដើម។ ឧ. ប្រជាជនខិតខំកែច្នៃគុណភាពផលិតផល។	៥
ផាមួង	ន. ឈ្មោះសំពត់សូត្រនៅកម្ពុជរដ្ឋមួយប្រភេទមានពណ៌លាតផ្សេងៗសម្រាប់ស្លៀកក្នុងពិធីប្រពៃណីផ្សេងៗ។ ឧ. ពលរដ្ឋនៅទីនោះស្ទាត់ជំនាញត្បាញហូលផាមួង។	៥
ផាល	ន. ១.ដែករាងជម មុខមុតសម្រាប់ដាក់ប្រហកត្រង់ពន្លូញចុងផ្ទៀងនង្គ័ល ឬហៅផ្លែនង្គ័លឬត្រាក់ទ័រសម្រាប់ភ្ជួរដី។ ឧ. សព្វថ្ងៃ ប្រហែលមានអ្នកប្រើប្រាស់ផាលនង្គ័លទៅភ្ជួរដីតិចបំផុត។ ២.អវយវៈដែលក្លាយជារោគមានសណ្ឋានស្រដៀងនឹងផាល នៅត្រង់ចុងឆ្អឹងជំនីរមនុស្ស។ ឧ. ចុកផាល។	១
ផូរផង់	គុ. ស្រស់ត្រចង់ ប្រផូរ បំព្រង។ ឧ. យក្សឡោមជាបឹងមួយមានសម្រស់ផូរផង់។	៣
ផៃ	ន. រានឬក្បួនបណ្តែតទឹក សម្រាប់អែបនាវាឱ្យងាយចុះឡើង។	២
ផ្កាភ្ញី	ន. ផ្កាកម្រង និងផ្ការាយផ្សេងៗ។	២
ផ្គត់ផ្គង់	កិ. ទំនុកបម្រុងមិនឱ្យខ្វះខាត រៀបបម្រុងទុក។ ឧ. ពួកគាត់ជួយផ្គត់ផ្គង់សៀងសម្រាប់កងទ័ព។	៤
ផ្គាប់ផ្គុន	កិ. ខំផ្គាប់ដោយយកចិត្តទុកដាក់ មិនឱ្យឃ្នើសចិត្តឬទាស់ចិត្ត។	២
ផ្ចិតផ្ចង់	កិ. យកចិត្តទុកដាក់ ប្រិតប្រៀន។ ឧ. យើងខំប្រឹងផ្ចិតផ្ចង់សរសេរឱ្យបានត្រឹមត្រូវល្អ	២
ផ្តេសផ្តាស	គុ.កិ. ខុសផ្លូវខុសគន្លង ខុសរបៀប ខ្ជីខ្ជា។ ឧ. សុខាណែនាំមិត្តកុំឱ្យដើរលេងផ្តេសផ្តាស។	៣
ផ្តៅ	ន. ឈ្មោះវល្លិដើមរឹងមួយប្រភេទមានបន្លានៅស្រទប ជាង ស្លឹក (ទីទៃពីរពាក់)។	៥
ផ្តាំ	កិ. ផ្ញើពាក្យសម្តីទុកឱ្យអ្នកទទួលស្តាប់ចងចាំហើយធ្វើតាម។ ឧ. ដូនតាផ្តាំឱ្យចងចាំជាក្បួនតម្រា។	៣
ផ្តាសាយ	ន. ឈ្មោះរោគមួយប្រភេទមានអាការបណ្តាលឱ្យកណ្តាស់ ឱ្យហូរហៀរទឹកសម្បារ។	២

ផ្តែផ្តាំ	កិ. ផ្តាំហើយផ្តាំទៀត។	២
ផ្ទៃ	ន. ១.ពោះ៖ ឧ. ហល់ផ្ទៃ។ ២.ផ្ទាំង៖ ឧ. ផ្ទៃសំពត់ ផ្ទៃពិតាន ផ្ទៃផែនដី។	២
ផ្ទះសម្បែង	ន. ផ្ទះធម្មតា ផ្ទះសាមញ្ញ ផ្ទះតូច ផ្ទះធំនិងផ្ទះរាយរង។ ឧ. ទឹកជំនន់ក៏បានធ្វើឱ្យខូចផ្ទះសម្បែងជាច្រើន។	៣
ផ្លាក	ន. ប្រដាប់ធ្វើពីបន្ទះឈើ លោហៈ ឬក្រដាសរឹងសម្រាប់ធ្វើជាសញ្ញាសម្គាល់ ធ្វើជាយីហោជាដើម។ ឧ. ពូសុខធ្វើផ្លាកយីហោថ្មី។	៦
ផ្លាកសញ្ញា	ន. សន្លឹកធ្វើអំពីលោហៈ...ឬឈើសំប៉ែត តូចជាផ្ទាំង សម្រាប់សម្គាល់កន្លែង លេខរថយន្តជាដើម។ ឧ. 🚸 នេះជាផ្លាកសញ្ញាកុមារដឹកដៃគ្នា មានន័យថាកន្លែងនោះមានកុមារឆ្លងកាត់ញឹកញាប់។	៣
ផ្សព្វផ្សាយ	កិ. ផ្សាយឱ្យសព្វឱ្យបានដឹងទូលំទូលាយ។ ឧ. បុណ្យនេះក៏ដើម្បីផ្សព្វផ្សាយតំបន់ទេសចរណ៍។ ឧ. តោះ នាំគ្នាផ្សព្វផ្សាយផលិតផលជាតិតាមដែលអាច។	៣; ៥
ផ្សារ[1]	កិ. ភ្ជាប់ភ្ជិតដោយទឹកបន្សារ។ ឧ. ពូដាជាជាងផ្សារដែក។	៣
ផ្សារ[2]	ន. ទីប្រជុំលក់ទិញរបស់ផ្សេងៗ។ ឧ.ម្តាយសុភីលក់នៅឯផ្សារ។	៣
ផ្សំផ្គុំ	កិ. ផ្សំឱ្យបានគ្នាជាប្តីប្រពន្ធ។	២
ព	**ព**	
ពង្ស	ន. ១.វង្ស ត្រកូល ពូជ អម្បរ។ ឧ. ក្មួយជាកូនមានពូជពង្ស។ ២.សន្ទតហៅឆ្នាំកំណើតមនុស្សតម្រូវនឹងពូជពង្សរបស់ទេព្តា។ ឧ. គេថាឆ្នាំជូត រោង មមី និងមមែជាពង្សទេព្តា។	៦
ពណ៌នា	កិ. អធិប្បាយសេចក្តី ពោលរៀបរាប់។ ឧ. អត្ថបទនេះពណ៌នាពីម្តាយ។ ឧ. ចូរម្នុនពណ៌នាអំពីកសិកម្មស្រុកយើង។	២; ៣; ៤
ពណ្ណរាយ	គុ. ដែលភ្លឺត្រចះត្រចង់ ដែលភ្លឺថ្លារុងរឿង។ ឧ. វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន។	៣
ពន្យារ	កិ. ធ្វើឱ្យយារ ធ្វើឱ្យយឺតយូរ។	២
ពន្លឺក	គុ. ដែលគួរភ្លឹកគួរស្បើម។ ឧ. ភ័យពន្លឺក។	៤

ពន្លះ	កិ. អារលះកាត់ឱ្យដាច់ចេញដោយឡែកពីគ្នា គឺអារលះស្បែកចេញពីសាច់ ឬយកសាច់ចេញពីឆ្អឹង។ ឧ. សីចេះពន្លះស្បែកនិងពន្លះសាច់លឿន។	៦
ពន់ប្រមាណ	គុ. ហួសប្រមាណ។	៦
ពពិល	ន. ប្រដាប់ធ្វើដោយលោហជាតិ មានសណ្ឋានស្រដៀងនឹងស្លឹកពោធិ៍ សម្រាប់បិទទៀន អុជកាន់បន្តគ្នា បង្វិលបក់ផ្សែងចូលជុំវិញមនុស្ស ឬរបស់អ្វីដើម្បីឱ្យកើតស្រីសួស្តី។	៦
ពលកម្ម	ន. ការងារដែលធ្វើដោយកម្លាំង(កាយ)។ ឧ. ពួកគាត់ប្រើកម្លាំងពលកម្មសុទ្ធសាធ។	៦
ពលរដ្ឋ	ន. ប្រជាជនប្រុសស្រីដែលជាកម្លាំងរបស់ប្រទេស។ ឧ. ការមានសុជីវធម៌ទើបក្លាយជាពលរដ្ឋក្នុងសង្គម។	៣
ពលសេនា	ន. ពួកទាហាន ពួកពល កងទ័ព។ ឧ. ពលសេនាទាំងនោះភ័យស្លន់ស្លោរត់អស់។	២
ពលិកម្ម	ន. ការលះបង់។ ឧ. លោកបានធ្វើពលិកម្មយ៉ាងធំធេង។	៥
ពាណិជ្ជកម្ម	ន. ការលក់ដូរ របរលក់ដូរ។ ឧ. សារព័ត៌មាននេះមានការផ្សាយពាណិជ្ជកម្មច្រើន។	៥
ពានា	កិ. យកសំពត់គ្របដណ្តប់ព័ទ្ធឆៀងស្មាម្ខាង។	៦
ពាយ័ព្យ	ន. ខាងលិចឆៀងជើង។ ឧ. ខេត្តសៀមរាបស្ថិតនៅទិសពាយ័ព្យ។	៣
ពាល	គុ. ល្ងង់ខ្លៅ ទំនើង អាក្រក់ កាចសាហាវ។ ឧ. អ្នកនោះជាក្មេងពាល បើនៅតែសេពគប់ដោយមិនប្រយ័ត្ននឹងនាំអន្តរាយ។	១
ពាលា	គុ. អាក្រក់ ថោកទាប ដែលនាំអន្តរាយ។ ឧ. បើឆ្កែតទាំងបី ឆ្កែតស្រាឆ្កែតស្រី ឆ្កែតល្បែងពាលា នាំឱ្យវិនាស ឬឈ្លោះទាស់គ្នា រងទុក្ខវេទនា ក្នុងក្រុមគ្រួសារ។	៥; ៦
ពាហនៈ	ន. គ្រឿងដឹកនាំ យាន ជំនិះ។ ឧ. អ្នកភូមិក៏បានជញ្ជូនសត្វពាហនៈទៅទីទួលសុវត្ថិភាព។	៣
ពិការ	គុ. ដែលខូចអវយវៈណាមួយប្រើការមិនកើត។ ឧ. យើងគួរប្រើសម្តីគួរសមរួសរាយចំពោះចាស់ជរានិងអ្នកពិការ។	៣

ពិចារណា	កិ. ត្រិះរិះ រំពឹង គិតម៉ត់ចត់។ ឧ. សម្តីនេះធ្វើឱ្យព្រានពិចារណា។ ឧ. ឯងពិចារណាយូរម្ល៉េះ។	២; ៦
ពិណ	ន. ប្រភេទនៃចាប៉ី។ ឧ. លោកគ្រូមិនចេះដេញពិណទេ។	២
ពិធីបុណ្យ	ន. ការតាំងផ្តើមពិធី ជាទូទៅជាការរំលឹកតាមបែបសាសនា សាធារណៈ ឬខួបណាមួយ។ ឧ. ពួកគាត់ធ្វើពិធីរាប់បាត្រ បួងសួងសុំសម្បត្តិភោគផល សុំសុខ និងស្តាប់ទេសនា។	៣
ពិនិត្យ	កិ. ពិចារណា សង្កេតមើលដោយល្អិតល្អន់។ ឧ. លោកគ្រូពិនិត្យសិន។	៦
ពិភពលោក	ន. សកលលោកទាំងមូលជាឋានរស់នៅរបស់មនុស្សសត្វទាំងពួង។	២
ពិភាក្សា	កិ. ជជែក ពិគ្រោះគ្នា ប្រឹក្សាគ្នា។	៦
ពិសា	កិ. (ពាក្យគួរសម)ហូប បរិភោគ ស៊ី។	៦
ពិសោធ	កិ. ល្បងមើល ពិនិត្យ ឬសាកមើលឱ្យឃើញពិត។ ឧ. ចាំពិសោធមើលសិន, ត្រូវពិសោធឱ្យឃើញពិត។	៥
ពិសោធន៍	ន. ការល្បងមើល ដំណើរពិនិត្យឬសាកមើលឱ្យឃើញពិត។ ឧ. គ្រូពេទ្យមួយក្រុមអាចយកទឹកអណ្តូងមកធ្វើពិសោធន៍។	៥
ពុត	ន. កិច្ចកលមាយា បង្វែងដំណើរឱ្យឃ្លាតចាកសេចក្តីពិត។ ឧ. មានពុត ធ្វើពុត។	៦
ពុទ្ធសករាជ	ន. ចំនួនថ្ងៃខែឆ្នាំ រាប់តាំងពីក្រោយថ្ងៃដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វានទៅបានមួយថ្ងៃកន្លងមក។ ឧ. ព.ស.២៤២៧ ជាឆ្នាំដែលសម្តេចសង្ឃរាជ ជួនណាត ប្រសូត។	៥; ៦
ពុទ្ធសាសនា	ន. ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ឧ. យើងគួរធ្វើតាមពុទ្ធ[5] សាសនាឱ្យបានច្រើន ទើបចិត្តបានសុខ មិនច្របូកច្របល់។	៣
ពុម្ព	ន. រូបតំណាង សំណាក គំរូ។ ឧ. ពុម្ពអក្សរនេះស្អាតណាស់។	២

[5] មានអដ្ឋង្គិកមគ្គ ជាផ្លូវដែលប្រកបដោយអង្គប្រាំបីដែលជាផ្លូវកណ្តាល ១.ការមានទស្សនៈត្រូវ ២.ការគិតត្រូវ ៣.ការនិយាយត្រូវ ៤.ការធ្វើអំពើត្រូវ ៥.ការចិញ្ចឹមជីវិតត្រូវ ៦.ការព្យាយាមត្រូវ ៧.ការមានសតិត្រូវ ៨.ការធ្វើឫការតាំងចិត្តត្រូវ, ដោយសង្ខេបគឺសីល សមាធិ និងបញ្ញា ជាផ្លូវប្រតិបត្តិដើម្បីរំដោះខ្លួនឱ្យចេញផុតពីសេចក្តីទុក្ខដែលពុទ្ធបរិស័ទយកជាមាគ៌ាជីវិត។

ពុល	គុ. ដែលមានពិសអាចបណ្តាលឱ្យរង៉ាប់រងើ ក្អួតចង្អោរ ឬធ្វើទុក្ខខ្លាំងដល់ឈឺស្លាប់ក៏មាន។ ឧ. ហាត់ប្រាណអាចបញ្ចេញញើសបញ្ចេញជាតិពុល។	៣
ពួកម៉ាក	ន. គូកន សម្លាញ់ មិត្តភក្តិ។ ឧ. សុខាជាពួកម៉ាកដ៏ល្អ។	៣
ពេចន៍[6]	ន. វចនៈ ពាក្យ សម្តី។ ឧ. ពាក្យពេចន៍នេះពីរោះ។ ឧ. កូនត្រូវចេះរៀបពាក្យពេចន៍និយាយឱ្យពីរោះពិសា។	៤; ៦
ពេជ្រ	ន. ត្បូងពិសេសមានសាច់រឹងខ្លាំងនិងមានពន្លឺចាំងឆ្ទុះព្រោតៗ។ ឧ. ភ្នែកឆ្មាមានពន្លឺភ្លឺថ្លាដូចគ្រាប់ពេជ្រ។	៣
ពោធិ៍សាត់	ន. ១.ឈ្មោះខេត្តមួយនៅខាងកើតខេត្តបាត់ដំបង។ ឧ. ពូសុខចង់ទៅលេងខេត្តពោធិ៍សាត់។ ២.ឈ្មោះក្រូចមួយប្រភេទ។ ឧ. ម៉ាក់ទិញក្រូចពោធិ៍សាត់។	៣
ព្យាបាល	កិ. ថែទាំឱ្យបានធូរស្រាកស្រាលជាពីជំងឺ។ ឧ. អ្នកគ្រូកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាព។	៣; ៦
ព្យាម	ន. ប្រវែងមួយកាងដៃស្មើនឹងបួនហត្ថ។ ឧ. ដីបណ្តោយ៤០ព្យាម ទទឹង២០ព្យាម១ហត្ថ១ចំអាម៤ផ្ទាប់។	១
ព្យាយាម	កិ. ខំប្រឹង ប្រឹងប្រែង សង្វាត។ ឧ. សុខាព្យាយាមក្នុងការសិក្សា។	៣
ព្យួរ	កិ. ពាក់ ថ្កក់ ចងបន្តោក បន្តោង។ ឧ. ពូសែមមកពីភ្នំរស្រែក៏ដោះអាវទៅព្យួរនឹងសសរផ្ទះ។	៣
ព្រលឹត	វារីជាតិមានដើមមូលត្រសូល ប្រើធ្វើជាបន្លែឬអន្លក់បាន, មានច្រើនប្រភេទ ខ្លះដើមស្រួយខ្លះស្វិត មានពណ៌ក្រហមលឿងឬស។	១
ព្រហ្មគីតិ	ន. ឈ្មោះកាព្យមួយយ៉ាងក្នុងមួយវគ្គមានបួនឃ្លា ត្រង់ឃ្លាទី១និងទី៣មាន៥ព្យាង្គ ឃ្លាទី២និងឃ្លាទី៤មាន៦ ព្យាង្គ។	៦
ព្រាន	ន. អ្នកប្រមាញ់សត្វ។ ឧ. ស្មានជាប់អន្ទាក់ព្រាន។ ឧ. នាយព្រានភ្ញាក់ ក៏ទន្ទ្រំជើង។	២; ៤
ព្រាហ្មណ៍	ន. មនុស្សដែលកំណត់តាមលទ្ធិបុរាណពីព្រេងនាយថាមានពូជដើមកើតអំពីព្រះឧស្ហព្រហ្ម។	៦

[6] (ទុកជាបរិវាសព្ទផ្សំនឹងពាក្យថា ពាក្យពេចន៍ គឺពាក្យសម្តីផ្សេងៗ)

ព្រឹក្សា	ន. ឈើទាំងឡាយ។ ឧ. ទង់ជាតិបក់រវិចៗឯចុងព្រឹក្សា។	៣
ព្រឹត្តិការណ៍	ន. ហេតុឬដំណើរប្រព្រឹត្តទៅតាមប្រក្រតី។ ឧ. "ភ្លៀងធ្លាក់ខ្លាំង"គឺជាព្រឹត្តិការណ៍ហេតុដែលកើតឡើង "ទឹកលិចភូមិ"ជាផលដែលកើតមានឡើងអាស្រ័យហេតុ។ ឧ. ថ្ងៃនេះមានព្រឹត្តិការណ៍ប្លែកៗនៅបណ្តាញសង្គម ។	៣; ៤; ៥; ៦
ព្រេច	កិ. ពារនឹងក្បាល ជាន់នឹងជើង ចាក់នឹងស្មុក។ ឧ. ថ្ងៃមួយ កូនមេដំរីប៉ាល់ប៉ៃចុះប្រេង ព្រេចហ្មស្រាប់។	៥
ព្រំ	ន. ឈ្មោះកម្រាលពិសេសមួយប្រភេទវិចិត្រដោយពណ៌និងក្បាច់រចនា។	២
ព្រំដែន	ន. ខណ្ឌសីមាបែងចែកទឹកដីរវាងប្រទេសនិងប្រទេស។ ឧ. ឪពុកចិន្តាធ្វើជាយោធានៅឯព្រំដែន។	៣
ព្រះ	ន. ១.អំណាចសក្តិសិទ្ធិជាគ្រឿងសក្ការៈ៖ ព្រះឥន្ទ្រ ព្រះព្រហ្ម។ ២.ន័យសក្ការៈដើម្បីលើកតម្កើងបុគ្គលដ៏ឆ្នើមជាមេសាសនាជាដើម។ ឧ. ព្រះពុទ្ធ ព្រះយេស៊ូ ...។ ៣.ន័យឧត្តុងឧត្តមដើម្បីសម្គាល់អម្បរក្សត្រ។ ឧ. ព្រះរាជា ព្រះនរោត្តម...។ ៤.ប្រើក្នុងរាជសព្ទ សង្ឃសព្ទ ឬពុទ្ធសព្ទខ្មែរ។ ឧ. ព្រះបាទ ព្រះហស្ត ព្រះទន្ត ព្រះកេសា ...។ ៥.ហៅដោយគោរពចំពោះវត្ថុឬបុគ្គលមួយចំនួន។ ឧ. ព្រះចន្ទ ព្រះធរណី ព្រះធម៌ ព្រះសង្ឃ ...។	៥
ព្រះគ្រូឧបជ្ឈាយ៍	ន. គ្រូបង្រៀនធម៌ គ្រូបង្រៀនបា្បប់វិន័យសង្ឃ។	៦
ព្រះចន្ទ	១.ភាវៈសម្រាប់បំភ្លឺជាចម្បងជាងពន្លឺទាំងអស់ក្នុងវេលាយប់៖ ឧ. ព្រះចន្ទពេញវង់ ហៅតាមពាក្យធម្មតាថា លោកខែ ខែរះ ខែលិច ខែភ្លឺ។ ២.ផ្កាយរណបធម្មជាតិរបស់ផែនដី ហើយទទួលពន្លឺពីព្រះអាទិត្យ៖ ឧ. ព្រះចន្ទវិលជុំវិញផែនដី។	៥
ព្រះត្រៃបិដក	ន. ប្រជុំនៃព្រះធម៌ក្នុងពុទ្ធសាសនាដែលចែកជាបីផ្នែក គឺព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម។ ឧ. លោកបានរៀបចំនិងប្រែគម្ពីរព្រះត្រៃបិដក។	៥; ៦
ព្រះបរិត្ត	ន. ធម៌សម្រាប់ការពារសេចក្តីអន្តរាយ។	៦

ព្រះរាជ	ន. មហាក្សត្រដ៏ឧត្តម។ ឧ. គាត់ជាព្រះរាជអគ្គមហេសី។	៣
ព្រ័ត្រ	ន. ពួរឬខ្សែត្រកួចធ្វើដោយស្បែកគោឬស្បែកក្របី។	២;៤
ព្លែម	គុ.កិ. អំពីអាការៈបញ្ចេញអណ្តាតលិទ្ធបបូរមាត់រឿយៗ។ ឧ. កុមារាលិទ្ធអណ្តាតព្លែមៗ។	១
ពំនាក់	ន. ទីពឹងពាក់ ទីជ្រកអាស្រ័យ។ ឧ. មានចៅហ្វាយនាយជាពំនាក់។	៤
ពាំ	កិ. នាំយកអ្វីៗដោយខាំនឹងមាត់។	២
ព័ត៌មាន	ន. ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន ព្រឹត្តិការណ៍។ ឧ. កាលណាគេចង់ដឹងព្រឹត្តិការណ៍ផ្សេងៗ គេអាចអានសារព័ត៌មាន។	៣;៤;៥
ព័ត៌មានផ្ទាល់ខ្លួន	ន. អត្តសញ្ញាណមនុស្សម្នាក់ ចាប់ពីឈ្មោះ អាសយដ្ឋាន សមាជិកគ្រួសារ។ល។ ឧ. សូមបំពេញព័ត៌មានផ្ទាល់ខ្លួន។	៣
ព័ទ្ធ	កិ. ចង រុំជុំវិញ ចោមជុំវិញ ចោមស្ទាក់បិទផ្លូវជុំវិញ។ ឧ. ពស់ធំរុំព័ទ្ធជុំវិញសម្បកក្លួច។ ឧ. សាលារៀនខ្ញុំមានរបងឬព័ទ្ធជុំវិញ។ ឧ. ប៉ូលិសព័ទ្ធចោរ, វល្លិព័ទ្ធដើមឈើ។	២;៣;៤;៦
ភ	**ភ**	
ភទ្របទ	ន. ឈ្មោះខែទី១០ ខាងចន្ទគតិ។	២
ភរិយា	ន. ប្រពន្ធ។ ឧ. ខ្លែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាឱ្យសុខ ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក ដ្បិតភរិយាជា។	៥;៦
ភារកិច្ច	ន. កិច្ចការដែលត្រូវធ្វើឬបំពេញ។ ឧ. ការសម្អាតថ្នាក់រៀនជាភារកិច្ចរបស់យើងទាំងអស់គ្នា។	៣
ភាវៈ	ន. ភាព។ ឧ. ភាវៈកាច, ផ្ទះនេះមានភាវៈគ្រាំគ្រាណាស់ហើយ។	៤
ភាស៊ី	ន. ពន្ធទំនិញដែលរាជការដកហូតពីអ្នកលក់ ឬអ្នកនាំទំនិញចេញចូល។	១;២
ភិតភ័យ	កិ. ភ័យខ្លាច ខ្លាចខ្លាំងឬខ្លាចណាស់។	៥
ភុជង្គ	ន. ពស់ នាគ។ ឧ. ភុជង្គនាគគឺពិភពនាគ។	៤

កុដង្គលីលា	ន. ឈ្មោះកាព្យមួយប្រភេទក្នុងមួយឃ្លាមានសង្កាត់បី, ត្រង់សង្កាត់ទី១មាន៦ព្យាង្គ, សង្កាត់ទី២និងទី៣មាន៤ព្យាង្គ។ ឧ. បទភុជង្គលីលាដូចជា ព្រឹងព្រួសជន្លូសឆ្លូតឆង ក្រូចព្រៃអង្គែង ដុះដាសលាយគ្នា។	៤
ភោគ	ន. សម្បត្តិទ្រព្យ សេចក្តីសុខ ការបរិភោគ ។ ឧ. សិរីជាលំនៅនៃភោគៈ។	៦
ភោជនាហារ	ន. អាហារសម្រាប់បរិភោគ។	៦
ភោជនីយដ្ឋាន	ន. កន្លែងសម្រាប់បរិភោគអាហារ។	៤
ភ្ងា	គុ. ពុំងា ប្រសើរ ថ្លៃថ្លា ជាទីស្រឡាញ់។	៦
ភ្ងារ	កិ. ភ្ងាក់មួយភាំងពីដេកលក់។	១
ភ្ជួរ	កិ. រម្លើងដីដោយនង្គ័លឱ្យរបើកជាអាចម៍បំណះ។ ឧ. ពូសែមដើរទៅយកអាវដែលព្យួរនៅសសរ រួចទើបទៅភ្ជួរស្រែ។	៣
ភ្ជុំបិណ្ឌ	ន. ឈ្មោះវិធីធ្វើទានមួយ ចាប់ពីថ្ងៃ០១រោចនៃខែភទ្របទដល់ខែដាច់(១៥ថ្ងៃ)។	២
ភ្លីទៀន	ន. ឈ្មោះគ្រឿងអុចជាលម្អ មានដងដាំបញ្ឈរធ្វើពីឫស្សី។	១
ភ្ញៀវ	ន. អ្នកដទៃដែលមកលេង មករក មកសួរនាំ មកទិញ។ ឧ. មានភ្ញៀវមកលេងផ្ទះម៉ានី។	២; ៤
ភ្នាក់ងារ	ន. បង្អែកការងារ, អ្នកព្រនាក់ការងារគឺអ្នកជាជំនួយការបន្ទាប់អធិបតី។	២
ភ្នាល់	កិ. ដាក់ខសន្យា ឬតាំងប្រឡងគ្នាដោយមានក្រយាតំណាំង។ ឧ. ភ្នាល់សេះ, ភ្នាល់មាន់។	៥
ភ្នំដើងព្រៃ	ន. ឈ្មោះរមណីយដ្ឋានប្រាសាទភ្នំមួយនៅស្រុកដើងព្រៃ...។ ឧ. លោកគ្រូធ្លាប់ទៅលេងរមណីយដ្ឋានភ្នំដើងព្រៃម្តង។	៣
ភ្លឺ	កិ. បញ្ចេញពន្លឺ យល់ច្បាស់។ ឧ. មេឃភ្លឺហើយបូណា។	៣
ភ្លឺស្រាងៗ	គុ.កិ. ភ្លឺជិតព្រឹក។ ឧ. នៅពេលព្រលឹមភ្លឺស្រាងៗ បូណានៅគេងនៅឡើយ។	៣

ភ្លើងសញ្ញាចរាចរណ៍	ន. ឧបករណ៍មានភ្លើងបីពណ៌សម្រាប់បញ្ជាការធ្វើដំណើរទៅមកកុំឱ្យកកស្ទះឬគ្រោះថ្នាក់។ ឧ. ចៃដន្យរំពេចនោះ ភ្លើងសញ្ញាចរាចរណ៍បានដាច់។	៣
ភ្លេចភ្លាំង	កិ. ភ្លេចដោយភ្លាំងស្មារតី។	៥
ភ័យ	ន. សេចក្តីខ្លាច ហេតុឬដំណើរដែលគួរខ្លាច។ ឧ. ពេលមានរឿងទុក្ខភ័យ អ្នកជិតខាងអាចជួយបានដែរ។	២; ៣
ម	**ម**	
មច្ឆជាតិ	ន. ពួកត្រីទាំងពួង។ ឧ. ក្នុងស្រះ មានមច្ឆជាតិតូចធំហែលទាំងហ្វូងៗ។	៦
មច្ឆា	ន. ត្រី ត្រីទាំងឡាយ ពួកត្រី។ ឧ. ហនុមានទៅនិយាយលួងលោមនាងសុវណ្ណមច្ឆា។	៤
មជ្ឈមមណ្ឌល	ន. មណ្ឌលកណ្តាល។ ឧ. មជ្ឈមណ្ឌលនៃការសិក្សាផ្នែកព្រះពុទ្ធសាសនា, មជ្ឈមណ្ឌលនៃវប្បធម៌។	៥
មណ្ឌល	ន. ១.រង្វង់មូល, ទីដែលមានសណ្ឋានមូល។ ឧ. មណ្ឌលកីឡា មណ្ឌលប្រណាំងសេះ។ ២.រង់ឬដួងព្រះអាទិត្យឬព្រះចន្ទ្រ។ ឧ. មណ្ឌលព្រះចន្ទ្រ មណ្ឌលព្រះអាទិត្យ។ ៣.ទី ទីប្រជុំ តំបន់។ ឧ. មណ្ឌលបោះឆ្នោត មណ្ឌលប្រឡង។	
មណ្ឌលសុខភាព	ន. ទីតាំងទទួលពិគ្រោះនិងព្យាបាលជំងឺកម្រិតតូចនៅតាមឃុំសង្កាត់។ ឧ. ស្រីនាថនិងម្តាយទៅមណ្ឌលសុខភាព។	៣; ៤
មតិ	ន. គំនិត យោបល់។	៦
មធ្យោបាយ	ន. ដំណោះស្រាយ យុទ្ធសាស្ត្រ ឧបាយជាកណ្តាល។ ឧ. នាឡិកាឆ្លាតវៃជាមធ្យោបាយទាក់ទងគ្នាតាមបែបទំនើប។ ឧ. បាវ៉ាំងក៏រកមធ្យោបាយចាប់លោក។ ឧ. ថ្ងៃមួយ គាត់សាកល្បងប្រើមធ្យោបាយមួយ។	៣; ៥; ៦
មនសិការ	ន. ដំណើរយកចិត្តទុកដាក់។	៦
មនុស្ស	ន. នរៈ, ជនអ្នកដឹងការខុសត្រូវ, សត្វវិសេសមួយប្រភេទជាពូជវង្សនៃមនុ។ ឧ. យើងជាមនុស្ស តែត្រូវតែស្វែងយល់និងរៀនសូត្ររកគុណធម៌... ទើបមានភាពជាមនុស្ស។	៣

មនុស្សធម៌	ន. ច្បាប់សម្រាប់ប្រដៅពួកមនុស្ស ឱ្យប្រព្រឹត្តសុចរិត។	៦
មនុស្សម្នា	ន. មនុស្សទាំងឡាយ មនុស្សសាមញ្ញ។ ឧ. មនុស្សម្នាទាំងឡាយអង្គុយក្រសោបឱបគ្នាភ័យរន្ធត់។	៣
មនោរម្យ	គុ. ជាទីរីករាយចិត្ត សប្បាយចិត្ត។ ឧ.ភូមិខ្ញុំបានសុខមនោរម្យ។	៣
មន្ត	ន. ពាក្យដែលចងក្រងសម្រាប់សូត្រសែកស្មោះផ្ចុំ អាគម វេទ, ពាក្យស័ក្តិសិទ្ធិសម្រាប់សូត្រប្រសិទ្ធីឱ្យកើតសុខសួស្តី ...។	៤
មន្ត្រី	ន. ១.អ្នកធ្វើការងារបម្រើរដ្ឋឬរាជការ។ ឧ. គ្រូបង្រៀនជាមន្ត្រីរាជការ។ ឧ. កងទ័ពគីង្គក់ចងពួកមន្ត្រីសេនារបស់តាព្រហ្ម។ ២.បុគ្គលិកនៃសង្គមស៊ីវិលឬអង្គការក៏ហៅថាមន្ត្រី។	២; ៥
មន្ទីរ	ន. គ្រឹហាធំៗ ផ្ទះ អគារ ...។ ឧ. ធម្មមន្ទីរ សារមន្ទីរ មន្ទីរពេទ្យ។	
មមាញឹក	គុ. ដែលញឹកខ្លាំង ដែលញឹកញាប់ពេកឥតស្រាក។	២
មមែ	គុ.កិ. មែៗរឿយៗ ភ្នកនឹករឿយៗមិនភ្លេច។ ឧ. ខ្ញុំនឹកមមែចង់បានផ្ទះតូចតែពីរជាន់នៅក្បែរជើងភ្នំ។	៣
មរណកាល	ន. សេចក្តីស្លាប់ កាលកំណត់ដែលត្រូវស្លាប់ ពេលស្លាប់។ ឧ. ធ្វើមរណកាល ទទួលមរណកាល។	៦
មរណា	ន. សេចក្តីស្លាប់ ក្ស័យ។	៤
មរណៈភាព	ន. ភាពស្លាប់។	៥
មរតក ឬ មត៌ក	ន. ទ្រព្យដំណែលឬទ្រព្យសំបាច់របស់បុគ្គលស្លាប់។ ឧ. ទ្រព្យមរតក គឺទ្រព្យរបស់បុគ្គលដែលស្លាប់ហើយ។ ឧ. យើងរួមគ្នាថែរក្សាមរតកនេះឱ្យបានគង់វង្ស។	៣, ៤
មរតកអក្សរសិល្ប៍	ន. ស្នាដៃអក្សរសិល្ប៍ដែលកវីឬអ្នកនិពន្ធបន្សល់ទុកឱ្យ។ ឧ. បុព្វបុរសយើងបានបន្សល់ទុកមរតកអក្សរសិល្ប៍យ៉ាងច្រើនសន្ធឹកសន្ធាប់។	៥
មហន្តរាយ	ន. អន្តរាយធំ សេចក្តីវិនាសធំ។ ឧ. ក្រោយគ្រោះមហន្តរាយ មានក្រុមសង្គ្រោះចុះជួយអ្នកភូមិ។	៣; ៤
មហាវិថី	ន. ផ្លូវធំៗក្នុងទីក្រុង។ ឧ. អ្នកទាំងពីរដើរឆ្លងកាត់មហាវិថីមួយ។	៣
មហាវិទ្យាល័យ	ន. កន្លែងសម្រាប់សិក្សាជាន់ខ្ពស់ សាលាកម្រិតឧត្តម។ ឧ. គុណបានចូលរៀនមហាវិទ្យាល័យវិចិត្រសិល្បៈ។	៦

មហិច្ឆតា	ន. ការលោភលន់។ ឧ. អ្នកខ្លះមានមហិច្ឆតាខ្លាំងពេកបានប្រើមង អួន ឬសំណាញ់ដែលមានក្រឡាញឹក។	៦
មហិទ្ធិឫទ្ធិ	ន. អំណាចធំ ឫទ្ធិខ្លាំងក្រៃលែង។	៤
ម៉ាស់	ន. កំណាត់ពាក់ការពារច្រមុះកុំឱ្យធូលីហុយចូល ឬកុំឱ្យឆ្លងរោគ។	២
ម្ល៉េះ	គុ.កិ. យ៉ាងនេះ ដូច្នេះ។ ឧ. លំបាកអ្វីម្ល៉េះ! យូរម្ល៉េះ? ឧ. ខ្ញុំមានប្រដាប់ប្រដារៀនហើយ...សប្បាយចិត្តម្ល៉េះទេ។	៣
មាឌ	ន. ទំហំ រូបស្បាត រាងរៅ ។ ឧ. លោកគ្រូមានមាឌធំល្មម។	៤
មាតា	ន. ម្តាយ គឺស្ត្រីដែលផ្តល់កំណើតដល់កូន។ ឧ. គាត់ក៏បានជូនដំណឹងដល់មាតាបិតាសិស្សផងដែរ។	៥; ៦
មាតាបិតា	ន. ម្តាយនិងឪពុក ម៉ែនិងឪ។ ឧ. យើងជាកូនត្រូវគោរពមាតាបិតា។	៣
មាតុភូមិ	ន. ស្រុកកំណើត ប្រទេសកំណើត។ ឧ. ដើមត្នោតដុះស្ទើរពាសពេញទឹកដីនៃមាតុភូមិយើង។ ឧ. ពីដើមមក មាតុភូមិយើងសម្បូរធនធានគ្រប់ទីកន្លែង។	២;៣;៤;៥;៦
មានអារម្មណ៍	កិ. មានចិត្ត គិតឃើញ យល់ឃើញ។	៣
មានះ	កិ. ចចេស រឹងត្អឹង។	៤
មាយា	ន. កិច្ចកល ល្បិចល្បែង ពុតត្បត់ ដំណើរលាក់ពុត។ ឧ. មនុស្សមានមាយា មាយាស្ត្រី។	១; ៤
មារយាទ	ន. សណ្តាប់ធ្នាប់ របៀប របប ឫក ឫកពា។ ឧ. សុជាមានចរិយាមារយាទល្អ។ ឧ. មារយាទថោក មារយាទថ្លៃ ឥតមារយាទ។ ឧ. កូនត្រូវចេះរាប់រើសមារយាទ។	៣; ៤; ៥
មិគសិរ	ន. ឈ្មោះខែទី០១នៃចន្ទគតិ មាន២៩ថ្ងៃ។	៦
មិញ ឬ អំមិញ	កិ. មុននេះ។ ឧ. មិញ គាត់នៅហ្នឹងតើ។	៣
មិត្តភក្តិ	ន. គូកន សម្លាញ់ ពួកម៉ាក។ ឧ. ខ្ញុំពុំសូវមានមិត្តភក្តិ។	៣
មុខរបរ	ន. របរដោយមុខ របរផ្សេងៗដោយឡែក។ ឧ. ការចិញ្ចឹមត្រីជាមុខរបរទីពីររបស់ពូសុខ។	៣

មុសា	គុ. ឬ គុ.កិ. ដែលកុហក មិនពិត ខុស ទទេ។	៦
មូលដ្ឋាន	ន. ទីដែលជាឫសគល់ ទីតាំងមាំ គោលការណ៍សំខាន់។ ឧ. កាកគតិ ព្រហ្មគីតិ ពំនោល និងព្យាង្គប្រាំពីរជាបទមូលដ្ឋានរបស់កំណាព្យខ្មែរ។	៥
មូលនិធិ	ន. កំណប់ទ្រព្យដើម ឬប្រាក់ដែលរៃអង្គាសនឹងធ្វើអ្វីមួយ។ ឧ. ក្រោយពីបានមូលនិធិទូរទស្សន៍និងអំណោយសប្បុរសជន គេបានចាក់ផ្សាយបេតុងភ្លាម។	៥
មូលហេតុ	ន. ហេតុដើម ដំណើរដើម។	៤
មូសិកទន្ត	ន. ធ្មេញកណ្តុរ វណ្ណយុត្តិមួយប្រភេទមានរូបជាគំនូសក្បៀសពីរ សណ្ឋានស្រដៀងនឹងធ្មេញកណ្តុរ (")។ ឧ. គេប្រើមូសិកទន្តលើព្យញ្ជន:«ង ញ ម យ រ វ និងប»។	៣
មួយសម្ទុះ(សន្ទុះ)	គុ.កិ. មួយសម្ទុះគឺប្រហែលមួយភ្លែត(អាចជាង១០នាទី)។ឧ.មួយសម្ទុះក្រោយមក មានសំឡេងចេចចាចៗធ្វើឱ្យគាត់ភ្ញាក់។	២
មេគង្គ	ន. មេទឹក, ឈ្មោះមហានទីគឺទន្លេធំ...មានប្រភពចេញពីទីបេត៍ហូរឆ្លងកាត់ប្រទេសចិន មីយ៉ានម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម។	៦
មេត្រី	ន. សេចក្តីរាប់រក សេចក្តីរាប់អាន។ ឧ. សាលាកុមារមេត្រីចង(ស្ថាន)មេត្រី សូមអញ្ជើញទស្សនាដោយមេត្រី។	៣
មេរោគ	ន. អតិសុខុមប្រាណដែលបង្កជាជំងឺ។ ឧ. រុយជាមេរោគ។	៣
មោទនភាព	ន. ភាពអំនួត ភាពពេញចិត្តនិងកោតស្ញប់ស្ញែងនូវផលអ្វីមួយ។ ឧ. ប៉ាមានមោទនភាពណាស់ដែលកូនរៀនពូកែ។ ឧ. នេះជាមោទនភាពមួយរបស់ជាតិយើង។	៣; ៥
មោហោ	ន. អវិជ្ជា សេចក្តីវង្វេង សេចក្តីល្ងង់ ឬភ័ន្តស្មារតីមិនយល់ការណ៍ពិតមិនស្គាល់ខុសត្រូវ។	៦
មោះមែ	ន. ការទាស់ហេតុ ទាស់ដំណើរ សេចក្តីហ្មងឆ្គង សេចក្តីខុសឆ្គង។	៦
ម្រឹគ	ន. សត្វចតុប្បាទព្រៃទូទៅមានខ្លា ឈ្លូស តោជាដើម។	៤
ម្រឹគីម្រឹគា	ន. ពួកម្រឹគញីនិងម្រឹគឈ្មោល។ ឧ. តំបន់ព្រៃភ្នំជាជំរំសត្វ ម្រឹគីម្រឹគា និងបក្សាទាំងឡាយ។	៣; ៤

ម្រុម	ន. ឈើមានមែកស្រួយឆាប់បាក់ ចាញ់ទឹក ស្លឹកខ្ចីប្រើជាបន្លែ។	១
យ	**យ**	
យប់មិញ	ន. យប់ដែលកន្លងទៅហើយបន្ទាប់គឺថ្ងៃនេះ។ ឧ. យប់មិញ ខ្ញុំគេងមិនសូវលក់។	៣
យល់សប្តិ	កិ. យល់សុបិនឃើញ។ ឧ. ស្លេះយល់សប្តិចម្លែក។	៦
យាគូ	ន. បបរ។	១
យាន	ន. គ្រឿងដឹកនាំ, គ្រឿងសម្រាប់ជិះដូចយ៉ាងរទេះ រថ ទូក ជាដើម។ ឧ. ខ្មែរយកពុទ្ធសាសនាធ្វើជាយាន។	
យានយន្ត	ន. យានដែលធ្វើចរាចរណ៍ដោយម៉ាស៊ីន។ ឧ. អ្នកបើកបរយានយន្តគ្រប់ប្រភេទត្រូវប្រុងប្រយ័ត្ននិងបន្ថយល្បឿន។	៣
យាយី	កិ. បៀតបៀនរឿយៗ ធ្វើទុក្ខបុកម្នេញរឿយៗ។ ឧ. មានជំងឺជាច្រើនដែលតាមយាយីដល់មនុស្សសត្វ។	៣
យីកេ	ន. ឈ្មោះល្បែងមហោស្រពមួយប្រភេទ លេងស្រដៀងនឹងល្ខោន។	១
យីហ៊ុប	ន. ឈ្មោះឈើផ្កាមួយប្រភេទ។	១
យុត្តិធម៌	ន. សេចក្តីទៀងត្រង់ មិនលម្អៀង។	៦
យុវជន	ន. ជនកំលោះក្រមុំ ឬជនវ័យពី១៨ដល់លើស៣០ឆ្នាំ។ ឧ. យុវជនប្រាំនាក់កំពុងឱនរើសសំរាមដាក់ថង់។	៣; ៤
យោគយល់	កិ. យល់ដោយសេចក្តីលម្អៀង យល់មុខ។ ឧ. គ្រួសារខ្ញុំចេះគោរពស្រឡាញ់គ្នានិងយោគយល់គ្នា។	៣
យោធា	ន. ទាហាន(ទាំងឡាយ) ពួកទាហាន។ ឧ. ឪពុកខ្ញុំជាយោធា។	២;៣
រ	**រ**	
ឬក(៣)	ន. បែបបទ សណ្តាប់ធ្នាប់ មារយាទ កិរិយា។ ឧ. ឆ្មាធ្វើឬកអៀនប្រៀន។	២

ឫកពា	ន. មារយាទ កិរិយា សណ្តាប់ធ្នាប់។ ឧ. អ្នកជិតខាងល្អមានឫកពាសុភាពរាបសា មិនងើងច្រងាងដាក់គ្នា។ ឧ. ពេលឪពុកម្តាយប្រើ កូនមិនត្រូវធ្វើឫកពាមិនពេញចិត្តឡើយ។	៣; ៤
រក្សា	កិ. មើលទុកដាក់ឱ្យមានរបៀបឬគង់ល្អ, ថែទាំ ចិញ្ចឹម។ ឧ. គ្រូផ្តាំឱ្យចេះរក្សាធ្វើអនាម័យ។ ឧ. កូនធំហើយ កូនឯងត្រូវចេះរក្សាខ្លួន។	៣; ៤
រង្វង់មូល	ន. កន្លែងដែលផ្លូវកាត់គ្នា ហើយមានវត្ថុរាងរង្វង់នៅកណ្តាល។ ឧ. យើងមកដល់រង្វង់មូលស្តន់ហើយ។	៣
រចនា	កិ. ធ្វើឱ្យត្រូវតាមរបៀប។ ឧ. ជាងដាចេះរចនាឱ្យល្អប្លែក។ ន. ការតាក់តែង ការធ្វើឱ្យវិចិត្រផ្សេងៗ៖ ឧ. ព្រះវិហារមានក្បរក្បាច់រចនាដ៏ប្រណីត។	៥
រញ្ជួយ	កិ. កក្រើក រង្គើដោយទាញ ដោយអង្រួន ឬដោយខ្យល់បក់។	២
រដ្ឋ	ន. ដែន ប្រទេស។ ឧ.កុមារត្រូវប្រឹងរៀន ទើបក្លាយជាពលរដ្ឋល្អ។	៣
រណ្តំ	កិ. ជំគ្នារឿយៗ ប៉ះឬទង្គិចគ្នាដូចគេជំរឿយៗ។ ឧ. បទនីមួយៗសុទ្ធតែពីរោះរណ្តំណែងណង។	៥
រថ	ន. រទេះទឹមសេះ។	៦
រថយន្ត	ន. យានដែលជាទូទៅមានកង់បួនដើរដោយកម្លាំងម៉ាស៊ីន (ឡាន)។ ឧ. រថយន្តកំពុងបើកបរតាមដងវិថី។	៣; ៦
រនាប	ន. ចម្រៀកឫស្សីឬឈើដែលយកមកក្រាលធ្វើគ្រែ ឬធ្វើផ្ទះ។	២
រនាស់	ន. ប្រដាប់មានមេ ដង ធ្មេញ, សម្រាប់ប្រើការរាស់។ ឧ. រនាស់ឈើ រនាស់	៥
រន្ធ	ន. រូង ប្រហោង។ ឧ. ពស់ក៏វារទៅកាន់រន្ធវាវិញដោយក្តីស្រេកឃ្លាន។	២; ៦
រន្ធត់	គុ. ដែលភ័យស្លុត។	៥;៦
របរ	ន. អម្រស់ អម្រស់ដែលរកបានដោយកម្លាំងកាយ។	៣

របស់របរ	ន. របស់ផ្សេងៗ ជាពិសេសរបស់ប្រើប្រាស់ជាប្រចាំ។ ឧ. សុតីក៏ចេះសន្សំសំចៃរបស់របរតាមសំណាង។	៣
របៀប	ន. ការរៀបចំលំដាប់ធ្វើអ្វីមួយឱ្យត្រូវបែប។ ឧ. ពូសុខរៀនពីរបៀបផលិតចំណីត្រី។	៣
រចោយ	ន. ១.គ្រឿងអន្លក់ស្រស់ឆៅឬឆ្អិន សម្រាប់ប្រើបរិភោគផ្សំជាមួយនឹងអាហារឆ្អាប។ ឧ. រចោយនំបញ្ចុកនេះច្រើនណាស់។ ២.គុ.កិ. ដែលពីមុនមានច្រើន លុះតមកកាន់តែរលោះនៅមានបន្តិចបន្តួច រង្វើលៗ។ ឧ. ផ្លែស្វាយនៅមានរចោយៗ, មនុស្សមកកាន់តែរចោយហើយ។	៣
រឆាំ	ន. ល្បែងច្រៀងរាំ។	២
រមណីយដ្ឋាន	ន. កន្លែងឬតំបន់ដែលជាទីរីករាយ ទីសប្បាយ ទីកម្សាន្ត។ ឧ. តើអ្នកធ្លាប់ទៅរមណីយដ្ឋានភ្នំប្រុសភ្នំស្រីឬទេ? ឧ. រមណីយដ្ឋានផ្អោកស្ថិតនៅក្នុងស្រុកគិរីវង់ ខេត្តតាកែវ។	៣; ៥
រម្យទម | រមទម	គុ. ដែលស្រគត់ស្រគំ ដែលសុភាពរាបសា។ ឧ. បើយើងធ្វើឫកមិនរម្យទមចឹង ឃើញទើសភ្នែក គេថាឱ្យហើយ។ គុ.កិ. ឧ. កូនៗត្រូវរៀនិយាយរៀនដើរឱ្យសុភាពរម្យទម។	៥; ៦
រយ៉ា	ន. គ្រឿងព្យរមានរំយោល សម្រាប់ពាក់នឹងត្រចៀក។	១
រឭក	ន. ការដឹងខ្លួន ការភ្ញាក់ដឹងខ្លួន។	២
រលករលេញ	កិ. រលកប្រដេញបន្តគ្នាឥតដាច់។	២
រលីបរលាប	គុ.កិ. ដែលនៅសល់បន្តិចបន្តួចរលាបៗ។ ឧ .សម្លូនៅសល់រលីបរលាបនឹងបាតឆ្នាំង។	១
រលោងស្រិល	គុ. រលោងខ្មៅរលើប។	២
ររីក	គុ.កិ. ដែលកម្រើកឬបម្រះរើកៗ។ ឧ. ចម្លាក់តាមជញ្ជាំងព្រះវិហារក៏មានភាពរស់ររើកដែរ។	៥
រសជាតិ	ជាតិរបស់អាហារ រសធ្ងាញ់។ ឧ. ស្វាយនេះមានរសជាតិផ្អែមធ្ងាញ់ណាស់។	២
រសាយ	កិ. របូតកំនួច របូតចំណង។ ឧ. អ្នកអានផ្ទុះសំណើចរសាយទុក្ខព្រួយបានមួយដងមួយយូរ។	៥

រស្មី	ន. ពន្លឺ ពន្លឺដែលមានខ្សែចាំងព្រាកៗ។ ឧ. ព្រះអាទិត្យបញ្ចេញរស្មី។	៣
ឬស្សា	ន. សេចក្តីច្រណែន សេចក្តីឈ្នានីស។ ល។	៤
រហ៊ុម	គុ. ដែលមានក្លិនស្អុយរងំ ដែលអាក្រក់ឬស្អុយក្តៅឈ្មោះ សាយពេញពាស។	៤
រហ័ស	គុ.កិ. ឆាប់រួសរាន់ លឿន។ ឧ. យើងត្រូវទៅមណ្ឌលសុខភាពឱ្យបានរហ័ស។ ឧ. កូនត្រូវរហ័សទៅសាលារៀននៅព្រឹកថ្ងៃចន្ទ។	២; ៣
រហ័សរហួន	គុ. ដែលមិនយឺត មិនចំអៀក។ ឧ. កូនត្រូវរៀនធ្វើការរហ័សរហួន។	៣
រ៉ែ	ន. ១.អង្គធាតុអសិរីរាង្គដែលកើតឡើងដោយធម្មជាតិឬជាសារធាតុគីមីធម្មជាតិមាននៅក្នុងដី សិលា ឬសំបកផែនដី។ ឧ. ប្រទេសយើងតូច តែសម្បូរភោគទ្រព្យរ៉ែ។ ឧ. គេថា សមុទ្រខ្មែរមានរ៉ែប្រេងកាតច្រើន។ ២.លោហធាតុផ្សេងៗដែលកើតនៅក្នុងដី គេជីកគាស់យកមកម្លាយសម្រាំងយកតែសាច់បានជាលោហជាតិតាមកំណើតដើម។ ឧ. រ៉ែសំណ រ៉ែស្ពាន់ រ៉ែដែក។ល។	៣; ៦
រាំរ៉ែ	គុ. ត្រាំត្រែង យូរ។	២
រាជការ	ន. ការងារឬកិច្ចការដែលត្រូវធ្វើសម្រាប់បម្រើព្រះរាជាឬប្រទេសជាតិ។ ឧ. ពុកម៉ែធ្វើការងាររាជការនិងធ្វើចម្ការដែរ។	៣
រាជរដ្ឋាភិបាល	ន. រដ្ឋាភិបាលនៃព្រះរាជា, ការគ្រប់គ្រងរដ្ឋដែលទាក់ទងដោយព្រះមហាក្សត្រិយ៍។	៦
រាត្រី	ន. យប់។ ឧ. សូមអស់សព្វសត្វបានសុខគ្រប់ទិវារាត្រី។	៥
រានហាល	ន. រានវាលជាប់នឹងផ្ទះសម្រាប់ហាលអ្វីៗ។	២
រាបសា	គុ. ដែលមិនប្លែកពីគេ យ៉ាងកណ្តាល សាមញ្ញ។ ឧ. មនុស្សរាបសា។	៤
រាយ	កិ. ឱ្យហូរហៃ។ ឧ. វារីអគ្គិសនីរាយដល់វាលរាប។	៣
រាយការណ៍	កិ. ថ្លែងរៀបរាប់សេចក្តីតាមដំណើរឬតាមកិច្ចការ។	៦

រាយការណ៍	កិ. ថ្លែងរៀបរាប់សេចក្តីតាមដំណើរឬតាមកិច្ចការ។	៦
រាយមាយ	កិ. ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា, មានចិត្តងាករេ។ ឧ. លោកមិនរាយមាយ គឺចិញ្ចឹមមើលថែកូនឱ្យល្អ។	២
រាវ	កិ ជ្រាវរកដោយដៃ។ ឧ. ធីតាលូករាវចុះឡើងៗ តែរកសៀវភៅមិនឃើញសោះ។	២
រិទ្ធិ | ឫទ្ធិ	ន. អំណាច សេចក្តីអស្ចារ្យ សម្បើម។	៤
រុក្ខជាតិ	ន. សរីរាង្គមានជីវិតដូចជាដើមឈើ បន្លែ ស្មៅ ...។ ឧ. សត្វនិងរុក្ខជាតិទាំងឡាយងាប់អស់ជាច្រើន។ ឧ. ដើមស្វាយជាពាក្យសម្គាល់រុក្ខជាតិ។ ឧ. ដីគ្មានជីវជាតិធ្វើឱ្យបន្លែនិងរុក្ខជាតិមិនអាចលូតលាស់។	២; ៣; ៤; ៦
រុក្ខទេវតា	ន. ទេវតាដែលអាស្រ័យនៅលើដើមឈើ។	៦
រុក្ខា	ន. ដើមឈើ។	៤
រុងរឿង	គុ. ភ្លឺត្រចះត្រចង់ ថ្កើងថ្កាន ប្រសើរ។ ឧ. ពេលស្តាប់តន្ត្រីបុរាណខ្មែរ ធ្វើឱ្យយើងនឹកឃើញអតីតកាលដ៏រុងរឿង។	២; ៣
រួតរះ	កិ. ស្រូតរួត រវៀសរវៃ ម្ដីម្នា។ ឧ. សិស្សរួតរះទៅតម្រង់ជួរ។	៣
រូបសម្បត្តិ	ន. ដំណើរមានរូបសមរម្យ មានរូបល្អ។ ឧ. រូបសម្បត្តិកូនៗល្អហើយ តែវិជ្ជានឹងជួយកូនបានកាន់តែច្រើន។	៤; ៦
រួសរាយ	គុ. រួសមាត់ដោយការរាក់ទាក់។ ឧ. គាត់ជាអ្នករួសរាយរាក់ទាក់។	៣
រើសអើង	កិ. ប្រកាន់យកតែតាមគាប់ចិត្ត។ ឧ. គាត់មិនរើសអើងយើងទេ។ ឧ. សិង្ហរើសអើងនឹងឆ្កែតឿថ្មី	៣
រៀន	កិ. សិក្សា ខំសង្កេតនិងហាត់តាមអនុវត្តតាមឱ្យចេះ។ ឧ. ម៉ែជូនកូនទៅចុះឈ្មោះចូលរៀន។	៣
រេល	គុ. ជ្រុលជ្រាលអំពីគំនរ, រណែល, ទ្រេល។	៦
រោគា	ន. រោគទាំងឡាយ ជំងឺទាំងឡាយ។ ឧ. កាលណាយើងមានអនាម័យ រោគានឹងពិបាកយាយីយើងបាន។	៣

រោងសិប្បកម្ម	ន. កន្លែងធ្វើសម្ភារៈដោយដៃ។ ឧ. អ្នកទាំងនោះបង្ហូរកាកសំណល់ពីលំនៅស្ថាននិងរោងសិប្បកម្មដែលមានជាតិពុល។	៦
រោច	ន. ថ្ងៃខាងរនោចនៃខែចន្ទគតិ គឺថ្ងៃដែលមានពន្លឺព្រះចន្ទថយចុះដូចគេចាប់រោច។	៦
រោទ៍	កិ. ស្រែកឮៗ យំឮ ស្រែកយំខ្លាំង។ ឧ. ទូរសព្ទរោទ៍ តែម្ចាស់មិននៅ។ ឧ. សិង្ហស្រែករោទ៍។	៣
រំភើប	កិ. រញ្ជួយ ព្រឺព្រួច។	២
ល	**ល**	
លក្ខណៈ	ន. គ្រឿងសម្គាល់ គ្រឿងចំណាំ គុណសម្បត្តិ។ ឧ. គុណនាមជាពាក្យសម្តែងលក្ខណៈរបស់នាម។ ឧ. ទង់អាស៊ានមានលក្ខណៈនៃប្រទេសក្នុងតំបន់។	៣
លក់[1]	កិ. ដេកស៊ប់ស្ងាត់អារម្មណ៍មិនដឹងខ្លួន។ ឧ. យប់មិញ ខ្ញុំគេងមិនសូវលក់ គឺភ្ញាក់ពីរបីដង។	៣
លក់[2]	កិ. ឱ្យរបស់ទៅអ្នកទិញដោយយកថ្លៃ។ ឧ. សុភីចេះជួយលក់។	៣
លក់ដូរ	កិ. លក់ខ្លះដូរខ្លះ គឺលក់របស់របិចរបុីរាយរង។ ឧ. នាងជួយម្តាយលក់ដូរនៅឯផ្សារ។	៣
លទ្ធផល	ន. ផលសម្រេច ផលដែលបានហើយ(result)។ ឧ. សុខាទទួលបានលទ្ធផលល្អជាទីគាប់ចិត្ត។ ឧ. បើលទ្ធផលសិក្សាល្អ អ្នកដែលសប្បាយចិត្តជាងគេគឺខ្លួនឯងផ្ទាល់។	២; ៣
លទ្ធភាព	ន. ភាពនៃអ្វីៗដែលបានសម្រេចហើយ ភាពដែលអាចធ្វើកើតឬធ្វើបាន រឿងឬករណីអ្វីមួយដែលអាចធ្វើទៅបាន(possibility)។ ឧ. សុខាតែងខិតខំរៀនអស់ពីលទ្ធភាព។ ឧ. គាត់អស់លទ្ធភាពសងសំណងហើយ។ ឧ. គំនិតដំបូងរបស់ខ្ញុំមិនកើតទេ ខ្ញុំក៏គិតពីលទ្ធភាពទីបី។	៦
លន្លង់លន្លោច	គុ.កិ. ស្រងេះស្រងោចអណ្តែតអណ្តូង។ ឧ. នៅវាលស្រែ គេឮចម្រៀងយ៉ាងលន្លង់លន្លោច។	២
លា	ន. សត្វពាហនៈដែលមានរូបរាងប្រហែលនឹងសេះ តែត្រចៀកវែងជាងសេះ។	២; ៤

លាក់កន្សែង	ន. ល្បែងក្មេងលេងច្រើននាក់អង្គុយដំកង់ទល់មុខគ្នា ក្មេងម្នាក់ឆ្ងលកន្សែងកាន់ដើរក្រឡឹងជុំវិញ ដើម្បីលបដាក់កន្សែងលាក់ពីក្រោយខ្នងក្មេងណាម្នាក់, ហាមផ្តាច់មិនឱ្យអ្នកអង្គុយដំកង់ងាកមើលក្រោយ ឬយកដៃស្ទាបពីក្រោយឡើយ, បើក្មេងដែលគេលាក់កន្សែងពីក្រោយខ្នងនោះមិនដឹងទេ, លុះអ្នកលាក់កន្សែងដើរក្រឡឹងម្តងទៀត មកដល់ត្រូវចាប់កន្សែងគក់ខ្នងក្មេងនោះមួយដៃ ហើយមានអំណាច ត្រូវកាន់កន្សែងដើរក្រឡឹងលាក់តទៅទៀត; ប៉ុន្តែបើដឹងហើយលូកចាប់យកកន្សែងបានមុនគេមកដល់, ត្រូវក្រោកឡើងភ្លាមកាន់កន្សែងដើរក្រឡឹងលាក់តាមចិត្តទៅ; ឯអ្នកដែលលាក់កន្សែងមុននោះត្រូវមកអង្គុយដំកង់ជាមួយនឹងគេវាល់គ្នាវិញ ត្រង់កន្លែងអ្នកដែលក្រោក។ ឧ. ឆ្នាំនេះ យើងមិនសូវឃើញគេលេងលាក់កន្សែង។	៣
លាតសន្ធឹង	គុ. ក្រាលសន្ធឹង ត្រដាងវែងអន្លាយ។	២
លាមក	ន. អាចម៍ ឧច្ចារៈ។ ឧ. សុខាចាក់លាមកសត្វទៅក្នុងរណ្តៅជី។	៣
លិខិត	ន. សំបុត្រ។ ឧ.សំណេរជូនដំណឹងអាចធ្វើតាមរយៈលិខិតស្នាម។	៥; ៦
លិខិតឆ្លងដែន	ន. លិខិតផ្តល់ឱ្យអ្នកដំណើរឆ្លងប្រទេសនីមួយៗ។	៦
លើសលប់	គុ.កិ. លើសហួសកំណត់ ហួសប្រមាណ។	៦
លេងកម្សាន្ត	កិ. លេងលំហែចិត្ត លេងឱ្យសប្បាយចិត្ត។ ឧ. គេនាំគ្នាលេងកម្សាន្តនៅឯវត្ត។	៣
លោកា	ន. លោកទាំងឡាយ។	៦
លោកិយ	ន. ពិភពលោក អ្វីៗក្នុងលោក។ ឧ. កូនត្រូវធ្វើបុណ្យពេលគាត់រលត់សង្ខារលាលោកកិយ។	៦
លោភលន់	ន. ការចង់មាន ចង់បានហួសហេតុ។	៤
ល្ខោនខោល	ន. ឈ្មោះល្បែងមហោស្រពមួយប្រភេទដែលអ្នកសម្តែងមានពាក់ក្បាំងមុខ។	១

ល្បាក់	ន. ថ្នាក់ដែលបាក់របេះឬដែលមានសណ្ឋានដូចគេលាក់ ឬក៏ដូចជាបាក់។ ស្ថានដីដែលមានទម្រង់ដូចគេលាក់ ភាគច្រើនមានទឹកហូរធ្លាក់ចេញពីកន្លែងនោះ។	៦
ល្បិច	ន. កលឧបាយ កិច្ចកល ស្មៀតសម្រាប់គេច។	២
ល្មម	គុ.កិ. សមគួរ មិនលើសមិនខ្វះ មិនតិចមិនច្រើន។ ឧ. គាត់លក់តម្លៃថោកសមល្មម។	៣
ល្មើស	កិ. ប្រព្រឹត្តលើសរំលងលើច្បាប់។ ឧ. ទំនិញក្លែងក្លាយនិងខូចគុណភាពជាប្រការល្មើសច្បាប់និងប៉ះពាល់សុខភាព។	៥
ល្មៀយ	គុ. ដែលទន់ល្មៃ ទន់ដូចសំឡី។	២
ល្វាចេក	ន. ឈ្មោះបក្សីតូចមួយប្រភេទសម្បុរខ្មៅលាយសបន្តិចត្រង់ស្លាប។	២
ល្វឹងល្វើយ	គុ. ល្ហល្ហេវក្រៃពេក ធំធេង។ ឧ. គេឃើញលម្ហសមុទ្រដ៏ធំល្វឹងល្វើយ។	២; ៤
ល្វែង	ន. ប៉ែក សង្កាត់ ចន្លោះជួរសសរ។ ឧ. ល្វែងផ្ទះ។	២
ល្ហល្ហេវ	គុ. ធំទូលាយ វាល។ ឧ. តំបន់នេះមានផ្ទៃល្ហល្ហេវជាច់កន្ទុយភ្នែក។	៦
លំចង់	ន. ពពួកព្រលឹតជាវារីជាតិដុះតាមវាលស្រែ តែដើមមូលតូចៗជាង ដើមសម្បុរស្វាយស្រគាំ ផ្កាសម្បុរខៀវស្វាយ។	១
លំនៅ	ន. ទីឬកន្លែងដែលនៅ។ ឧ. តើឯងមានលំនៅនៅឯណា?	៣
លំនៅដ្ឋាន	ន. ផ្ទះ។	៦
ល័ក្ខ ឬ ល័ខ	ន. វត្ថុវាសម្រាប់លាប ជ្រលក់អំបោះ ឬសូត្រយកពណ៌។ ឧ. បុរសនោះលាយល័ខជ្រលក់អំបោះ។	៥
វ	**វ**	
វគ្គ	ន. ពួក ក្រុម សង្កាត់ ផ្នែក។ ឧ. កំណាព្យឆ្នូតបីប្រការត្រង់មេរៀននេះមានបីវគ្គ។	៥
វង្វេង	កិ. ភ្លេចឬភ័ន្តស្មារតី ភ័ន្តផ្លូវ ច្រឡំចាំពុំបាន។ ឧ. គ្រឿងញៀននាំឱ្យវង្វេងស្មារតី...។	២; ៣
វង្ស	ន. ពូជ ត្រកូល ក្រសែ តំណត្រកូល។	៦

វង្សត្រកូល	ន. ពូជ ក្រសែតំណត្រកូល។ ឧ. សាវន់ជាកូនកសិករមានវង្សត្រកូលល្អ។	៥
វចនានុក្រម	ន. ឈ្មោះសៀវភៅរៀបលំដាប់ពាក្យនិងពន្យល់ន័យពាក្យ។ ឧ. លោកបានចូលរួមយ៉ាងសំខាន់ក្នុងការរៀបចំវចនានុក្រម។	៥; ៦
វឌ្ឍនភាព	ន. ភាវៈឬដំណើរនាំឱ្យចម្រើន។ ឧ. សង្គមមានវឌ្ឍនភាពទាល់តែយើងខំរៀន ខំរក ខំធ្វើ ...។	៣
វណ្ណយុត្ត	ន. គ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរ។ ឧ. វណ្ណយុត្តសម្រាប់ប្រើក្នុងភាសាខ្មែរកន្លងមកមាន១៩យ៉ាង គឺ (ៈ) (៉) (៊) (៏) (៌) (៎) (ៗ) (៍) (៑) (◌្) (។) (៕) (◌ៜ) (}) (-) (...) (-ល-)ឬ(។ល។) (◌:)។	៥
វត្តអារាម	ន. វត្តលោកសង្ឃ។	៥
វត្ថុ	ន. អីវ៉ាន់ របស់ របស់ជាទីតាំង។ ឧ. ទ្រុង លាមក ម៉ាស ទឹក និងសាប៊ូជាពាក្យសម្គាល់វត្ថុ។ ឧ. ដើមត្នោតអាចយកធ្វើផ្ទះ ទូក និងវត្ថុផ្សេងៗទៀត។	២; ៣
វន្ទា	កិ. ថ្វាយបង្គំ សំពះ គំនាប់។ ឧ. កូនត្រូវវន្ទាដោយភក្តី។	៦
វន្ទីយ៍	កិ. ថ្វាយបង្គំ សំពះ គំនាប់។ ឧ. កូននាំគ្នារៀបចង្ហាន់ធូបទៀនភ្ជីក្រាបវន្ទីយ៍ប្រគេនលោក។	៦
វប្បធម៌	ន. ការផ្សាំបណ្តុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីដោយវិទ្យាសាស្ត្រឬសិល្បៈផ្សេងៗ។ ឧ. ក្នុងសារមន្ទីរមានសម្បត្តិវប្បធម៌ជាច្រើន។ ឧ. ខ្មែរមានវប្បធម៌អរិយធម៌រុងរឿងតាំងពីបុរាណ។	៣; ៥
វស្សា	ន. រដូវភ្លៀង។	២
វាងវៃ	គុ. ប៉ិន ឈ្លាស ស្ទាត់ រហ័ស ជំនាញ ប្រាកដ។	៤
វាចា	ន. សម្តី។	៦
វាយតម្លៃ	កិ. កំណត់ឬវិនិច្ឆ័យអំពីគុណភាព សារៈសំខាន់ បរិមាណ ឬគុណតម្លៃរបស់អ្វីមួយ។ ឧ.នៅសេចក្តីបញ្ចប់ យើងអាចវាយតម្លៃថា គាត់ជាមនុស្សល្អ ដូចជាចេះជួយគ្នាក្នុងគ្រោក្រ...។	៣
វាយនភ័ណ្ឌ	ន. ការផលិតគ្រឿងសម្លៀកបំពាក់ មានហូល ផាមួង ក្រមា សារុងជាដើម។	៤

វារ	កិ. លូនដោយប្រវា។ ឧ. កូនក្មេងទើបចេះវារ។ ឧ. ស្រមោចទាំងនោះ តោងវារឡើងមកលើកគោក។	២; ៣
វារី	ន. ទឹក។ ឧ. អគ្គិសនីដោយវារី រាយដល់វាលរាប។	៣;៦
វារីជាតិ	ន. អ្វីៗដែលដុះក្នុងទឹក, សត្វទឹក។ ឧ. ឈូក ព្រលឹត និងលំចង់ជាវារីជាតិ។	៣
វារីអគ្គិសនី	ន. អគ្គិសនីដែលផលិតដោយកម្លាំងទឹកហូរ។ ឧ. តើទំនប់វារីអគ្គិសនីមាននៅឯណា?	៣; ៦
វាសនា	ន. សំណាង បុណ្យភ័ព្វ ចរិយាដែលអប់រំសន្សំទុកឬកប់ទុកក្នុងចិត្ត។ ឧ. អាស៊ានចង់ក្លាយជាសហគមន៍តែមួយវាសនាតែមួយ។	៣
វិចិត្រ	គុ. ល្អប្លែក ដែលរំលេចឬឆ្លាស់ក្បាច់រចនា។ ឧ. របស់វិចិត្រ ការវិចិត្រ ក្បាច់វិចិត្រ។ កិ. លាយចម្រុះឬរំលេចពណ៌ រំលេចឬឆ្លាស់ក្បាច់រចនា។ ឧ. ពូជាងខំវិចិត្ររបស់នេះឱ្យល្អប្លែក។	២; ៥; ៦
វិចិត្រសិល្បៈ	ន. សាលាបង្រៀនជំនាញសិល្បៈជំនាញគំនូរ។ ឧ. ពូធឿននិងអ្នកគ្រូបានណែនាំ ឱ្យចូលរៀនមហាវិទ្យាល័យវិចិត្រសិល្បៈ។	៦
វិជ្ជា	ន. ចំណេះ ការចេះដឹង វេទមន្ត។ ឧ. សិស្សគប្បីខិតខំសិក្សានិងលេងកីឡាដើម្បីបានទាំងវិជ្ជានិងសុខភាពស្មារតីភ្លឺថ្លា។	២; ៤
វិជ្ជាជីវៈ	ន. មុខតំណែង មុខការរបរសម្រាប់ចិញ្ចឹមជីវិត។	៦
វិញ្ញាណ	ន. ធម្មជាតិដឹងច្បាស់ដោយអារម្មណ៍។	៥
វិញ្ញាណក្ខន្ធ	ន. កងវិញ្ញាណដែលរាប់បញ្ចូល១ក្នុងចំណោមខន្ធ៥។	៦
វិថី	ន. ផ្លូវ។	២
វិទ្យាសាស្ត្រ	ន. វិជ្ជាមួយប្រភេទដែលគេរកឃើញដោយពិសោធជាក់លាក់ការលៃផ្សំធាតុជាដើម។ ឧ. គាត់ជាអ្នកវិទ្យាសាស្ត្រដ៏ល្បី។	៣;៤;៥
វិទ្យុ	ន. ឧបករណ៍ចាប់រលកសំឡេង។	៥
វិធី	ន. បែបធ្វើ របៀបធ្វើ របៀបកិច្ចការនៃអ្វីមួយ។ ឧ. ចំណោទនេះ គេអាចធ្វើតាមវិធីបូក។	៣

វិនាស	កិ. ខូចបង់ បាត់ បាត់បង់។ ឧ. ឆ្នាំនេះ ខ្ទុំវិនាសទ្រព្យអស់ច្រើន។ ឧ. អាជីកម្មកាប់ទន្ទ្រានព្រៃឈើក៏នាំឱ្យវិនាសសត្វព្រៃដែរ។	៤; ៦
វិនិយោគ	បោះទុន បណ្តាក់ទុន។ ឧ. ផ្នែកខ្លះត្រូវបានក្រុមហ៊ុនចិនធ្វើវិនិយោគរួចទៅហើយ។	៦
វិន័យ	ន. ការដឹកនាំទៅរកផ្លូវល្អ ច្បាប់ប្រដៅឱ្យប្រព្រឹត្តត្រឹមត្រូវ។ ឧ. សុជារៀនពូកែនិងគោរពវិន័យជានិច្ច។ ឧ. សិស្សត្រូវខំសិក្សា គោរពវិន័យ ធ្វើពលកម្មនិងអនាម័យ។	៣; ៥; ៦
វិរៈជន	ន. ជនក្លាហាន។	៥
វិស្វករ	ន. អ្នកបច្ចេកទេសខាងសំណង់ អគ្គិសនី អេឡិកត្រូនិចជាដើម។ ឧ. ប៉ែនប្រឹងប្រែងរៀនរហូតក្លាយទៅជាវិស្វករជំនាញ។	៥
វិស្សមកាល	ន. ពេលឬឱកាសដែលឈប់សម្រាកពីការងារឬការរៀនសូត្រ។ ឧ. វិស្សមកាលធំ ម្ចាយនាំសុជាតាទៅលេងផ្ទះពូនៅភ្នំពេញ។	៤; ៥
វិស័យ	ន. ទី តំបន់ បរិវេណ ផ្នែក។ ឧ. វិស័យអប់រំ វិស័យសេដ្ឋកិច្ច។	១
វីរជន	ន. ជនអង់អាចក្លាហាន។ ឧ. ការបាត់បង់វីរជនស្នេហាជាតិ ធ្វើឱ្យយើងសោកស្តាយជាពន់ពេក។	៥
វីរបុរស	ន. បុរសអង់អាចក្លាហាន។ ឧ. ក្រឡាហោមគង់ជាវីរបុរស។	៥
វីរុស	ន. មេរោគ។	៥
វឹង	គុ.កិ. វិញ វិញទៀត ភ្លាម, ពេញទំហឹង។ ឧ. សូមបងវិលវឹងឱ្យរួសរាន់វ៉ា។ ឧ. វារត់វឹង។	៤
វុឌ្ឍី	ន. សេចក្តីចម្រើន ការលូតលាស់។ ឧ. ឆ្លៃតស្រានាំឱ្យភ្លេចសីលភ្លេចទានភ្លេចញាណវុឌ្ឍី។	៥
វៀរ	កិ. លើកលែង តម អត់មិនធ្វើ។ ឧ. បើប្រាថ្នាស្មារតីមានញាណវុឌ្ឍី លោកទូន្មានពុំឱ្យសេពឱ្យវៀរតែម្តង។	៥
វេជ្ជបណ្ឌិត	ន. គ្រូពេទ្យព្យាបាលជំងឺដែលមានសញ្ញាប័ត្រវេជ្ជសាស្ត្រពីសាកលវិទ្យាល័យ។	៥
វេទ	ន. វិជ្ជា ចំណេះ, ឈ្មោះគម្ពីរខាងសាសនាព្រាហ្មណ៍។	៤

វេទនា[7]	ន. ការដឹង ឬទទួលអារម្មណ៍ជាសុខឬជាទុក្ខ(ច្រើនសំដៅទុក្ខ)។ ឧ. វេទនាណាស់! វេទនាអ្វីម្ល៉េះទេ!	៦
វេទមន្ត	ន. មន្តក្នុងវេទ (ច្រើនសំដៅមន្តអាគម មន្តសូត្រស្តោះផ្តុំ)។	៤
វេន	ន. កាលកំណត់ ដំណើរផ្លាស់គ្នា។	២
វែរ	កិ. ប្រគល់ឬប្រគេនអ្វីៗចំពោះមនុស្សណាម្នាក់ ឬចំពោះព្រះសង្ឃ។	៦
វេចនសព្ទ	ន. ជាពាក្យមានន័យដូចគ្នានិងអាចជំនួសគ្នាបាន។ ឧ. វេចនសព្ទនៃពាក្យ(ម៉ែ)មាន៖ ម៉ែ ម៉ាក់ ម្តាយ មាតា ញោមស្រី។	៣
វាំង	ន. កំពែងព័ទ្ធភូមិលំនៅរបស់ក្សត្រិយ៍។ ឧ. សារមន្ទីរជាតិនៅក្បែរព្រះរាជវាំង។	៣
វិធ	កិ. ដួសឆ្កឹះខ្លាំងដោយចុងស្នែង ។ ឧ. ក្របីវិធ។	៦
វ័យ	ន. អាយុ កំណត់អាយុ។ ឧ. កូនៗស្ថិតក្នុងវ័យសិក្សា ចូរខំរៀន។ ឧ. ជីដូនជីតាខ្ញុំមានវ័យចាស់ជរាណាស់ទៅហើយ។ ឧ. មនុស្សម្នាក់ៗត្រូវបំពេញកាតព្វកិច្ចឱ្យសមស្របតាមវ័យ។	២;៣;៤
ស	**ស**	
សកម្មភាព	ន. ភាពដែលសកម្មគឺភាពកម្រើក នៅមិនស្ងៀម ការធ្វើឬបំពេញការងារ។ ឧ. តើតួអង្គណាមានសកម្មភាពមុនគេ?	២; ៣
សក្ការបូជា	ន. គ្រឿងបូជាដោយគោរព គ្រឿងបូជាដ៏ផ្ទិតផ្ទង់។ ឧ. គេតម្កល់ឆ្នឹងលលាដ៏ក្បាលទុកធ្វើជាសក្ការបូជានិងឱ្យចងចាំ។	៥
សក្ការៈ	ន. ការធ្វើគោរព គ្រឿងបូជា។ ឧ. គេឆ្លាក់រូបធ្វើជាវត្ថុសក្ការៈ។	៣
សក្តី	ន. សាក្សី។ ឧ. ជាសក្ខីភាព យើងមានបុព្វការីដូចជាជំនន្ឋ ... នូកនជាដើម។	៥
សក្ខីភាព	ន. ភាពជាសក្សី ភស្តុតាង។	៥
សក្តានុពល	ន. លទ្ធភាពឬកម្លាំងដែលអាចធ្វើអ្វីមួយបាន។ ឧ. នៅកម្ពុជាមានសក្តានុពលផ្នែកកសិកម្ម ប៉ុន្តែតើយើងត្រូវធ្វើដូចម្តេច?	៥

[7] ពោលតាមគម្ពីរពុទ្ធសាសនា វេទនាមាន៥យ៉ាង គឺ១-សុខវេទនា ២-ទុក្ខវេទនា ៣-ឧបេក្ខាវេទនា ៤-សោមនស្សវេទនា ៥-ទោមនស្សវេទនា។

សង្កេត	កិ. ពិនិត្យ រំពឹងមើលឱ្យឃើញជាក់។ ឧ. ត្រូវសង្កេតមើលសិន, បានសង្កេតឃើញសព្វគ្រប់ហើយ។	៤
សង្ខារ	ន. ជីវិត សព៌ាង្គកាយ គ្រឿងតាក់តែង។ ឧ. កូនត្រូវផ្គត់ផ្គង់ទាន់គាត់នៅមានសង្ខារ។	៦
សង្គម	ន. បណ្តុំមនុស្សក្រុមធំដែលរស់ក្នុងដែនរួម មានរបៀបរៀបចំរបៀបធ្វើកិច្ចការ ចែករំលែកការងារដែលត្រូវធ្វើ ... និងការការពារសន្តិសុខ។	៦
សង្គមធម៌	ន. មែកធាងនៃអរិយធម៌ដែលទ្រទ្រង់ការរស់នៅ និងការបណ្តុះបណ្តាលតាមរយៈគ្រឿងសម្ភារៈ ប្រដាប់ប្រើប្រាស់ វិធីបច្ចេកទេស ការបង្កើតផលិតផល ការរៀបចំសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ...។	៤
សង្កប់	កិ. ស្ទុះទៅសង្កត់ ស្ទុះទៅគ្របជាប។ ឧ. ឆ្មាសង្កប់កណ្តុរ។	៤
សង្គ្រាម	ន. ចម្បាំង សឹក។ ឧ. ពេលខ្លះ គេធ្វើសង្គ្រាមដើម្បីសន្តិភាព។	២;៣
សង្វាត	កិ. ខំប្រឹងខ្លាំង ខ្មីឃ្មាត ស្រវាស្រទេញ។ ឧ. កូនៗ ចូរសង្វាតសូត្ររៀន។	៣
សង្ហា	គុ.កិ. ដែលរុងរឿង មានរូបល្អអង់អាច ឆើតឆាយ...។ ឧ. តោថ្មឈរយ៉ាងសង្ហា។	៣
សច្ចធម៌	ន. ធម៌ដែលមានពិត ធម៌ដែលកើតឡើងពិត។	៦
សច្ចៈ	ន. សេចក្តីពិត ដំណើរទៀង ទៀងទាត់។	៦
សញ្ជប់	គុ.កិ. ជ្រប់មុខស្រពោនស្រពាប់ក្រៀមក្រំ។ ឧ. យើងត្រូវគោរពទង់ជាតិដោយសញ្ជប់សញ្ជឹង នឹកដល់គុណបុព្វបុរស។	៣
សញ្ជាតិ	ន. កន្លែងដែលកើត ស្រុកកំណើត ឬសគល់កំណើត ដើមកំណើត។	៦
សញ្ជឹង	កិ. ទ្រឹងសញ្ជឹងគិតដោយអាការក្រៀមក្រំ។	២;៦
សញ្ញា	ន. សេចក្តីសម្គាល់, រូប វត្ថុ ឬសភាវៈអ្វីមួយដែលតំណាង។ ឧ. ក្នុងវង់ក្រចកនេះ(?)ជាសញ្ញាសួរ។	៣

សញ្ញាខណ្ឌ	ន. សញ្ញាយ៉ាងនេះ(។)សម្រាប់ប្រើរាំងឃ្លាឬសង្កាត់នៃសេចក្តីមួយៗឱ្យដាច់ស្រឡះដោយឡែកពីគ្នា។ ឧ. ឃ្លា "ការឧស្សាហ៍ព្យាយាម" គ្មានសញ្ញាខណ្ឌទេ, "យើងត្រូវខិតខំរៀនទាន់ខ្លួននៅក្មេង។" ទើបត្រូវមានសញ្ញាខណ្ឌ។	៣
សញ្ញាណ	ន. គ្រឿងសម្គាល់។ ឧ. ពាក្យនេះជាសញ្ញាណ។	៣
សញ្ញាណជាតិ	ន. គ្រឿងសញ្ញាសម្គាល់របស់ជាតិ។ ឧ. ទង់ជាតិជាសញ្ញាណជាតិខ្មែរ។	៣
សណ្ឋិត	កិ. ឋិតនៅស៊ប់ តាំងស៊ប់។ ឧ. កិត្តិនាមលោកនៅសណ្ឋិតជាប់នឹងដួងព្រលឹងកូនខ្មែរជានិច្ច។	៥
សតវត្សរ៍	ន. ឆ្នាំមួយរយ កាលកំណត់មួយជុំរយឆ្នាំឬមួយខួបរយឆ្នាំ។ ឧ. ព្រះវិហារបានសាងសង់នៅចុងសតវត្សរ៍ទី៩។	៥
សត្រូវ	ន. អ្នកបៀតបៀនគេ អ្នករករឿងគ្នា បច្ចាមិត្ត។ ឧ. កូនៗប្រយ័ត្នកុំឱ្យទៅជាសត្រូវនឹងគ្នា។	៣; ៥
សទ្ធា	ន. ជំនឿ។ ឧ. រាស្ត្រឬមន្ត្រីធ្វើបុណ្យតាមសទ្ធា។	៦
សន្ដាន	ន. ពូជពង្ស វង្សត្រកូល។	៤;៦
សន្តិភាព	ន. ភាពស្ងប់ ភាពសះជានឹងគ្នាគ្មានសង្គ្រាម ភាពគ្មានចលាចល ។ ឧ. យើងចង់រស់នៅដោយសុខសន្តិភាព។	១; ៣;៤
សន្ទនា	កិ. និយាយគ្នា។ ឧ. ម្ដាយធីតាសន្ទនាតាមទូរសព្ទនឹងអ្នកគ្រូ។ ឧ. ឪពុកម្ដាយកំពុងសន្ទនាជាមួយភ្ញៀវ។	៤; ៥
សន្ទឹក	ន. សូរលាន់ខ្លាំង សូរដែលលាន់រំពងគួរឱ្យស្ញែច។ ឧ. សន្ទឹកខ្យល់ព្យុះ។	៤
សន្និសីទ	ន. ការប្រជុំជជែកពិភាក្សាបញ្ហាផ្សេងៗដែលស្ថិតនៅក្នុងសកម្មភាពស្មុគស្មាញមិនទាន់ដាច់ស្រេច ដើម្បីរិះរកផ្លូវចេញឬដោះស្រាយឱ្យជ្រះស្រឡះ, ការថ្លែងឬសេចក្តីពន្យល់អំពីបញ្ហាផ្សេងៗដល់សាធារណជន។ ឧ. ខ្ញុំត្រូវទៅចូលរួមសន្និសីទ។	៥
សន្យា	កិ. ប្ដេជ្ញា សន្មត។ ឧ. ពួកប្រុសៗក៏យល់ព្រមតាមខសន្យា។	២;៥
សន្សំ	កិ. ប្រមែប្រមូលពីតិចឱ្យបានទៅជាច្រើន។ ឧ. សំណាងចេះសន្សំប្រាក់ទុកមុនចាយ។	៣

សន្សំសំចៃ	កិ. សន្សំផងសំចៃផង សំចៃអ្វីៗដែលចាំបាច់មិនខ្ជះខ្ជាយ។ ឧ.រឿងនេះអប់រំយើងឱ្យស្រឡាញ់ ចេះថែទាំ និងសន្សំសំចៃ។	៣
សប្តាហ៍	ន. ប្រាំពីរថ្ងៃ។ ឧ. មួយសប្តាហ៍ក្រោយមក នាងធ្វើជាយកសៀវភៅរូបភាពទៅមកមើលឱ្យម្ចាស់ឃើញ។	៦
សប្បាយ	នៅជាសុខ ឥតព្រួយឥតរោគ។ ឧ. កុមារសប្បាយចិត្តពេលមានប្រដាប់ប្រដារៀន។	៣
សប្បាយ	កិ. ១.រីករាយចិត្ត នៅជាសុខ ឥតព្រួយឥតរោគ។ ឧ. ខ្ញុំមិនសូវសប្បាយ។ ២.យ៉ាងសប្បាយ គុ.កិ. គឺយ៉ាងស្រួលចិត្ត។ ឧ. បូបូកំពុងគូរូបលេងយ៉ាងសប្បាយ។ ៣.ន. ដំណើរនៅជាសុខ ដំណើរមិនមានទុក្ខព្រួយ។ ឧ. ទីនេះឥតមានសប្បាយ។	២; ៣
សប្បុរស	គុ. ១.ល្អ ប្រសើរ ត្រឹមត្រូវ។ ឧ. ចិត្តសប្បុរស មនុស្សសប្បុរស។ ២.ន. អ្នកមិនធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត អ្នកប្រព្រឹត្តល្អ អ្នកត្រឹមត្រូវ។ ឧ. ពួកសប្បុរស។	៦
សប្បុរសជន	ន. អ្នកចូលចិត្តប្រព្រឹត្តល្អ ធ្វើទាន និងជួយអ្នកឥតទីពឹង។ ឧ.សប្បុរសជនជាច្រើនបានចុះជួយជនរងគ្រោះ។	៣;៥; ៦
សព	ន. ខ្មោចស្រស់ រូបបុគ្គលស្លាប់។ ឧ. សិង្ហមិនព្រមឱ្យឆ្មាំយកសពឆ្កែចេញពីទ្រុង។ ឧ. នាងយកមាសទៅដាក់ក្នុងមាត់ប្តីរួច ទើបយកសពទៅបូជា។	៣; ៥; ៦
សព្វសាធុការ	ន. ការបញ្ចេញវាចាថា សាធុ! ឧ. សូមទេវតាឱ្យពរសព្វសាធុការ។	៣
សព្វ	គុ.កិ. ទាំងពួង ទាំងអស់ ទាំងមូល ទាំងស្រង ទាំងគ្រប់។ ឧ. ម៉ែមើលសព្វកិច្ចការមេផ្ទះ។	២
សព្វថ្ងៃ	គុ.កិ. រាល់ថ្ងៃ។ ឧ. សព្វថ្ងៃ ខ្ញុំរៀននៅសាលាបឋមសិក្សាក្រែក។	៣
សម	គុ. ដែលល្មមល្មមើលមិនទាស់ភ្នែក។ ឧ. ម៉ាក់ស្លៀកពាក់ខោអាវអីក៏សម។	៣

សមណគោតម	ន. ព្រះបរមនាមរបស់ព្រះសក្យមុនីសម្មុទ្ធ។	៦
សមត្ថកិច្ច	ន. ១.មន្ត្រីរាជការដែលមានដែលជំនាញណាមួយក្នុងការបម្រើរដ្ឋ, ២.ប្រើនសំដៅមន្ត្រីដែលមានតួនាទីបង្ក្រាបអំពើទុច្ចរិត រកសន្តិសុខ រកយុត្តិធម៌។ ឧ. កម្លាំងសមត្ថកិច្ចមកជួយធ្វើអន្តរាគមន៍យកអ្នករបួសទៅមន្ទីរពេទ្យ។	៣; ៥
សមត្ថភាព	ន. មធ្យោបាយឬជំនាញដើម្បីធ្វើអ្វីមួយ, ភាពដែលអាចធ្វើកើត។ ឧ. បច្ចេកវិទ្យាថ្មីៗបានរួមចំណែកអភិវឌ្ឍសមត្ថភាព។	៣; ៥
សមរភូមិ	ន. ទីបោះទ័ព ទីចម្បាំង។ ឧ. អង្គការបានធ្វើការអប់រំពីផលប៉ះពាល់នៃថ្នាំជក់ដល់យុទ្ធជននៅសមរភូមិមុខ។	៥
សមរម្យ	គុ. ដែលត្រូវបែបត្រូវយ៉ាងមិនទាស់ភ្នែក សមល្មម។ ឧ. ប្រជាជនមានជីវភាពសមរម្យ។ ឧ. មីងសឿនមានជីវភាពសមរម្យ។ ឧ. សម្តីសម្តែងនេះមិនសមរម្យ កូនកុំធ្វើទៀតណា៎។ ឧ. សុភាពចង់បានការងារសមរម្យមួយ។ ឧ. បើចង់ទៅណា កូនត្រូវជម្រាបគាត់ឱ្យបានសមរម្យ។	២; ៣; ៤; ៥; ៦
សមាគម	ន. ការរួមគំនិតគ្នា ដំណើររួបរួមកិច្ចការជាមួយគ្នា។ ឧ. អាស៊ានជាសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍។	៣
សមាជិក	ន. អ្នករួមក្នុងគ្រួសារ ចូលរួមក្នុងអង្គភាព សមាគម ឬប្រជុំ។ ឧ. សមាជិកទាំងអស់ក្នុងក្រុមទៅសាលារៀនមុនម៉ោង។	១:៣; ២:៣
សមាស	ន. ការផ្សំចូល ការបង្រួមចូល បំព្រួញបទ។ ឧ. មហស្វារ្យ ជាពាក្យសមាសបែបបាលី គឺ មហា+អស្វារ្យ។	៣
សមាសធាតុ	ន. ធាតុដែលរួមផ្សំដោយធាតុជាច្រើនបញ្ចូលគ្នា។ ឧ. គាត់យកសមាសធាតុផ្សំផ្សេងទៀតលាយចូលគ្នា។	៣
សមិទ្ធផល	ន. ផលដែលបានសម្រេច។ ឧ. កម្ពុជាមានសមិទ្ធផលថ្មីៗ។	៣:៥
សមុទ្រ	ន. សាគរ អន្លង់ទឹកធំធេងជ្រាលជ្រៅលួសលួវលន្លឹមបាត់ត្រើយ ដែលមានអំបិលឬរសជាតិប្រៃស្មើភាគគ្នានឹងទឹក។ ឧ. អ្នកដែលធ្លាប់ទៅលេងឆ្នេរសមុទ្រថាសប្បាយណាស់។	៣
សម្គាល់	ក. ចំណាំ ចំណាំទុកឱ្យស្គាល់។ ឧ. សុខា ជាពាក្យសម្គាល់មនុស្ស។	៣

សម្ងំ	កិ.	១.ប្រឹងដេកធ្មេចភ្នែក, នៅស្ងៀមមិនកម្រើកមិនស្តី។ ឧ. បូណានៅតែសម្ងំគេងដដែល។ ២.នៅធ្វើអ្វីមួយមិនទៅណា។ ឧ. កុំនៅសម្ងំលេង ទៅជួយគេទៅ!	៣
សម្ទុះ (សន្ទុះ)	គុ.កិ.	កម្លាំងឬទំហឹងល្បឿនដែលស្ទុះ(មួយរយៈខ្លី)។ ឧ. បោលមួយសម្ទុះ ទៅមួយសម្ទុះ ដើរមួយសម្ទុះ។	២
សម្បត្តិ	ន.	ទ្រព្យ ធនធាន លម្អ គុណភាព។ ឧ. អ្នកប្រើគ្រឿងញៀនតែងបំផ្លាញទ្រព្យសម្បត្តិ។	២ ៣
សម្បុក	ន.	លំនៅរបស់សត្វតិរច្ឆានពួកខ្លះសម្រាប់ដាក់ស៊ុត ដាក់កូនឬសម្រាប់ជ្រកអាស្រ័យ។ ឧ. មេទាភ្ញាស់បានកូនមួយសម្បុក។	៣
សម្បុរ	ន.	ពណ៌របស់ស្បែក(មនុស្សនិងសត្វ)។ ឧ. ម្តាយខ្ញុំមានសម្បុរខ្មៅស្រអែម។ ឧ. គោខ្ញុំមានសម្បុរស្នោត។	២ ៣
សម្បូរ	កិ.	ពេញគ្រប់គ្រាន់ មានគ្រប់គ្រាន់ បរិបូរ។ ឧ. សិប្បកម្មថ្មកែវអាចលើកស្ទួយជីវភាពឱ្យសម្បូរធូរធារ។	២ ៣
សម្ផស្ស[1]	ន.	ការប៉ះពាល់ព្រមឬត្រូវនៃអាយតន:ខាងក្នុងគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងមនោទៅនឹងអាយតន:ខាងក្រៅ។ ឧ. ចក្ខុសម្ផស្សជាវេទនា គឺការទទួលអារម្មណ៍ដឹងតាមភ្នែក។	៣; ៥
សម្ផស្ស[2]	ន.	សម្រស់ សោភណភាព។ ឧ. នេះជាសម្ផស្សនារីខ្មែរ ដែលមិនចាំបាច់កែសម្ផស្ស។	២ ៥
សម្ពោធ	កិ.	ថ្លែងសេចក្តីរៀបរាប់ ឬរាយការណ៍ក្នុងទីប្រជុំឆ្លង ឬក៏ឡើងមន្ទីរជាដើម។	៥
សម្ព័ន្ធ	ន.	ការចងភ្ជាប់គ្នា ការតភ្ជាប់គ្នា ដំណើរទាក់ទងរកគ្នា។ ឧ. ពួកគេចង់ធ្វើសម្ព័ន្ធនឹងគ្នា។	១; ៦
សម្ព័ន្ធមិត្ត	ន.	ការចងគ្នាជាមិត្ត, ច្រើនសម្គាល់ការចងមិត្តនឹងគ្នារវាងប្រទេសខាងផ្លូវយោធាតាមរយៈកតិកាសញ្ញា...។ ឧ. ស្តេចសៀមចងសម្ព័ន្ធមិត្តជាមួយព្រះជ័យចេស្តា។	៥
សម្ភព	ន.	ការកើតព្រម ការកើតដោយល្អ។ គុ. ដែលកើត ដែលសម្រាល ដែលឆ្លងទន្លេ។ ឧ. មីងទៅមន្ទីរសម្ភព។	១

សម្ភារៈ	ន. គ្រឿងប្រើប្រាស់ របស់ដែលត្រូវរួមផ្សំជាមួយគ្នា។ ឧ.យើងត្រូវសម្អាតដៃនិងសម្ភារៈប្រើប្រាស់ជាមួយសាប៊ូឱ្យបានស្អាត។ ឧ. ក្រោយទឹកជំនន់ អ្នកភូមិខ្វះខាតសម្ភារៈជាច្រើន។	២; ៣
សម្រក	ន. រដូវទឹកស្រក។	៦
សម្រាន្ត	កិ. ដេក។ ឧ. លោកកំពុងសម្រាន្ត។ អញ្ជើញម៉ែសម្រាន្ត!	៥
សម្លាប់	កិ. ធ្វើឱ្យស្លាប់ ផ្តាច់ជីវិត។ ឧ. បើបងសម្លាប់ខ្ញុំ ដូចសម្លាប់ម្តាយឪពុកខ្ញុំដែរ។	២
សម្អាត	កិ. ធ្វើឱ្យស្អាតអស់មន្ទិល។ ឧ. សមាជិកត្រូវរួមគ្នាសម្អាតថ្នាក់។	៣
សម័យ	ន. កាល ពេលវេលា។ ឧ. វត្ថុរបស់ខ្ញុំមិនទំនើបទាន់សម័យមែន ប៉ុន្តែខ្ញុំសម្អាតវាជាប្រចាំ។	២
សរសើរ	កិ. និយាយលើក លើកតម្កើង និយាយស្ងើច។ ឧ. គ្រូសរសើរសិស្សឧស្សាហ៍ ហើយតែងជួយណែនាំសិស្សខ្ជិល។	៣
សស	ន. គ្រឿងសម្រាប់ទ្រ។ ឧ. សសផ្ទះ។	២
សស្ត្រា	ន. គ្រឿងប្រដាប់ធ្វើដោយដែកមានមុខមុត មានកាំបិត ផ្តាក់ដាវ លំពែងជាដើម។	៣
សហការ	ន. ការព្រមធ្វើជាមួយគ្នា។ ឧ. ប្រជាជនជឿជាក់និងចូលរួមសហការ។	៥
សហគមន៍	ន. ប្រជុំភូមិដែលអ្នកស្រុកប្រកបមុខរបរចូលគ្នា។ ឧ. ដើម្បីឱ្យកសិផលមានទីផ្សារ កសិករត្រូវចងក្រងគ្នាជាសហគមន៍។ ឧ. សហគមន៍ល្អមិនត្រូវមានផ្សែងបារីឡើយ។	៣ ៥ ៦
សហប្រតិបត្តិការ	ន. ការបំពេញកិច្ចការរួម ការពួតដៃគ្នាយ៉ាងជិតស្និទ្ធជួយធ្វើកិច្ចការណាមួយ។ ឧ. ប្រទេសកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាសមាជិកក្លឹបឆ្នេរសមុទ្រស្អាតទាំង២៧។	៣
សហាយ	ន. បុរសស្ត្រីដែលដើរហើរឬដែលខូចកាចនឹងគ្នា។	៦
ស៊ីយ	កិ. ចួបហេតុអាក្រក់ចង្រៃ។	២
សាកល្បង	កិ. ល្បងមើលឱ្យដឹង ពិសោធមើល។ ឧ. អ្នកមិនត្រូវសាកល្បងប្រើប្រាស់វាទេ។ ឧ. គាត់សាកល្បងប្រើមធ្យោបាយមួយ។	៣; ៦

សាខា	ន. មែក។ ឧ. ដើមឈើនេះធំហើយបែកសាខាច្រើន។	២
សាគរ	ន. សមុទ្រ។ ឧ. ទោះសាគរធំធេងក៏ពុំស្មើទឹកចិត្តដែលមាន។	១ ២
សាង	កិ. បង្កើត។ ឧ. ការខិតខំរៀនសាងក្តីសុខ។	៦
សាធារណជន	ន. ជនទូទៅ។ ឧ. គាត់សរសេរឱ្យសាធារណជនបានដឹងឮ។	៥
សាធារណៈ	គុ. ដែលទូទៅ ដែលប្រើបានទាំងអស់គ្នា។ ឧ. សុជាគោរពចាស់ទុំទាំងក្នុងសាលានិងទីសាធារណៈ។ ឧ. សាលារៀនជាសម្បត្តិសាធារណៈ។	៣ ៤
សាធុ	គុ. ល្អប្រពៃ ត្រឹមត្រូវ ដែលឱ្យសម្រេចប្រយោជន៍។	១
សាមគ្គី	ន. សេចក្តីព្រមព្រៀង ព្រមព្រឹសជាមួយគ្នា, ដំណើរស្រុះគ្នា។ ឧ. អាជ្ញាធរនិងប្រជាជនចេះជួយគ្នានិងរួមសាមគ្គីគ្នា។ ឧ. ពួកគេចេះសាមគ្គី ស្រឡាញ់គ្នា និងជួយធុរៈគ្នា។ ឧ. កូនចៅសាមគ្គីជួបជុំរីករាយ។	២; ៣; ៤; ៦
សារព័ត៌មាន	ន. កាសែត ទស្សនាវដ្តី។ ឧ. គាត់សរសេរសារព័ត៌មាន។	៥
សារភាព	ន. ១.ភាវៈពិត ដំណើរឬសេចក្តីពិត។ ឧ. ទទួលសារភាព គឺទទួលតាមដំណើរពិត ទទួលខុស។ ២.កិ. ឆ្លើយ បង្ហាញ ឬស្តែងពីអារម្មណ៍តាមសេចក្តីឬភាវៈពិត ។ ឧ. សារភាពកំហុស សារភាពអំពីរឿងរ៉ាវពិត។	២
សារមន្ទីរ	ន. មន្ទីរតម្កល់វត្ថុបុរាណ របស់មានតម្លៃ និងភណ្ឌៈផ្សេងៗ។ ឧ. ខ្ញុំបានទៅសារមន្ទីរជាមួយឪពុកម្តាយ។ ឧ. ពួកយើងក៏បានចូលទស្សនាសារមន្ទីរតម្កល់ឯកសារ។ ឧ. អ្នកមកលេងរាជធានីភ្នំពេញច្រើនទៅវត្តភ្នំ វិមានឯករាជ្យ សារមន្ទីរជាតិ...។	២ ៣ ៥
សាសនា	ន. ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ។ ឧ. នៅក្នុងលោកមានច្រើនសាសនា។	៦
សាហាវ	គុ. កាច កាចមោះមុតឥតញញើត។	២
សិក្ខាសាលា	ន. ការប្រជុំសិក្សារៀនសូត្រ។ ឧ. មានសិក្ខាសាលាមួយនៅខេត្តកំពង់ចាមអំពីផ្កាសាយថ្មី។	៥
សិក្សា	កិ. រៀនសូត្រ។ ឧ. យើងធ្វើអ្វីក៏ដោយ យើងគួរសិក្សាសិន។	៣;៦

សិង្ហ	ន. សីហៈ តោ។ ឧ. សិង្ហមិនបានខាំឆ្កែតឿទីមួយ។	៣
សិទ្ធិ	ន. អំណាច ការសមតាមបំណង លទ្ធភាពទទួលស្គាល់បានតាមផ្លូវច្បាប់។ ឧ. កូនទាក៏មានសិទ្ធិរស់រានមានជីវិតដែរ។	៣; ៦
សិប្បកម្ម	ន. ១.ការជាងគឺជំនាញក្នុងការបង្កើតរបស់ដោយដៃ។ ២.កន្លែងផលិតកម្មធុនតូច ឬសហគ្រាសខ្នាតតូចជាងរោចក្រ គឺប្រើពលកម្ម តិច អាចមានម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ ផលិតផលបានតិចតួចនិងគុណភាពមានកម្រិត។ ឧ. សិប្បកម្មចម្លាក់ថ្មកែវលើកស្ទួយជីវភាពមួយកម្រិត។ ឧ. គេច្រើនឃើញមានសិប្បកម្មស្លដៃកនៅទីប្រជុំជន។	៣; ៥
សិប្បករ	ន. ជាង អ្នកធ្វើជាង អ្នកធ្វើការងារហត្ថកម្ម(Craftsman)។ ឧ. សិប្បករមានដូចជាអ្នកមានជំនាញ ឬជាជាងឈើ ឆ្លាក់គូរ រៀបឥដ្ឋ ... បូកបាយអជាដើម។	៥
សិប្បនិម្មិត	គុ. ដែលកើតដោយប្រើបច្ចេកទេសជំនួសផលធម្មជាតិ។ ឧ. តួងសិប្បនិម្មិត ផ្ទៃញសិប្បនិម្មិត បញ្ញាសិប្បនិម្មិត។	៥
សិប្បៈ	ន. ជំនាង ឬការជាងផ្សេងៗដោយហត្ថកម្ម។ ឧ. ចំណេះខាងសិប្បៈ(កម្ម)ដែលត្រូវសិក្សា មានការជាងឈើ ឆ្លាក់គូរ រៀបឥដ្ឋ បូកបាយអ រហូតដល់ការបង្ហាត់សេះដំរី, ចំណេះភ្លេងតន្ត្រីច្រៀងរាំជាដើម ឬការប្រដាប់តាក់តែងការរចនាវិចិត្រផ្សេងៗ (ហៅ សិប្បៈឬ**សិល្បៈ** ទាំងអស់)។	៥
សិរី	ន. មង្គល សួស្តី សេចក្តីសុខចម្រើន។ ឧ. សិរីជាលំនៅនៃភោគៈ។ ឧ. ផ្ទះបងមានសិរីត្រជាក់ត្រជុំណាស់។ ឧ. យើងនាំគ្នាបោសជម្រកនាំសិរីមក។	២; ៦
សិល្បករ	ន. អ្នកសិល្បៈ ដូចជាអ្នកសម្តែង អ្នកចម្រៀង អ្នករបាំ ...។	៥
សិល្បៈ	ន. ចំណេះដឹង របៀប ឬបំណិនក្នុងការធ្វើអ្វីមួយ(សិប្បៈ)។ ឧ. តូរ្យតន្ត្រីខ្មែរក៏ជាសិល្បៈបុរាណមួយរបស់ខ្មែរ។	៣
សិល្ប៍	ន. សិប្បៈ»សិល្បៈ»សិល្ប៍ គឺចំណេះដឹង របៀប ឬបំណិនក្នុងការធ្វើអ្វីមួយ(សិប្បៈ)។	៥

សិល្បវិធី	ន. សិល្ប: វិធីសាស្ត្រ ឬមធ្យោបាយផ្សេងៗរបស់អ្នកនិពន្ធក្នុងការសរសេររឿងដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ អ្នកទស្សនាឱ្យជក់ចិត្ត ចាប់អារម្មណ៍ទៅតាមដំណើររឿង។	៥
សិស្សានុសិស្ស	ន. សិស្សទាំងឡាយ គឺទាំងតូចទាំងធំ...។ ឧ. សិស្សានុសិស្សរួតរះរើសសំរាមមុនពេលគោរពទង់ជាតិ។ ឧ. នៅក្នុងទីធ្លា សិស្សានុសិស្សនាំគ្នាលេងល្បែងជាក្រុមៗ។	២; ៣; ៥
សីតុណ្ហភាព	ន. ភាពត្រជាក់និងក្តៅ។ ឧ. ដើម្បីដឹងសីតុណ្ហភាព គេប្រើទែម៉ូម៉ែត្រ។	៣
សីល	ន. ១.ចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា។ ឧ.ពួកាន់សីលហើយ មិនរវល់ទៀតទេ។ ២.ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ[8]។ ឧ. **សីល**ជាបាតគ្រឹះ បន្ទាប់មក**សមាធិ**ដែលនាំទៅរក**បញ្ញា**។	៣
សីល១០	ន. សីលសម្រាប់សមណេរនិងគ្រហស្ថ។	៦
សីល៥	ន. សីលដែលអប់រំមនុស្សទូទៅដើម្បីឲ្យសុខសន្តិភាពក្នុងជីវិតរស់នៅ រួមានវៀរចាកកិរិយា១.សម្លាប់សត្វ ២.កាន់យកនូវវត្ថុដែលគេមិនបានឱ្យ ៣.ព្រឹត្តខុសក្នុងកាមទាំងឡាយ ៤.ពោលនូវពាក្យកុហក ៥.ផឹកនូវទឹកស្រវឹង។	៦
សីលធម៌	ន. ១.ធម៌ដែលនាំកាយវាចាឱ្យប្រព្រឹត្តល្អ វៀរចាកអំពើអាក្រក់។ ឧ. មនុស្សមានសីលធម៌សំដៅមានឥរិយាបថល្អ ចេះជួយគ្នា ចេះគោរពច្បាប់ ...។ ២.អាកប្បកិរិយាស្តង់ដា គឺគោលការណ៍និងជំនឿអំពីអាកប្បកិរិយាដែលត្រូវនិងខុស ឬ ល្អនិងអាក្រក់។[9] ឧ. ខ្ញុំគោរពក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន។	៣; ៥; ៦

[8] (ព.ពុ.មានសីល៥ សីល៨ និងសីល១០)

[9] អាចជាផ្អែកតាមទស្សនវិជ្ជា? សីលធម៌ទាំងប្រាំយ៉ាងមាន៖

សីលធម៌ផ្ទាល់ខ្លួន ៖ ដឹងខុសត្រូវ ល្អអាក្រក់ ភ្លាហាន មានការទទួលខុសត្រូវ មានភាពម្ចាស់ការក្នុងការងារ។

សីលធម៌ក្នុងគ្រួសារ ៖ ស្គាល់កាតព្វកិច្ចជាឪពុកម្តាយ ជាកូន, ចិញ្ចឹមបីបាច់កូនឲ្យកូនរៀនសូត្រ ស្រលាញ់ឧបត្ថម្ភកូន អប់រំកូនស្មើៗគ្នា។

សីលធម៌វិជ្ជាជីវៈ ៖ មិនលោភលន់ ប្រកបរបរសុចរិត មិនរំលោភបំពានអ្នកដទៃ មានមនសិការការងារ ចេះតស៊ូព្យាយាមមិនរាថយ។

សីលធម៌ក្នុងសង្គម ៖ មានសាមគ្គីល្អ មិនបង្កទំនាស់ ចេះគោរពសិទ្ធិគ្នា ស្រលាញ់យុត្តិធម៌ ស្រលាញ់មនុស្សទូទៅ ទទួលស្គាល់ទុក្ខអ្នកដទៃ។

សុខទុក្ខ	ន. សុខនិងទុក្ខ គឺសភាពសុខឬមានទុក្ខដូចម្តេច។ ឧ. មីងនិងស្រីនាថមកសួរសុខទុក្ខអ្នកគ្រូ។	៣
សុខភាព	ន. ១. ភាពជាសុខ សេចក្តីសុខ។ ឧ. គាត់មានសុខភាព។ ២. សភាពនៃអាការៈរាងកាយឬផ្លូវចិត្ត។ ឧ. សុខភាពរបស់កុមារក៏ល្អឡើងវិញ។	៣
សុខសាន្ត	ន. សុខស្ងប់ សុខស្រួល។ ឧ.ពុកម៉ែត្រេកអរ គ្រួសារក៏បានសុខសាន្ត។ ឧ. កូននិងមេមាន់រស់នៅប្រកបដោយភាពសុខសាន្ត។ ឧ. សត្វទាំងបីនាំគ្នារស់នៅក្នុងព្រៃជាសុខសាន្ត។	២; ៣; ៤
សុចរិត	ន. ការប្រព្រឹត្តល្អ ការធ្វើត្រឹមត្រូវ។ ឧ. សំណាងជាក្មេងសុចរិត។ ឧ. មនុស្សមានសេចក្តីថ្លៃថ្នូរព្រោះប្រព្រឹត្តតែអំពើល្អ មានគុណធម៌ សីលធម៌ សុចរិត ...។ ឧ. ការប្រព្រឹត្តអំពើសុចរិត តាំងចិត្តស្មោះ មិនកុហក និងមិនមើលបំណាំគ្នានោះជីវិតគង់បានសេចក្តីសុខ។	២; ៥; ៦
សុជីវធម៌	ន. ការរស់នៅដោយល្អ មានសណ្តាប់ធ្នាប់ ដឹងប្រមាណ ចេះគួរសមក្នុងការប្រាស្រ័យ។ ឧ. កូនល្អត្រូវមានសុជីវធម៌។	៣; ៦
សុបិន	ន. ការដេកលក់ដែលប្រើសំដៅ "ការយល់សប្តិឃើញ"។ ឧ. យប់មិញ ខ្ញុំមានសុបិនមិនល្អ។	៦
សុភមង្គល	ន. មង្គលល្អប្រពៃ គឺសេចក្តីសុខទាំងផ្លូវកាយនិងចិត្ត។ ឧ. សមាជិកគ្រួសារខ្ញុំរស់នៅប្រកបដោយសុភមង្គល។	៣; ៦
សុភាពរាបសា	គុ. សុភាពរមទម សុភាពគួរឱ្យចូលចិត្ត។ ឧ. ជាវីមានចរិតសុភាពរាបសាគួរឱ្យស្រឡាញ់។	៣
សុរា	ន. ទឹកស្រវឹង ហៅក្លាយទៅជាស្រា។[10] ឧ. អ្នកសេពផឹកសុរាតែងវង្វេងស្មារតី។	៣
សុវណ្ណ	ន. មាស។ ឧ. សុវណ្ណមាលា មានន័យថាកម្រងផ្កាមាស។	៣
សុវណ្ណភូមិ	ន. ដែនដីមាស ទឹកដីដែលសម្បូរសម្បត្តិធម្មជាតិ។ ឧ. ដែនដីខ្មែរប្រៃថាសុវណ្ណភូមិ។	៣

សីលធម៌ពិភពលោក៖ មានទំនាក់ទំនងល្អជាមួយបរទេស ដោយមិនប្រកាន់ជាតិសាសន៍ វណ្ណៈ ពណ៌សម្បុរ ...។

[10] ទឹកស្រវឹងមានដើមកំណើតដំបូងបង្អស់ កើតអំពីព្រានព្រៃឈ្មោះ សុរៈ។

សុវត្ថិភាព	ន. ការប្រកបដោយសេចក្តីសុខ ភាពមានជោគមានសួស្តី។ ឧ. ក្មួយទៅចុះ សូមបានតែសុខនិងសុវត្ថិភាពតាមផ្លូវ។ ឧ. កូនគួរជ្រើសរើសល្បែងណាមានសុវត្ថិភាព។	៣ ៤
សូន្យសង្ហារ	កិ. ស្លាប់។ ឧ. បើមិនចង់សូន្យសង្ហារ ឯងកុំលេងល្បែងនេះ។	៤
សូរ	ន. សព្ទ សំឡេង សំឡេងលាន់ឮ។ ឧ. ពាក្យ(លិច លេច) អាចមានសូរដូចគ្នា។	៣
សូរសព្ទ	ន. សូរសំឡេង សំឡេងក្លៀវក្លា សំឡេងខ្លាំង។ ឧ. ពាក្យ(សរ ស) ក៏មានសូរសព្ទតែមួយដូចគ្នា។	៣
សួគ៌	ន. ទេវលោក ឋានទេវតា។ ឧ. គេចាត់ទុកឆ្នេរអូរឈើទាលជាឋានសួគ៌ទេសចរណ៍។	៣
សួរ	កិ. ពោលពាក្យទៅរកអ្នកដទៃឱ្យគេឆ្លើយតបប្រាប់។ ឧ. នៅពេលគេសួរក្នុងល្បះសំណួរ ត្រូវបញ្ចប់ដោយសញ្ញាសួរ(?)។	៣
សួស្តី	ន. សេចក្តីសុខស្រួល សុខចម្រើន, ការប្រព្រឹត្តទៅស្រួលដំណើរមានជោគ។ ឧ. មានសួស្តី ទៅមកដោយសួស្តី។	
សេកសោម	ន. សេកមានមាឌធំនិងមានចំពុះក្រហម។	១
សេចក្តីបញ្ចប់	ន. សេចក្តីដែលត្រូវបញ្ចប់នៅចុងតែងសេចក្តី។ ឧ. នៅសេចក្តីបញ្ចប់ កូនៗសរសេរតែពីរបីជួរបានហើយ។	៣
សេចក្តីផ្តើម	ន. សេចក្តីដែលត្រូវផ្តើមនៅដើមតែងសេចក្តី។ ឧ. សេចក្តីផ្តើមនៃការពណ៌នាពីសត្វ ត្រូវប្រាប់ឈ្មោះ ភេទ និងកន្លែងរស់នៅ។	៣
សេដ្ឋកិច្ច	ន. ១.កិច្ចការដែលនាំឱ្យមានបាន កិច្ចការរកស៊ីជួញដូរដែលនាំចំណូល។ ឧ. ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ពូសុខធ្វើស្រែផងនិងចិញ្ចឹមត្រីផង។ ២.កិច្ចការឬមុខរបរដ៏ឧត្តមដែលនាំឱ្យប្រទេសរីកចម្រើន។ ឧ. តាត្រាំប្រឹងពង្រឹងសេដ្ឋកិច្ចប្រទេសរបស់គាត់។	៣; ៥; ៦
សេដ្ឋី	ន. អ្នកមានទ្រព្យច្រើន អ្នកមានធំ។ ឧ. គេជាសេដ្ឋី ព្រោះគេចេះដឹងរឿងសេដ្ឋកិច្ច ដឹងបែងចែកចំណូលចំណាយ ដឹងនិងចេះកិច្ចការដែលរកចំណូលបាន។	២
សេនា	ន. ពួកទាហាន កងទ័ព រេហ៍ពល។ ឧ. សេនាមឿងបានចូលថ្វាយខ្លួន។	៥

សេព	កិ. ផឹក បរិភោគ ប្រព្រឹត្ត ប្រើប្រាស់ រាប់រកយកជាគ្នា។ ឧ. លោកពុំឱ្យសេពសុរា ព្រោះខ្លាចវាអាចនាំឱ្យឆ្គួត។ ឧ. កុំសេពគ្រឿងញៀន សុរា ឬកញ្ឆានាំឱ្យវេទនា។ ឧ. កុំសេពគប់មិត្តដែលដើរលេងច្រើន។	៣; ៥; ៦
សេពគប់	កិ. រាប់រកយកជាគ្នា។	៦
សេរីភាព	ន. អំណាចដែលអាចធ្វើបានតាមអំពើចិត្ត ប៉ុន្តែក្រោមច្បាប់ អំណាចពេញទី។	៤
សេវាកម្ម	ន. ការផ្តល់សេវាដល់អតិថិជនឬសាធារណជន។ ឧ. ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ។	៣
សោភណភាព	ន. លម្អ សម្រស់ ភាពស្រស់ស្អាត។ ឧ. យើងប្តេជ្ញាថែរក្សាឆ្នេរសមុទ្រឱ្យមានអនាម័យនិងសោភណភាពល្អប្រណីត។	៣
សោភា	ស្រស់ត្រចង់ ស្រស់ស្អាត ស្រស់ប៉ប្រៃ។ ឧ. សួនច្បារមានជីរម្ទេសផ្កាល្អស្រស់សោភា។	២
សោភ័ណ	គុ. ល្អ ហ្មត់ហ្មែង ប្រសើរ។	៦
សោមនស្ស	ន. សេចក្តីសប្បាយចិត្ត។	៦
ស្លប់	កិ. កោតខ្លាច ស្ងៀមស្ងាត់ដោយកោតខ្លាច។ ឧ. អ្នកស្រុកស្លប់ឥតហ៊ានកម្រើក។	២
ស្លប់ស្លែង	កិ. ស្លប់ខ្លាចក្រែងស្ងែងក្នុងចិត្ត។	២
ស្លែង	កិ. កោត នឹកខ្លាច នឹកអស្ចារ្យក្នុងចិត្ត អៀនខ្មាសខ្លាំង។ ឧ. គេស្ងែងអស់ទាំងស្រុក។	២
ស្តារ	កិ. ១.បាចឬដងយកទឹកចេញឱ្យស្រាលឱ្យស្អាត: ឧ. ស្តារទូកស្តារអណ្តូង។ ២.កកាយឬកើបយកចេញឱ្យអស់:ឧ.ស្តារបង្គន់ ស្តារជង្រុក។ ៣.បាញ់លមើលឱ្យអស់ច្រែះ ឱ្យថ្នឹក ឱ្យសុំសាច់: ឧ. ស្តារកាំភ្លើង។ ៤.ធ្វើឱ្យមានភាពប្រសើរឡើងវិញ ឱ្យមានប្រក្រតីភាពឡើងវិញ: ឧ. តើយើងអាចស្តារស្ថានភាពនេះបានឬទេ?	៦
ស្តីបន្ទោស	កិ. ស្តីឱ្យ ថាឱ្យ បន្ទោសនៅមុខ។ ឧ. គាត់មិនស្តីបន្ទោសទេ។	៣

ស្តុក	គុ. ដែលមានច្រើន មានទំហំធំ។	៥
ស្តុកស្តម្ភ	គុ. មាំមួន បរិបូណ៌ មានច្រើន។	៦
ស្ថានភាព	ន. សភាពនៃទីតាំង, បរិស្ថានឬកាល:ទេស:ណាមួយដែលជះឥទ្ធិពល...។ ឧ. ក្នុងស្ថានភាពនេះ យើងនឹងដាំកូនឈើឱ្យបានច្រើន។	៦
ស្ថានីយ	ន. ទីសម្រាប់ស្នាក់ ទីសំចត ដំណាក់សម្រាប់ឈប់សម្រាក។	៤
ស្ថិរភាព	ន. ភាពឋិតថេរ។ ឧ. អាស៊ានចង់ឱ្យសមាគមនេះមានស្ថិរភាព សន្តិភាព ...។	៣
ស្នុះស្នា	កិ. ស្នុះដោយប្រញាប់ រួសរាន់ រូតរះ។ ឧ. ម៉ានីស្នុះស្នាចេញពីក្នុងផ្ទះមកដោយត្រេកអរ។	២
ស្នង	ន. តំណាង។ កិ. ជួស ចេញខ្លួនជាតំណាង: ឧ. កូនស្នងឪពុក ព្រះពុទ្ធរូបស្នងព្រះអង្គ។	២
ស្នា	ន. អាវុធបុរាណមួយប្រភេទធ្វើសម្រាប់បាញ់ព្រួញ។ ឧ. ព្រានប្រមាញ់លើកស្នាបម្រុងនឹងបាញ់លលកនោះ តែស្រមោចខាំផ្អើលបាត់។	២
ស្នាក់ការ	ន. ទីកន្លែងណាត់ជួបជុំ។	២
ស្នាដៃ	ន. ថ្វីដៃ, អ្វីៗដែលកើតពីដៃដែលបានធ្វើបានសម្រេច។ ឧ. យើងត្រូវចេះស្រឡាញ់និងថែរក្សាស្នាដៃខ្មែរជំនាន់ដើម។	៣; ៥
ស្នាព្រះហស្ត	ន. ស្នាដៃ។ ឧ. លោកមានស្នាព្រះហស្តជំៗជាច្រើន។	៥
ស្នឹត	ន. សំណុំផ្លែចេកដែលនៅជាប់នឹងស្នង ឬដែលពន្លះចេញពីស្នងមកមិនឱ្យរបេះដាច់ពីគ្នា។ ឧ. ចេកមួយស្នឹតថ្លៃពីរពាន់រៀល។	២
ស្និទ្ធស្នាល	គុ. ជិតដិតនឹងគ្នា ស្និទ្ធឥតរង្កៀស។	៤
ស្នូក	ន. មានរាងក្រឡមខាងក្នុង សណ្ឋានស្មាចតែមានរបាំងខាងដើមនិងខាងចុង	២
ស្នែង	ន. ប្រដាប់សម្រាប់សែង។ ឧ. កូនទ្រាំមិនបាន ក៏ទម្លាក់ស្នែងចោល។	២

ស្បៀង	ន. គ្រឿងបរិភោគចិញ្ចឹមជីវិតក្នុងការដើរផ្លូវឆ្ងាយ។ ឧ. សប្បុរជនក៏បានចុះជួយឧបត្ថម្ភស្បៀងអាហារ។	៣
ស្ពានអាកាស	ន. ស្ពានដែលគេសង់ខ្ពស់រំលងលើផ្លូវដើម្បីបញ្ចៀងការស្ទះចរាចរណ៍។ ឧ. នៅភ្នំពេញមានស្ពានអាកាស។	២ ៣
ស្មារតី	ន. សេចក្តីនឹកឃើញ ការចាំបាន សតិ។ ឧ. គ្រឿងញៀនធ្វើឱ្យវង្វេងស្មារតី ឆេវឆាវ ខូចសុខភាព...។	៣:៤:៥:៦
ស្អរ	គុ. កំណាញ់ រឹតត្បិតឥតអៀនខ្មាស ។	៤
ស្មោះត្រង់	គុ. ស្មោះពិត ស្មោះឥតងាករេ។ ឧ. ក្នុងរឿងនេះ សិង្ហមានភាពស្មោះត្រង់ តែរើសអើងគ្នា។	៣
ស្មោះសរ	ន. សេចក្តីរីករាយរាក់ទាក់ គោរព សាទរ។ ឧ. កូនត្រូវស្តាប់ដំបូន្មានដោយចិត្តស្មោះសរ។	៣; ៦
ស្រងាត់	គុ. ដែលមានពណ៌ខៀវ ឬបៃតងស្រដាំឆ្ពះភ្នែក។	២
ស្រវា	កិ. លូកដៃទៅចាប់យកអ្វីៗដោយប្រញាប់ ក្រសាវយកដោយម្ជឹម្ហា។ ឧ. វាស្រវាយកនំតែម្នាក់ឯង។	
ស្រវាស្រទេញ	កិ. ខំប្រឹងខ្លាំង សង្វាតខ្លាំង។ ឧ. នេះជាវ័យដែលត្រូវស្រវាស្រទេញរកចំណេះវិជ្ជា។	៥
ស្រាក	កិ. បានអន់, ស្រាល ធូរស្រាល។ ឧ. ស្រាកឈឺ ស្រាកកំហឹង ភ្លៀងឥតស្រាក។	៦
ស្រាកស្រាន្ត	គុ. ស្រាកអស់កម្លាំង ឬអន់អស់កម្លាំង គឺធូរស្រាលពីអស់កម្លាំង ធូរស្រាលគ្រាន់បើម្តងៗ។	៦
ស្រាន្ត	គុ. ១.លំបាក នឿយហត់ អស់កម្លាំង។ ឧ. ...មើលថែម៉ែឪឱ្យលោកស្រាន្ត (ច្រើននិយាយថា ស្រាកស្រាន្ត)។ ២.ដែលបានអន់គ្រាន់បើ អន់ឈឺ(លែងសូវឈឺ)។ ឧ. ជំងឺស្រាន្ត។	៦
ស្រាំ	គុ. ដែលមានស្នាមប្រេះឆា។	២
ស្លន់ស្លោ	កិ. ស្លន់ធ្វើភ្នែកស្លោ ឬស្លន់ឆោឡោ។ ឧ. គាត់ភ័យស្លន់ស្លោមិនដឹងជាធ្វើដូចម្តេច។	២; ៤
ស្លាក	ន. សំបុត្រជាកំណត់តូចៗ ជាគ្រឿងសម្គាល់ឈ្មោះជាដើម។ ឧ. សរសេរស្លាក, បិទស្លាកជាសម្គាល់។	៦

ស្លូតបូត	គុ. ស្លូតសុភាព ស្លូតនឹងធឹង មិនងាយរបូតមាត់ថា។ ឧ. ដាវីជាក្មេងស្លូតបូត។	៣
ស្វាគមន៍	កិ. និយាយជម្រាបសួរដោយគួរសម ទទួលរាក់ទាក់ ទទួលដោយសោមនស្ស។ ឧ. ខ្មែរគ្រប់ប្រាណស្វាគមន៍សាមគ្គី។	៣
ស្វិតចៅ	ន. បក្សីពួកចាបមួយប្រភេទ មាឌតូច យំឮសូរសព្ទស្រមៃហាក់ដូចជាពាក្យថា ស្វិតចៅៗ!... ឬថា ស្វិតទេចៅៗ។ ឧ. បក្សីស្វិតចៅនេះ មានរូបរាងតូចស្រស់ស្អាតគួរគយគន់។	១
ស្វិតស្វាញ	គុ. កំណាញ់ស្វិតស្អិតល្អតមិនងាយនឹងចាយទ្រព្យ កំណាញ់ក្រៅតម្រា។ ឧ. សេដ្ឋីនេះកំណាញ់ស្វិតស្វាញ តែចាញ់ប្រាជ្ញាមាណព។ គុ. ដែលសាញទទូចមិនងាយព្រម មិនងាយលែង។ ឧ. សម្តីស្វិតស្វាញ មនុស្សស្វិតស្វាញ។ គុ. ដែលមិនរាថយ ដែលអត់ធ្មត់ ដែលតានតឹងខ្លាំង៖ ឧ. អ្នកស្វិតស្វាញក្នុងការងារ; គុ.កិ. ប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ។	១
ស្អែក	គុ.កិ. ថ្ងៃមួយតបន្ទាប់ពីថ្ងៃនេះ។ ឧ. ស្អែក ខ្ញុំនឹងយកមកឱ្យឯង។	២
ស្អាត	គុ. ដែលល្អ ស្រស់ ដែលមានសម្រស់។ ឧ. សាលារៀនខ្ញុំស្អាត គ្មានសំរាម និងស្រស់បំព្រងជានិច្ច។	៣
សំចៃ	កិ. សន្សំទុកបម្រុងការ ក្បិតក្បៀតការពារភ្ជីខ្វះខាត។ ឧ. សំណាងចេះសំចៃក្រដាសសៀវភៅដែលនៅសល់។	២ ៣
សំណង់	ន. ការសាងសង់ អគារដែលសង់រួចហើយ។ ឧ. នេះជាសញ្ញាការដ្ឋានសំណង់🚧🏗️។	៣
សំណើម	ន. ភាវៈសើម សភាពសើម។ ឧ. ច្រមុះឆ្មាមានសំណើមជានិច្ច។	៣
សំណុំ	ន. អ្វីដែលគេប្រមូលរួមជាដុំ។ ឧ. ដើមត្នោតមានរាងមូលទ្រសំណុំស្លឹកពណ៌បៃតង។	២
សំបុត្រ	ន. អក្សរសរសេរលើក្រដាសជំនួសឱ្យការនិយាយ។	២
សំពង	កិ. វាយពេញកម្លាំងដៃដោយដំបងឬកំណាត់ឈើ។ ឧ. កសិករក៏ទាញដំបងសំពងខ្លា។	៣
សំយាក	កិ. ធ្វើឱ្យធ្លាក់សស្រេកសស្រាក។	២

សំរាម	ន. កាកសំណល់ឬវត្ថុដែលមិនចង់បានឬត្រូវចោល។ ឧ. ពួកគាត់កំពុងឱនរើសសំរាមដាក់ថង់។	៣
សំឡេង	ន. សទ្ទជាតិដែលមកប៉ះសោតប្បសាទឱ្យឮ។ ឧ. គេឮសំឡេងមាន់រងាវដាស់បូណា។	៣
សះស្បើយ	កិ. បាត់ឈឺស្រឡះ ជាស្រឡះពីជំងឺ។ ឧ. សូមជូនពរអ្នកគ្រូឱ្យឆាប់ជាសះស្បើយ។	៣
ស័ក្តិសិទ្ធិ	ន. ការសម្រេចដោយអំណាច, គុ. ដែលខ្លាំងពូកែ ដែលមានអំណាច សម្រេចប្រយោជន៍បាន។	៤
ហ	**ហ**	
ហនុមាន	ន. ឈ្មោះស្តេចពានររបស់ព្រះរាម។ ឧ. ព្រះរាមបង្គាប់ឱ្យហនុមានធ្វើថ្ពល់កាត់សមុទ្រ។	៤
ហាត់ប្រាណ	កិ. បង្វឹកខ្លួនធ្វើចលនា ហាត់ឱ្យយឺតសរសៃក្នុងខ្លួន។ ឧ. យើងហាត់ប្រាណដើម្បីបញ្ចេញញើសបញ្ចេញជាតិពុល។	៣
ហិង្សា	ន. ការបៀតបៀន ការធ្វើអាក្រក់រកគ្នា ការធ្វើទុក្ខគ្នា។ ឧ. គ្រឿងញៀនេះក៏បង្កឱ្យមានអំពើចោរកម្មនិងហិង្សា។ ឧ. មនុស្សត្រូវកុំឱ្យមានហិង្សារកគ្នា។	៣; ៤
ហិន	កិ. វិនាស សាបសូន្យ លិចលង់។ ឧ. ហិនទ្រព្យ។	៤
ហូរហែ	គុ.កិ. ដែលហែៗគ្នាមិនដាច់ ដែលចេះតែមានបន្តគ្នាមិនដាច់។ ឧ. មានគេទៅមកហូរហែ។	២
ហើរ	កិ. ទៅឯអាកាសដោយកម្លាំងស្លាបជក់ខ្យល់។ ឧ. ចាបហើរ។ កិ. ខ្ចរខ្ចាយទៅ៖ ឧ. សម្តីហើរតាមខ្យល់។ គុ. ដែលថយខ្សោយពណ៌៖ ឧ. សំពត់ហើរពណ៌។	១
ហេដ្ឋារចនាសម្ព័ន្ធ	ន. មធ្យោបាយនិងទំនាក់ទំនងផលិតកម្មដែលជាមូលដ្ឋានសង្គមដូចជាផ្លូវ ស្ពាន។ ឧ. គ្រោះទឹកជំនន់បណ្តាលឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធជាច្រើន។	៣
ហេតុ	ន. ដើមទងព្រឹត្តិការណ៍ឬរឿងអ្វីមួយដែលកើតឡើង។ ឧ. ពីព្រោះ មកពី ដោយសារ	៣

ហេតុការណ៍	ន. ដំណើរ ឬរឿងរ៉ាវដែលកើតឡើងដោយហេតុផ្សេងៗ។ ឧ. ទាំងអ្នកដំណើរបានស្ទុះទៅមើលហេតុការណ៍នេះ។ ឧ. ខ្ញុំត្រូវទៅដើម្បីពិនិត្យសង្កេតហេតុការណ៍ដល់ទីកន្លែង។	៣ ៥ ៦
ហោរា	ន. គ្រូទាយ។ ឧ. ឧកញ៉ាហោរានោះឈ្មោះខៀវ។	៥
ហ្អ	ន. អ្នកទាក់ដំរី ឬអ្នករក្សាដំរី។ ឧ. ដំរីព្រេចហ្អស្លាប់ទៅ។	៥
ហ្អងសៅ	កិ. មានមន្ទិល មិនបរិសុទ្ធ។	៦
ហ្អតចត់	គុ. ត្រឹមត្រូវបរិសុទ្ធ គ្រប់គ្រាន់ ស្អាត។ ឧ. គុណខិតខំរៀនសូត្រហើយធ្វើកិច្ចការដោយហ្អត់ចត់។	៦
ឡិកឡក់	គុ.កិ. ដែលនិយាយភាសារបស់ខ្លួនមិនទាន់ច្បាស់។ ឧ. កូនធំហើយ កុំនិយាយឡិកឡក់ដូចកូនក្មេងទៀត។	២
ឡូ	ន. ចំណែកផ្សេងៗក្នុងការបែងចែក ឬចំនួនផ្សេងដែលបែងចេញជាភាគ។ ឧ. ដីមួយឡូ ផ្លែឈើមួយឡូ។	៦
ឡើង	កិ. ១. ស្ទុះពីក្រោមមកលើ។ ឧ. ស្លេស្ម៉ឡើង។ ឧ. បូណាឡើងឈរួចពោលថា៖ “អូ! សួស្តីបងៗ...” ២. ទៅខាងលើ ទៅពីក្រោមទៅលើ។ ឧ. ពូឡើងជណ្តើរ។ ៣. ស្ទុះខ្ពស់ទៅលើ។ ឧ. ខ្លែងឡើងខ្ពស់ណាស់។ ៤. ចាប់តោងជាន់ប្រវាទៅលើ។ ឧ. ក្មេងឡើងដើមឈើ។ ៥. ចាប់តោងលូតទៅលើ។ ឧ. ម្លូឡើងជន្លង់។ ៦. គុ.កិ. ដែលចេះតែចម្រើនទៅខាងលើ។ ឧ. ខ្ពស់ឡើង ធំឡើង ល្អឡើង, កាន់តែច្រើនឡើង ដើរឆាប់ឡើង!	៣
ឡេឡោះ	គុ. ដែលលាយដោយការលេងឥតយកជាការពិតពុំបាន។ ឧ. កុមារម្នាក់នេះប្រើសម្តីឡេះឡោះ។ គុ.កិ. កូនកុំនិយាយឡេះឡោះច្រើន។	១
អ	**អ**	
ឯ	ធ. ខាង ចំណែកខាង នា ឮដំ ត្រង់។ ឧ. គាត់នៅឯកើតភូមិ។ ឈ. រឹង ចំណែកឯ។ ឧ. ម៉ាក់ទៅផ្សារ ឯប៉ានៅក្រោយផ្ទះ។	៣

ឧកញ៉ា	ន. អ្នកមានបុណ្យសក្តិខ្ពស់ អ្នកមានទ្រព្យច្រើន។	២
អាកប្បកិរិយា	ន. អាការៈនៃរាងកាយ លំនាំនៃរាងកាយឬក៏ឫកពា។ ឧ. ខ្ញុំបានសម្តែងអាកប្បកិរិយាមិនសមរម្យចំពោះមិត្ត។ ឧ. អ្នកមីងមានអាកប្បកិរិយារម្យទមល្អណាស់ និយាយស្តីមួយៗតែច្បាស់ ស្លៀកពាក់ស្អាតតាមពេលតាមពិធី ហើយឧស្សាធ្វើការងារណាស់។	៣; ៤; ៥; ៦
ឯករាជ្យ[១]	ន. ឈ្នះ ជ័យជម្នះ, រាជាណាចក្រមិនចំណុះនៃប្រទេសដទៃ។ ឧ.អ្នកមកលេងរាជធានីភ្នំពេញច្រើនទៅវត្តភ្នំវិមានឯករាជ្យ។	២
ឯករាជ្យ[២]	ន. ១.រាជ្យនៃស្តេចតែមួយ។ ២.ភាពនៃប្រទេសដែលមានសិទ្ធិនិងសេរីភាពពេញបរិបូរក្នុងការគ្រប់គ្រងខ្លួនឯងមិនមែនជាចំណុះនៃប្រទេសដទៃ។ ៣.ម្ចាស់ការលើការងារឬជីវិតខ្លួនឯង។ ឧ. យុវជនគួរមានភាពឯករាជ្យ ដើម្បីរៀនពីបទពិសោធន៍ថ្មីៗក្នុងសង្គម។	២
អាការៈ	ន. កិរិយា ឫកពា លំនាំ ទ្រង់ទ្រាយ ភិនភាគ គ្រឿងសម្គាល់។ ឧ. សម្តីរបស់គាត់បានចេញអាការៈឱ្យដឹងថាល្អឬអាក្រក់។ ឧ. អ្នកជំងឺមានអាការៈរាកនិងក្អួត។	២; ៣; ៤
ឱកាស	ន. វេលាទំនេរ ចន្លោះ កាលានុវត្តភាព។ ឧ. គេនិយមលេងល្បែងប្រជាប្រិយក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ។	៣
អាកាសធាតុ	ន. បរិយាកាសដូចជាសើម ត្រជាក់ ឬក្តៅក្នុងកន្លែងមួយ។ ឧ. អាកាសធាតុមានការប្រែប្រួល។	៣
អក្ខរា	ន. អក្សរ។ ឧ. ខ្ញុំសូមបញ្ចប់អក្ខរាតែត្រឹមនេះចុះ។	៥
អក្សរសាស្ត្រ	ន. ក្បួនខ្នាតរបស់អក្សរ។ ឧ. សម្តេចសង្ឃជាអ្នកប្រាជ្ញខាងផ្លូវធម៌ផងខាងអក្សរសាស្ត្រផង។	៥
អក្សរសិល្ប៍	ន. ផ្នែកមួយនៃអក្សរសាស្ត្រ ដែលអ្នកនិពន្ធលើកពីបញ្ហាមនុស្សបញ្ហាសង្គមមកចោទនិងដោះស្រាយដោយប្រើសិល្ប៍វិធី។ ឧ. រឿងដែលចេះចាំតៗគ្នាគ្មានឈ្មោះអ្នកនិពន្ធ យើងតែងហៅថា អក្សរសិល្ប៍ប្រជាប្រិយ។	៥
អគារ	ន. មន្ទីរ ផ្ទះ រោង។ ឧ. នៅមុខអគារនីមួយៗមានសួនច្បារ។	៣
អគារសិក្សា	ន. មន្ទីរសម្រាប់រៀនសូត្រ សាលារៀន។	៦

អគ្គមហេសី	ន. មហេសីចម្បងរបស់មហាក្សត្រ។ ឧ. ព្រះនាងសោមាឬនាងនាគ ជាអគ្គមហេសីរបស់ព្រះចៅង។	៣
អគ្គិសនី	ន. ភ្លើងអេឡិចទ្រិក។ ឧ. ស្រុកយើងក៏មានប្រើអគ្គិសនីដើរដោយវារី។ ឧ. ទូរសព្ទនេះអាចនាំសំឡេងមនុស្សតាមខ្សែអគ្គិសនី។	៣; ៥
អគ្គិសនីវិភាគ	ន. ១.ប្រតិកម្មបំបែកនៃអង្គធាតុក្រោមអំពើនៃចរន្តអគ្គិសនីជាប់។ ឧ. គេយកដីនោះទៅធ្វើអគ្គិសនីវិភាគយកមាសសុទ្ធ។ ២.ការព្យាបាលរោគដោយកាំរស្មីអ៊ិចឬកាំរស្មីផ្សេងៗទៀត។	៦
អាគ្នេយ៍	ន. ខាងកើតឆៀងត្បូង។ ឧ. កម្ពុជាស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍។	៣
អង្គការ	ន. ស្ថាប័នមនុស្សដែលមានគោលបំណងជាក់លាក់ជាពិសេស អាជីវកម្ម សង្គម សមាគម។ល។ ឧ.តើមានអង្គការឬសប្បុរសជនណាខ្លះចុះជួយជនរងគ្រោះ?	៣
អង្គការ	ន. ទីកន្លែងចាត់ការធំៗ, បែបផែនរបៀបរៀបចំកិច្ចការដែលរដ្ឋឬក្រុមរាជការណាមួយបង្កើតឡើង ដើម្បីប្រព្រឹត្តទៅកាន់សេចក្តីចម្រើន។ ឧ. អង្គការសង្គ្រោះសត្វស្លាបឃ្លាំមើលឃើញសត្វក្រៀលចុះមកច្រើនឡើង។	៦
អង្គញ់	ន. វាល្លិមានដើមធំរឹង ផ្លែធំវែងៗ ផ្លែមួយៗមានគ្រាប់ច្រើនធំៗ រាងមូលសំប៉ែត កាលណាទុំមានសាច់រឹង។ ឧ. ល្បែងបោះអង្គញ់នេះ គេចែកគ្នាជាពីរក្រុម គឺក្រុមបុរសនិងក្រុមស្ត្រី។	៣
អង្គ	ន. រូបរាងកាយ ចំណែកនៃរាងកាយ។ ឧ. កុមារទាំងអស់ត្រូវស្វះស្វែងរកវិជ្ជាគ្រប់អង្គ។	៥
អង្រុត	ន. នេសាទុបករណ៍មួយប្រភេទធ្វើដោយបន្ទោះឫស្សីមូលៗ រាងក្រឡម តូចខាងមាត់លើធំគាយខាងក្រោម សម្រាប់រុតឬក្រុងមច្ឆជាតិ។	៥
អាចារ្យ	ន. អ្នកប្រដៅ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ។	៦
អាជីព	ន. មុខរបរចិញ្ចឹមជីវិត ការចិញ្ចឹមជីវិត។ ឧ. ការជ្រើសរើសអាជីពដែលខ្លួនស្រឡាញ់និងប្រសប់ ធ្វើឱ្យយើងមិនធុញនឹងកិច្ចការប្រចាំថ្ងៃ។ ឧ. ប្រជាជនពោធិ៍សាត់មួយចំនួនចាប់អាជីពចម្លាក់ថ្មកែវ។	៣ ៥ ៦

អាជីវករ	ន. អ្នកប្រកបមុខរបរចិញ្ចឹមជីវិត។ ឧ. មន្ត្រីកាំកុងត្រូលបានណែនាំដល់អាជីវករពីរចំណុច។	៥
អាជ្ញា	ន. អំណាច ការគ្រប់គ្រង ការបង្គាប់ ច្បាប់បញ្ញត្តិ។ ឧ. កញ្ជ្រោងថា ព្រះឥន្ទ្រឱ្យអាជ្ញាកាន់។	៤
អាជ្ញាធរ	ន. អ្នកទ្រទ្រង់នូវអាជ្ញា អ្នកកាន់អំណាច...។ ឧ. អាជ្ញាធរដែនដី និងប្រជាជនរួមសាមគ្គីគ្នា ទើបភូមិឃុំបានសុខក្សេមក្សាន្ត។ ឧ. ក្រសួងបានប្រកាសជូនដំណឹងដល់អាជ្ញាធរដែនដី។	៣; ៥
អញ្ជើញ	កិ. ១.ស្នើឬហៅអ្នកណាម្នាក់ទៅធ្វើអ្វីមួយឬកន្លែងណាមួយ។ ឧ. តើម៉ាក់អញ្ជើញទៅជាមួយកូនដែរឬទេ? ឧ. ពូឯងអញ្ជើញមកលេង។ ២.ហៅគោរព បង្គាប់ ឬលំអុតលំឱន(ឱ្យទៅឬចូល)។ ឧ. ខ្ញុំអញ្ជើញគាត់ហើយ។	២
ឆ្ងង់	ត្រង់ នៅនា ឯ។ ឧ. ហ្វូងបក្សីហើរឆ្ងង់អាកាស។	១
ឆ្ងង់អាកាស	ន. ក្នុងអាកាស ចំត្រង់អាកាស។ ឧ. ស្លឹកដូចឆត្របើកចោលកណ្តាលឆ្ងង់អាកាស។	២
ឥណទាន	ន. ការឱ្យខ្ចី។	៦
អាណានិគមនិយម	ន. លទ្ធិ ឬអធ្យាស្រ័យនៃជនខ្លះដែលចូលចិត្តតែខាងជ្រៀតជ្រែកវាយដណ្តើមយកប្រទេសដទៃមកធ្វើជាស្រុកចំណុះខ្លួន។ ឧ. លោកត្រូវពួកអាណានិគមបារាំងចាប់បាន។	៥
អាណាព្យាបាល	ន. អ្នកគ្រប់គ្រង ថែរក្សា និងគាំពារកូនចៅឬអ្នកក្នុងបន្ទុក។ ឧ. អ្នកមានគុណមានដូចជាឪពុកម្តាយ អាណាព្យាបាល ...។ ឧ. សូមអាណាព្យាបាលសិស្សមកចុះឈ្មោះឱ្យបានរួសរាន់។	៣; ៥
អាណិកជន	ន. ជនជាតិមួយដែលទៅរស់នៅប្រទេសផ្សេងទៀត ហើយចូល សញ្ជាតិជនជាតិនេះ។	៦
អណ្តាត	ន. ជ្លីវ៉ា គឺអវយវៈមួយយ៉ាងនៅក្នុងមាត់...សម្រាប់គ្រលៀសគ្រលៀវ។ ឧ. "ល្អឬអាក្រក់"មកតែពីសម្តីនិងចិត្តនេះឯង គឺអណ្តាតនិងបេះដូង។	៣
អតិថិជន	ន. មនុស្សជាភ្ញៀវអ្នកមកទិញ អ្នកមករកពឹងពាក់។ ឧ. ប្រជាជនខិតខំកែច្នៃគុណភាពទំនិញដើម្បីបម្រើតម្រូវការអតិថិជន។	៥

អតីត	គុ. ដែលកន្លងទៅហើយ។ ឧ. អតីតកាល គឺកាលដែលកន្លងទៅហើយ។ ឧ. ឧបជាអតីតមេគុកទួលស្លែង។	៥
អតីតកាល	ន. កាលដែលកន្លងទៅហើយ។ ឧ. នៅសារមន្ទីរ យើងអាចរៀនសូត្របានអំពីប្រវត្តិសាស្ត្រខ្មែរយើងក្នុងអតីតកាល។	៣; ៥
ឧតុនិយម	ន. ដំណើរកំណត់រដូវ ការពិនិត្យបាតុភូតធម្មជាតិ។ ឧ. ខ្ញុំមិនទាន់សូវស្គាល់ក្រសួងធនធានទឹកនិងឧតុនិយមនៅឡើយ។	៥
អត្ត	ន. ខ្លួន អត្មា។ ឧ. អត្តសញ្ញាប័ណ្ណខ្ញុំផុតកំណត់ហើយ។	៣
ឧត្តម	គុ. ខ្ពង់ខ្ពស់ ល្អ ប្រសើរ ថ្លៃថ្លា។	៦
ឧត្តមសិក្សា	ន. កម្រិតនៃការអប់រំនៅសាកលវិទ្យាល័យ។ ឧ. ប៉ែនបានប្រឡងជាប់ចូលឧត្តមសិក្សា។	៥
ឧត្តរ	ន. ទិសខាងជើង។ ឧ. សៀមរាបជា«តារៈនៅទិសឧត្តរ»។ ឧ. កប៉ាល់បារាំងបាននាំលោកឆ្ពោះទៅកាន់ទិសឧត្តរ។	៣ ៥
អត្តសញ្ញាណជាតិ	ន. គ្រឿងសម្គាល់ជាតិមួយ សញ្ញាសម្គាល់ជាតិមួយ។ ឧ. អត្តសញ្ញាណជាតិនៃកម្ពុជាមានប្រាសាទអង្គរវត្ត ទង់ជាតិ ភ្លេងជាតិ ព្រះសង្ហារ។	៣
ឧត្តុង្គឧត្តម	គុ. ឧត្តមលើសលែង ប្រសើរកន្លង។ ឧ.តួនាទីជាប្រធានអាស៊ាន នេះ ជាមោទនភាពជាតិដ៏ឧត្តុងឧត្តមមួយរបស់កម្ពុជា។	៣
អត្ថន័យ	ន. ខ្លឹមសារ ប្រយោជន៍។ ឧ. បុណ្យសមុទ្រផ្តោតទៅលើអត្ថន័យសំខាន់បួន។	៣
អត្ថន័យ	ន. ការពន្យល់ សេចក្តី ការរៀបរាប់លក្ខណៈនៃវត្ថុផ្សេងៗ។	៥;៦
អាត្មា	ន. ខ្លួន ចិត្ត។ ឧ. ព្រះសង្ឃប្រើពាក្យ(អាត្មា) មិនប្រើ(ខ្ញុំ)ទេ។ ឧ. មនុស្សសត្វត្រូវរកស៊ីចិញ្ចឹមអាត្មា។	៥; ៦
អាទិត្យ	ន. ពន្លឺដ៏ក្រៃលែង គឺដួងពន្លឺដែលបំភ្លឺលោកក្នុងវេលាថ្ងៃ។ ឧ. ព្រះអាទិត្យក៏ជួយក្រើនបូណាឱ្យក្រើកឡើង។	៣
ឪទឹន	ន. ក្រឡមានមាត់តូចល្មម សម្រាប់ដាក់ទឹកត្រីជាដើម។	២
ឧទ្ទិស	កិ. សំដៅចំពោះ។ ឧ. កូនឧទ្ទិសភាគផលកុសលបុណ្យទានឆ្ពោះអ្នកចែកឋាន។	៦
ឧទ្ទិសកុសល	កិ. បញ្ចេញវាចាផ្សាយផលជូនដល់អ្នកមានគុណ ឬអ្នកណាម្នាក់។	៦

ឥទ្ធិពល	ន. កម្លាំងរបស់ឫទ្ធិ កម្លាំងរបស់អំណាច។ ឧ.ការផឹកស្រាលើសកម្រិតជះឥទ្ធិពលដូចជាស្រវឹងវង្វេង អួតក្អេងក្អាង ផឹកទាល់តែដាច់លុយហើយជំពាក់គេ បញ្ចាំខ្ទេចខ្ទី ខូចសុខភាព ឬអាចបង្កជាហិង្សានិងគ្រោះថ្នាក់ចរាចរណ៍។	៣
អធិកអធម	គុ. ហឹកហ៊ាក់ ក្រៃលែង លើសលន់ រុងរឿង។	៦
អធិបតីភាព	ន. ភាពជាធំ ជាប្រធាន ជាប្រមុខ ឬជាម្ចាស់។ ឧ. សាលានឹងរៀបចំពិធីប្រគល់រង្វាន់ក្រោមអធិបតីភាពអភិបាលខេត្ត។	៥
អធិរាជ	ន. ស្តេចដែលធំជាងស្តេចទាំងឡាយក្នុងប្រទេសជិតខាង។ ឧ. ដុនប៉េដ្រូជាអធិរាជនៃប្រទេសប្រេស៊ីល។	៥
អធ្យាស្រ័យ	ន. ក្តីអនុគ្រោះ ការអត់ឱន ការមិនប្រកាន់ទោស។ ឧ. អ្នកជិតខាងត្រូវតែចេះយោគយល់គ្នានិងមានអធ្យាស្រ័យដល់គ្នា។	២;៣;៦
ឱន	កិ. បន្ទន់ចុះទៅមុខ បន្ទន់កាយចុះក្រោមពីបញ្ឈរ។ ឧ. ពួកគាត់ឱនវើសសំរាម។	៣
អនាគត	ន. សម័យឬកាលខាងមុខ អ្វីដែលកើតឡើងនៅពេលខាងមុខ។ ឧ. ក្នុងបឋមវ័យ យើងត្រូវស្រាវស្វែងរកវិជ្ជាដើម្បីអនាគត។ ឧ. អនាគត ខ្ញុំចង់ក្លាយជាគ្រូបង្រៀន។ ឧ. ទោះបីជើងពិការ សុភាពតែងស្រមៃចង់បានការងារសមរម្យមួយក្នុងពេលអនាគត។	២;៣;៥;៦
អនាគត	ន. ពេលខាងមុខ។ ឧ. ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតភ្លឺស្វាង។	២
អនាគតល្អ	ន. ការទទួលបានជោគជ័យនិងរីករាយ។ ឧ. កូនៗមានភារកិច្ចសំខាន់ជាងគេ គឺខិតខំរៀនសូត្រដើម្បីមានអនាគតល្អ។	៣
